ជំពូក ៥

ធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គំរោង

Description of Environment

ជំពូកទី ៥

ធនធានបរិស្ថានដែលមានស្រាប់នៅក្នុងតំបន់គំរោង

ក្នុងជំពូកនេះគឺ ពិពណ៌នាអំពីស្ថានភាពធនធានបរិស្ថានដែលមានស្រាប់ (បរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងបរិស្ថានសង្គម) ក្នុងតំបន់ទីតាំងគំរោងដែលប្រមូលព័តិមានបានពីស្ថាប័ន អង្គភាពពាក់ព័ន្ធ រួមទាំងការចុះអង្កេតសិក្សាស្រាវជ្រាវ ផ្ទាល់ពីមូលដ្ឋាន ដើម្បីបានទិន្នន័យគ្រឹះសំរាប់ធ្វើការវិភាគ និងវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (ESIA) ដែលនឹងកើត ឬអាចកើតឡើងពីសកម្មភាពនៃការអនុវត្តគំរោង ។

ក្នុងជំពូកនេះក៏រាយការណ៍ខ្លះៗផងដែរអំពីសំណូមពរ និងប្រឹក្សាពិគ្រោះយោបល់ជាមួយសាធារណជន និងស្ថាប័ន-អង្គភាពពាក់ព័ន្ធមួយចំនួននៅក្នុងតំបន់ទីតាំងគំរោង ។

៥.១ បរិស្ថានធម្មជាតិ (Natural Environment)

៥.១.១ ធនធានរូបសាស្ត្រ (Physical Resources)

៥.១.១.១ អាកាសធាតុ (Climate)

១- របបទឹកភ្លៀង (Rainfall)

តំបន់អារ៉ែងនេះមានបរិមាណទឹកភ្លៀងធ្លាក់ខ្ពស់បង្គួរ បើប្រៀបទៅតំបន់ទំនាបកណ្តាល ព្រោះវាស្ថិតនៅក្បែរតំបន់មាត់សមុទ្រ និងតំបន់ភ្នំជាប់ខេត្តកោះកុង នៃប្រទេសកម្ពុជា និងនៅជ្រលងនៃជួរភ្នំក្រវាញក្នុង ខេត្តពោធិ៍សាត់។ គ្មានទិន្នន័យទឹកភ្លៀងកត់ត្រានៅតំបន់គំរោងឡើយមានតែស្ថានីយ៍កត់ត្រាទឹកភ្លៀងដែលនៅជិតជាងគេនោះ គឺស្ថានីយ៍ស្មាច់មានជ័យ (ក្រុងខេមរភូមិន្ទ) ខេត្តកោះកុង។

បរិមាណទឹកភ្លៀងធ្លាក់ គិតជាមធ្យមរយៈពេល១២ឆ្នាំ គិតពីឆ្នាំ **១៩៩៩** ដល់ **២០១០** គឺ **៤០៩៣.៦៨មម** (Return Period 12 years) (ប្រភពទិន្នន័យបានពីមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកុងកោះ) ។ ក្នុងតារាង១០បានបង្ហាញកំពស់ ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំខ្ពស់បំផុតរយៈ ពេល ១២ឆ្នាំ គឺនៅខែកក្កដា ឆ្នាំ ២០០៦ មានដល់ **១៦៩៥.៩ មម.**។

តារាង ១០: បរិមាណទឹកភ្លៀង គិតជា ម.ម ក្នុងរយៈពេល ១២ឆ្នាំ (១៩៩៩-២០១០)

Month / Years	Jan I	Feb II	Mar III	Apr IV	May V	Jun VI	Jul VII	Aug VIII	Sep IX	Oct X	Nov XI	Dec XII	Yearly total
1999	0	143.8	160.1	461.7	222.6	684.2	901.6	410.5	294.6	183.3	0	0	3462.40
2000	117.3	78.5	74.2	148	450.7	780.9	1048.1	1531.6	203	428.9	43	95.6	4999.80
2001	121.9	80.8	155.7	224.4	584.4	1157.5	712.1	931.6	427.1	356.9	26	9.1	4787.50
2002	0	0	86.3	172	369.3	782.4	504.3	886.2	604.4	77	79.5	38.2	3599.60
2003	0	37.7	38.7	91.3	251.3	291.4	929.4	593.8	493.9	372.4	5	0	3104.90
2004	50.6	94.9	54.8	37.2	296.8	599.2	884.6	1052.8	242	238.5	60.3	0	3611.70
2005	3.8	15.2	68	133.2	334.9	728.3	1040.8	466	607.4	220.8	244.6	46.7	3909.70
2006	48.7	147.7	64.9	105.5	521.5	413.7	1695.9	864.4	584.2	528.5	123	6.2	5104.20
2007	0	32	47.8	237.6	325.1	390.8	930.1	789.3	673.3	337.6	46.9	19.1	3829.60
2008	2.8	47.7	108.5	347.7	638.8	558.2	701.2	760.7	651.2	273.9	60.0	38.5	4189.20
2009	2.8	69.1	189.4	203.0	384.4	442	1226.6	219.4	1616.6	102.6	NA	NA	4455.90
2010	78	141.8	163.4	151.1	323.4	704.8	603.3	675	394.6	566.0	167.4	0.0	3968.80
Mean	35.49	74.10	100.98	192.73	391.93	627.78	931.50	765.11	566.03	307.20	77.79	23.04	4093.68
Min	0.00	0.00	38.70	37.20	222.60	291.40	504.30	219.40	203.00	77.00	0.00	0.00	1593.60
Max	121.90	147.70	189.40	461.70	638.80	1157.50	1695.90	1531.60	1616.60	566.00	244.60	95.60	8467.30





Source: Department of Meteorology, Ministry of Water Resources and Meteorology

២- សីតុណ្ហភាព (Temperature)

ប្រភពទិន្នន័យបានពីនាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម និងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តកោះកុង បានបង្ហាញថា :

- មធ្យមភាគនៃសីតុណ្ហភាពអតិបរមារយៈពេល ១ ឆ្នាំ មានកំរិត ៣២°C
- មធ្យមភាគនៃសីតុណ្ហភាពអប្បបរមារយៈពេល ១ ឆ្នាំ មានកំរិត ២៣.៨°C
- មធ្យមភាគនៃសីតុណ្ហភាពរយៈពេល ១ ឆ្នាំ មានកំរិត ២៧.៩°C
- សីតុណ្ហភាពអតិបរមារយៈពេល ១៥ ឆ្នាំ ខ្ពស់បំផុតមានកំរិត ៣៥.៣°C នៅឆ្នាំ ១៩៩៩
- សីតុណ្ហភាពអប្បបរមារយៈពេល ១៥ ឆ្នាំ ទាបបំផុតមានកំរិត ២០.១°C នៅឆ្នាំ ២០១០

តារាង ១១: សីតុណ្ហភាពអតិបរមាប្រចាំ ខែ គិតជា °C ក្នុងរយៈពេល១៥ឆ្នាំ (១៩៩៥_២០១០)

Month / Years	Jan I	Feb. II	Mar. III	Apr. IV	May V	Jun. VI	Jul. VII	Aug. VIII	Sep. IX	Oct. X	Nov. XI	Dec. XII	Yearly Mean
1995	31.0	30.2	32.5	34.2	33.2	33.7	32.2	30.2	31.3	30.0	32.3	31.3	**31.8**
1996	31.3	32.0	33.6	33.7	33.1	33.6	31.0	30.7	31.1	30.2	32.0	30.0	**31.9**
1997	31.2	32.0	35.0	35.0	34.0	34.5	32.3	30.6	31.6	31.5	31.1	31.3	**32.5**
1998	31.0	32.2	34.2	34.6	34.7	33.3	30.9	32.4	30.3	31.5	30.2	29.3	**32.1**
1999	31.5	32.6	34.2	35.3	33.3	33.1	31.5	32.0	31.0	30.9	30.2	30.6	**32.2**
2000	30.3	32.5	33.2	34.2	32.5	33.6	30.2	32.1	30.2	30.4	30.1	30.2	**31.6**
2001	31.0	32.6	33.1	34.0	32.5	30.6	26.5	30.5	29.8	31.9	31.9	32.3	**31.4**
2002	31.1	32.6	33.0	34.0	32.6	30.6	30.6	30.3	31.1	32.2	32.6	32.4	**31.9**
2003	31.0	32.7	33.3	34.3	32.4	32.1	31.0	32.3	32.0	31.2	32.0	31.0	**32.1**
2004	32.0	31.9	33.0	34.4	32.7	31.0	30.3	29.7	31.2	32.5	33.0	32.9	**32.1**
2005	31.2	32.9	32.8	33.7	32.6	31.2	29.5	30.4	29.9	31.9	32.2	31.1	**31.6**
2006	32.1	32.1	33.1	33.0	32.1	31.3	28.6	29.0	30.4	31.2	33.4	32.8	**31.6**
2007	32.8	32.1	33.0	34.1	33.4	33.0	30.9	30.7	30.7	31.2	31.9	32.5	**32.2**
2008	32.6	32.3	32.4	33.1	31.9	31.6	30.8	30.7	30.9	31.9	32.6	32.7	**32.0**
2009	30.9	31.7	32.7	33.0	32.3	31.3	30.6	31.8	29.8	31.3	33.1	33.2	**31.8**
2010	33.0	33.3	34.0	34.5	34.8	33.0	31.3	31.3	32.4	31.5	32.5	32.9	**32.9**
Monthly total	**504.0**	**515.7**	**533.1**	**545.1**	**528.1**	**517.5**	**488.2**	**494.7**	**493.7**	**501.3**	**511.0**	**506.5**	**511.6**
Monthly mean	**31.5**	**32.2**	**33.3**	**34.1**	**33.0**	**32.3**	**30.5**	**30.9**	**30.9**	**31.3**	**31.9**	**31.7**	**32.0**
Max	**33.0**	**33.3**	**35.0**	**35.3**	**34.8**	**34.5**	**32.3**	**32.4**	**32.4**	**32.5**	**33.4**	**33.2**	**33.5**

តារាង ១២: សីតុណ្ហភាពអប្បបរមាប្រចាំ ខែ គិតជា °C ក្នុងរយៈពេល១៥ឆ្នាំ (១៩៩៥_២០១០)

Month / Years	Jan I	Feb. II	Mar. III	Apr. IV	May V	Jun. VI	Jul. VII	Aug. VIII	Sep. IX	Oct. X	Nov. XI	Dec. XII	Yearly Mean
1995	21.0	23.5	23.4	24.6	25.3	24.9	24.1	24.3	24.4	24.5	23.3	23.2	**23.9**
1996	21.5	23.0	23.1	25.0	25.5	25.0	24.5	24.0	24.5	24.0	23.5	22.6	**23.9**
1997	21.6	22.6	24.5	25.2	24.7	24.3	23.9	23.9	24.3	24.6	24.0	22.5	**23.8**
1998	21.5	23.0	24.0	24.3	24.2	24.5	23.5	23.5	25.0	23.6	24.0	22.6	**23.6**
1999	20.6	22.9	23.5	24.3	24.3	24.1	24.0	23.2	23.6	23.5	23.5	21.9	**23.3**
2000	21.5	23.0	23.7	23.6	24.6	25.2	23.5	23.6	23.0	24.3	23.5	21.5	**23.4**
2001	22.6	23.2	24.4	24.4	25.1	25.0	24.4	24.3	24.6	24.6	24.3	23.4	**24.2**
2002	21.6	23.7	23.9	24.3	25.0	25.0	24.5	34.8	24.5	24.6	24.4	23.4	**25.0**
2003	20.3	21.8	24.0	24.9	25.0	22.3	23.8	23.5	22.0	23.9	23.6	22.7	**23.2**
2004	22.6	23.3	24.7	25.2	25.4	25.3	24.4	24.8	24.3	24.0	24.1	22.0	**24.2**
2005	22.4	23.8	23.7	24.7	25.1	25.0	24.6	24.9	24.3	24.7	24.4	23.5	**24.3**
2006	23.4	24.5	25.0	25.0	25.0	25.2	24.4	24.4	24.5	24.1	24.3	22.8	**24.4**
2007	22.4	21.5	23.0	24.1	24.4	24.7	24.2	24.7	24.8	24.9	24.2	22.9	**23.8**
2008	21.6	23.7	23.9	24.9	25.0	25.3	31.9	34.8	24.4	24.8	24.4	23.4	**25.7**
2009	20.8	23.1	24.0	24.8	24.8	24.8	24.2	24.9	24.0	24.2	23.1	21.1	**23.7**
2010	20.6	20.7	32.7	20.7	20.8	20.1	20.1	19.5	20.1	20.1	19.7	18.8	**21.2**
Monthly total	**346.0**	**367.3**	**391.5**	**390.0**	**394.2**	**390.7**	**390.0**	**403.1**	**382.3**	**384.4**	**378.3**	**358.3**	**381.3**
Monthly mean	**21.6**	**23.0**	**24.5**	**24.4**	**24.6**	**24.4**	**24.4**	**25.2**	**23.9**	**24.0**	**23.6**	**22.4**	**23.8**
Min	**20.3**	**20.7**	**23.0**	**20.7**	**20.8**	**20.1**	**20.1**	**19.5**	**20.1**	**20.1**	**19.7**	**18.8**	**20.3**

៣- ល្បឿន និងទិសដៅខ្យល់ (Wind Speed and Wind Direction)

យោងតាមរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូងរបបខ្យល់នៅ ខេត្តពោធិ៍សាត់ គ្មានការសិក្សាដោយស្ថាប័នរដ្ឋាភិបាលណាមួយទេ។ ក្រុមការងារសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង បានទៅទំនាក់ទំនង លោក **ឡុង សារ៉ាវុធ** ប្រធាននាយកដ្ឋានឧតុនិយមនៃក្រសួងធនធានទឹក និងឧតុនិយមបានបញ្ជាក់ថា ទិសដៅល្បឿនខ្យល់ក្នុងតំបន់គំរោងគ្មានឬនៅខេត្តពោធិ៍សាត់គ្មានទិន្នន័យទេ ក៏ប៉ុន្តែនៅឆ្នាំ ២00៦ SAWAC បានធ្វើការទំនាក់ទំនងលោកស្រី **សេង វណ្ណារ៉េត** អតីតប្រធាននាយកដ្ឋានឧតុនិយម ហើយលោកស្រីបានមានប្រសាសន៍ថា ចំពោះពន្លឺថ្ងៃនៅខេត្តជុំវិញ នាយកដ្ឋានមិនបានសិក្សាទេ

ប៉ុន្តែមានទិន្នន័យចំពោះល្បឿនខ្យល់នៅខេត្តពោធិ៍សាត់ និងក្រុងព្រះសីហនុហើយលោកស្រីអាចយកមកធ្វើការវិភាគសំរាប់ទិន្នន័យខ្យល់ក្នុងការប្រើប្រាស់ទិន្នន័យនេះនៅខេត្តពោធិ៍សាត់បានបើចាំបាច់ (ល្បឿន និងទិសដៅខ្យល់ មើលក្នុងតារាង១៣ ខាងក្រោម) ។ ទិន្នន័យនេះសំរាប់ការសិក្សាធ្វើទំនប់វារីអគ្គិសនី ។ (សូមមើលទំព័រ៩២)

លើសពីនេះទៅទៀត នៅឆ្នាំ២០១១ ក្រុមសិក្សាបានទៅទំនាក់ទំនងជាមួយលោក **អ៊ុំ រិណា** អនុប្រធានកាប់រូម នៃក្រសួងធនធានទឹក និងឧតុនិយមលោកបានមានប្រសាសន៍ថា ទិសដៅល្បឿនខ្យល់ ក្នុងឆ្នាំ២០១០ និងឆ្នាំ២០១១ក្នុងតំបន់គំរោង ឬខេត្តពោធិ៍សាត់គឺគ្មានទិន្នន័យទេ ។

តារាង ១៣: ល្បឿន និងទិសដៅខ្យល់ជាមធ្យមប្រចាំខែ ក្នុងរយៈពេល១៥ឆ្នាំ (១៩៩៥_២០០៩)

Months	Jan		Feb		Mar		Apr		May		Jun		Jul		Aug		Sep		Oct		Nov		Dce	
Years	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx	dd	fx
1995	N	7	NW	7	S	8	S	7	NW	9	NW	10	W	9	NW	9	W	10	NW	6	W	7	N	6
1996	N	9	S	2.9	E	3.1	S	5	NW	8	W	8	W	10	NW	8	W	8	S	6	E	4	N	6
1997	N	5	S	3.1	N	3.5	SE	8	SE	8	W	8	W	8	W	7	W	8	NW	8	NW	8	N	8
1998	N	8	NW	2.4	S	2.3	S	8	S	5	W	8	NW	10	NW	8	W	7	S	9	N	8	NW	6
1999	NE	8	SE	2.4	SE	2.4	S	6	NW	8	W	10	W	12	W	7	W	8	NW	9	NW	8	N	6
2000	N	10	S	2.6	S	3.1	NW	4	NW	3.3	NW	6	NW	4.9	W	5	NW	12	NW	3.9	N	6	N	7
2001	N	8	SE	1.9	S	5	SE	5	NW	3.8	W	4.9	NW	5	W	5	W	2.6	NW	2.6	N	8	N	5
2002	N	8	N	2.4	SE	6	S	3	SW	6	NW	3.1	W	8	NW	4.7	NW	3.2	W	5	W	9	N	4
2003	NE	8	S	2.6	SE	5	S	3	SW	6	NW	5	W	8	NW	4	W	10	W	6	W	5	NW	5
2004	N	3.5	S	1.9	S	2.3	SE	2	SW	5	W	2.5	NW	2.3	NW	2.5	NW	2 3	NW	5	W	2.1	N	8
2005	S	5	SE	4	SE	7	NW	6	NW	5	W	6.3	W	7.3	NW	7.5	W	6.8	NW	9.2	NW	7	NW	6
2006	N	3	S	4	S	5	SE	3	S	4	SW	6	W	5	SW	6	SW	4	N	4	N	5	N	4.3
2007	NE	4.4	S	3.8	S	4	SW	4.3	W	4.2	NW	4.4	W	5.3	W	3.1	SW	3.9	NE	2.8	NW	3.1	NE	3.8
2008	N	3.2	S	4.3	S	4.5	SW	3.3	S	3.7	SW	5.9	W	4.7	SW	5.5	S	3.9	N	3.9	N	4.9	N	4.3
2009	N	4.4	S	3.8	S	5		4.3	W	4.2	NW	4.4	W	5.3	W	3.1	W	4.3	N	3.6	N	5	N	4.2
Dir	354		185		97		175		230		253		265		270		230		287		345		358	
Average	N	6.3	S	3.3	S	4.4	S	4.8	NW	5.5	W	6.2	W	7.0	NW	5.7	W	6.3	NW	5.6	N	6.0	N	5.6
Min		3		1.9		2.3		2		3.3		2.5		2.3		2.5		2.3		2.6		2.1		3.8
Max		10		7		8		8		9		10		12		9		12		9.2		9		8

ប្រភពទិន្នន័យបានពីក្រសួងធនធានទឹក និងឧតុនិយម. នាយកដ្ឋានឧតុនិយម

៤-សំណើមបរិយាកាស (Humidity) **និង កំដៅថ្ងៃ** (Sunlight)

យោងតាមប្រភពព័ត៌មានរបស់នាយកដ្ឋានឧតុនិយមនៃក្រសួងធនធានទឹក និងឧតុនិយម គ្មានការសិក្សា និងគ្មានទិន្នន័យដែលបានធ្វើក្នុងតំបន់ ឬក្នុងខេត្តពោធិ៍សាត់នោះទេ ឬខេត្តជុំវិញនោះទេ ។

៥- រំហួត

យោងតាមទិន្នន័យរបស់ក្រុមហ៊ុន Tokyo Electiroc Power Sevices Co.Ltd (Sep 2006) បានបង្ហាញថា បរិមាណរំហួតសរុបប្រចាំឆ្នាំមាន ១៤៤៥មម (មើលតារាង ១៤ខាងក្រោម):

តារាង ១៤: បរិមាណរំហួតប្រចាំឆ្នាំ (គិតជាមម)

Jan	Feb	Ma	Apr	May	Jun	Jul	Aug	Sep	Oct	Nov	Dec	Total
127	148	177	146	124	131	144	117	69	73	83	107	1,445

៥.១.១.២ គុណភាពខ្យល់ សំលេង និងរំញ័រ (Air Noise and Vibration Quality)

១- គុណភាពខ្យល់

មុនការសាងសង់ តំបន់គំរោងនេះស្ថិតនៅក្នុងតំបន់ជនបទដាច់ស្រយាលនៃស្រុកវាលវែង ហើយមានចំងាយប្រមាណ ១៦៨គ.ម ពីទីរួម ខេត្តពោធិ៍សាត់ ហើយចំងាយប្រមាណ ៨៤ គ.ម ពីទីរួមខេត្តកោះកុង ដែលជាតំបន់មានព្រៃឈើ និងដីកសិកម្ម

តិចតួច នៅក្នុងតំបន់គំរោងគ្មានតំបន់ទីប្រជុំជន ឬតំបន់ឧស្សាហកម្ម ឬពាណិជ្ជកម្មទេ។ ចំពោះផ្លូវថ្នល់មានផ្លូវលំជនបទ គ្មានស្ពានរឹងមាំទេ មាន តែស្ពានបណ្តោះអាសន្ន ហេតុដូច្នេះហើយ នៅក្នុងតំបន់គំរោងនោះ គឺគុណភាពខ្យល់មានលក្ខណៈនៅជា ធម្មជាតិ គ្មានការបំពុល ខ្យល់ទេ ហើយក៏គ្មានទិន្នន័យណាដែលបញ្ជាក់ពីការបំពុលខ្យល់នៅតំបន់នោះដែរ ។

ចំពោះការធ្វើតេស្តរកគុណភាពខ្យល់នៅក្នុងតំបន់គំរោងកំឡុងពេលសាងសង់គំរោង ក្រុមការងារ SAWAC បានសហការណ៍ជាមួយមន្ទីរពិសោធន៍ នៃក្រសួងបរិស្ថាន បានចុះទៅវាស់គុណភាពខ្យល់ និងសំលេង ២៤ ម៉. នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១១ នៅកន្លែងកិនថ្ម ដែលជាកន្លែងមានសកម្មភាពមមាញឹកជាងគេក្នុងតំបន់គំរោង បានបង្ហាញថាគុណភាពខ្យល់ស្ថិត នៅក្រោមកំរិតស្តង់ដារបស់ក្រសួងបរិស្ថាននៅឡើយ (លម្អិតមើលតារាង១៥ខាងក្រោម)

តារាង ១៥: គុណភាពខ្យល់នៅក្នុងតំបន់គំរោងកំឡុងពេលសាងសង់ (ខែកក្កដា ឆ្នាំ២០១១)

ល.រ No	ប៉ារ៉ាម៉ែត្រ Parameter	ខ្នាត Unit	លទ្ធផល Result	ស្តង់ដារ Standard	វិធីសាស្ត្រវិភាគ ឧបករណ៍ Method/Equipment
1	Carbon Monoxide (CO)	mg/m^3 N	0.66	20	Detecion Tube
2	Nitrogen Dioxide (NO2)	mg/m^3 N	0.012	0.1	Saltzman Mthod
3	Sulfur Dioxide (SO2)	mg/m^3 N	0.006	0.3	Pararosaniline Mathod
4	Total Suspended Particles (TSP)	mg/m^3 N	0.13	0.33	Low Volume Sampler Method

៧- សំលេង និងរំញ័រ

មុនការសាងសង់គំរោងដូចបានបង្ហាញនៅក្នុងចំណុចគុណភាពខ្យល់រួចមកហើយ គឺតំបន់គំរោងមិនស្ថិតនៅក្នុងតំបន់ទីប្រជុំជន ឬតំបន់ពាណិជ្ជកម្ម ឬតំបន់ឧស្សាហកម្មទេ ជាតំបន់ដាច់ស្រយាល ដូចនេះគ្មានការបំពុលណាមួយដោយសារសំលេង និងរំញ័រគួរឱ្យកត់សំគាល់ទេ ក្រៅពីសំលេង ម៉ូតូ រថយន្តតូច រទេះគោ គោយន្តតិចតួច នៅតាមផ្លូវចេញ ចូលទៅឃុំ អូរសោម នៃស្រុកវាលវែង ព្រមទាំងសំលេងសត្វព្រៃស្រែក ដូចជាសត្វទោច បក្សីចកវ៉ក ព្រាំង ជាដើម ។ល។

ក្នុងកំឡុងពេលសាងសង់គំរោងក្រុមការងារ SAWAC បានសហការណ៍ជាមួយមន្ទីរពិសោធន៍ នៃក្រសួងបរិស្ថានបានចុះទៅវាស់គុណភាពខ្យល់ និងសំលេង ២៤ម៉. នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១១ នៅកន្លែងកិនថ្ម ដែលជាកន្លែងមាន សកម្មភាពមមាញឹកជាងគេក្នុងតំបន់គំរោង។ ពេលព្រឹកចាប់ពីម៉ោង ៦:០០ ដល់រសៀលម៉ោង ១៣:០០ សំលេងជាមធ្យម ៦១.៩ dB គឺក្រោមស្តង់ដា (ស្តង់ដា ៧០ dB)។ ដូចគ្នាដែរ ចាប់ពីម៉ោង ១៤:០០ ល្ងាច ដល់ម៉ោង ១៨:០០ សំលេងជាមធ្យម ៥៨.៧dB គឺក្រោមស្តង់ដា (ស្តង់ដា ៦០ dB)។ រីឯពេលយប់វិញ បានបង្ហាញថាគុណភាពសំលេង លើសពីកំរិតស្តង់ដា របស់ក្រសួងបរិស្ថាន តិចតួច គឺពេលយប់ ចាប់ពីម៉ោង ២៣:០០ ដល់ពេលភ្លឺម៉ោង ៥:០០ សំលេងជាមធ្យមមានការលើសស្តង់ដា គឺ ៥៥.៣dB (ស្តង់ដា៥០ dB)។ (លម្អិតមើលតារាង១៦ខាងក្រោម)។

តារាង ១៦: គុណភាពសំលេង នៅក្នុងតំបន់គំរោងកំឡុងពេលសាងសង់ (ខែកក្កដា ឆ្នាំ២០១១)

Survey Period		Noise Level dB (A)				Remarks
		LAeq	Standard	Lmax	Lmin	
Day	06:00 - 07:00	63.1	70	72.4	52.6	
	07:00 - 08:00	62.8		84.6	52.1	
	08:00 - 09:00	65.4		85.9	52.0	
	09:00 - 10:00	59.3		86.8	52.3	
	10:00 - 11:00	63.6		85.4	51.8	
	11:00 - 12:00	59.1		82.4	51.6	
	12:00 - 13:00	57.4		77.4	50.8	
	13:00 - 14:00	60.7		80.3	52.6	
	14:00 - 15:00	70.2		85.5	53.7	
	15:00 - 16:00	60.7		80.9	52.0	

Survey Period		Noise Level dB (A) LAeq	Standard	Lmax	Lmin	Remarks
	16:00 - 17:00	60.5		75.1	52.5	
	17:00 - 18:00	61.5		83.8	51.9	
	18:00 - 19:00	59.8		81.1	50.9	Mean=61.9
Evening	19:00 - 20:00	60.5	65	79.2	50.5	
	20:00 - 21:00	59.6		68.4	50.6	
	21:00 - 22:00	58.4		70.1	51.7	
	22:00 - 23:00	56.4		66.5	50.4	Mean=58.7
Nignt	23:00 - 24:00	54.7	50	61.6	50.3	
	24:00 - 01:00	54.1		58.9	50.1	
	01:00 - 02:00	55.6		60.2	50.4	
	02:00 - 03:00	54.6		59.1	53.2	Generator
	03:00 - 04:00	55.9		59.4	53.1	
	04:00 - 05:00	56.1		62.4	53.5	
	05:00 - 06:00	56.2		59.8	53.4	Mean=55.3
24 hours Average		59.43		73.63	51.83	

សំគាល់: ពណ៌ក្រហម គឺជាលទ្ធផលលើសស្តង់ដារបស់ក្រសួងបរិស្ថាន ។

ចំពោះគុណរំញ័រក្នុងពេលសាងសង់គំរោងនៅក្នុងតំបន់សាងសង់វិញ គឺស្ថិតនៅក្រោមស្តង់ដារបស់ក្រសួងបរិស្ថាននៅឡើយទេ (លម្អិតមើលតារាង ១៧ខាងក្រោម) ។

តារាង ១៧: គុណភាពរំញ័រ នៅក្នុងតំបន់គំរោងកំឡុងពេលសាងសង់ (ខែកក្កដា ឆ្នាំ២០១១)

Survey Periode Day Time	Standard of Type 1	Leq (db)	Survey Peiod Nigh Time	Standard of Type 1	Leq (db)	Remark
06:00 - 07:00	Max 65 db Day Time	42.8	18:00 - 19:00	Max 50 db Night Time	43.6	
07:00 - 08:00		42.4	19:00 - 20:00		44	
08:00 - 09:00		44.0	20:00 - 21:00		42.6	
09:00 - 10:00		44.5	21:00 - 22:00		43.1	
10:00 - 11:00		43.6	22:00 - 23:00		41.6	
11:00 - 12:00		44.5	23:00 - 24:00		40.5	
12:00 - 13:00		40.3	24:00 - 01:00		40.1	
13:00 - 14:00		42.4	01:00 - 02:00		40.6	
14:00 - 15:00		43.3	02:00 - 03:00		40.8	
15:00 - 16:00		43.6	03:00 - 04:00		40.9	
16:00 - 17:00		45.1	04:00 - 05:00		41.6	
17.00 - 18:00		44.6	05:00 - 06:00		41.3	
Average		43.4	Average		41.73	

៥.១.១.៣ លក្ខណៈសណ្ឋានភាពដី ប្រភេទដី និង ភូគព្ភសាស្ត្រ នៅក្នុងតំបន់គំរោង
(Topography Soil Type and Geology in Project Area)

១- សណ្ឋានភាពដី (Topography)

លក្ខណៈភូមិសាស្ត្ររបស់តំបន់គំរោង គឺស្ថិតនៅក្នុងតំបន់ចន្លោះជួរភ្នំក្រវាញ និង ដងរែក ដែលតំបន់អាងជាជ្រលងរាង U និង V ។ នៅក្នុងតំបន់ផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងអាតៃផ្នែកនេះមានរយៈកំពស់ចាប់ពី ៣០០ម ទៅដល់ ៦០០ម ធៀបនឹងនីវ៉ូ សមុទ្រ ដែលមានភ្នំទាបៗគ្របដណ្តប់ទៅដោយព្រៃទឹកភ្លៀងនៃតំបន់ត្រូពិក (មើលផែនទីលេខ១. ២. ៣A, និង៣B) ។ ជំរាលដីជាមធ្យមក្នុងតំបន់គំរោងគឺ ប្រមាណ I=0.0128 ត្រូវជា ០.៧៣អង្សារ រីឯនៅតាមជ្រលងស្ទឹងកន្លែងខ្លះ មានជំរាលខ្ពស់រហូតដល់ ៣០អង្សា" ប្រភពទិន្នន័យបានពីក្រុមហ៊ុន China Yunnan Corporation fore Internation Techno-Economic Cooperation (CYC) " ។

ចំពោះរយៈកំពស់បាតស្ទឹងអាតៃមានរយៈកំពស់ពី ៤៦២ម-៤៣១ម (គិតចាប់ពីទំនប់ទី១ ដល់ទំនប់ទី២) ហើយបាតស្ទឹងនេះក្រាលទៅដោយសិលាប្រភេទថ្មខ្សាច់ និងថ្មភក់ (Sand and Mud Stone)។ សិលានៅក្នុងតំបន់អាងទាំងពីរ ជាប្រភេទ ថ្មខ្សាច់ ថ្មភក់ និងថ្មបាសាល ដែលកើតឡើងនៅពាក់កណ្តាលយុគ្គសម័យ Jurassic និង Cretaceous នៃ Himalayan period។ រយៈកំពស់នៅក្នុងតំបន់អាងមានចាប់ពី ៤៤០ ទៅ ៥២២ម ដែលមានចំណោទចោទទេរទៅរកស្ទឹងអាតៃបង្កើតជាជ្រលង U និង V មានមុខកាត់ប្រមាណចាប់ពី ៥០ម-៧០ម បង្កលក្ខណៈល្អក្នុងការស្តុកទឹកសំរាប់អាងទាំងពីរនេះ ។

២- ប្រភេទដី (Soil Type)

តាមផែនទីប្រភេទដីរបស់លោក Crocker **ឆ្នាំ** ១៩៦៣ មាត្រដ្ឋាន ១/១.000.000 **បានបង្ហាញ**ថា តំបន់ដីផ្ទៃអាងដែលនឹងត្រូវលិច ៤២៣៧ ហ.ត នេះមានសមាសភាពដី ២ ប្រភេទគឺ ប្រភេទដី Acid Lithosols មាន**ផ្ទៃដី** ៣៨៩៥ ហិកតា និង Red-Yellow Podzols ៣៤២ ហិកតា។

- ប្រភេទដី Acid Lithosols គឺជាដីមានប្រមោគជីជាតិល្អដែលមានល្បាយសារធាតុសរីរាង្គ (កើត**ពី**ការពុកផុយនៃ ស្លឹកឈើ ឬសឈើ ដើមឈើអាចម៍សត្វ ។ល។ ដីនេះជាដីខ្សាច់ម៉ដ្ឋលាយដីកន្តែង មានពណ៌ឈាមជ្រូកស្រាលទៅប្រផេះ មានកំរាស់ប្រមាណចាប់ពី ០,៥ ម. ទៅ ១ ម.។ រុក្ខជាតិភាគច្រើនដែលដុះលើដីនេះ គឺជារុក្ខជាតិប្រភេទព្រៃស្រោង ពាក់កណ្តាលស្រោង និងព្រៃល្បោះខ្លះៗជាអន្លើដោយកន្លែង។
- ប្រភេទដី Red-Yellow Podzols គឺជាដីមានជីជាតិមធ្យម ដែលមានលាយសារធាតុសរីរាង្គ**ដូចដី** Acid Lithosols ដែរ ប៉ុន្តែមានសារធាតុសរីរាង្គមានតិចតួចហើយមានលាយល្បាយដីឥដ្ឋភាគច្រើន។ ដីនេះមានព**ណ៌**ប្រផេះស្រាលទៅក្រម៉ៅ កន្លែងខ្លះមានពណ៌ឈាមជ្រូកស្រាលដែរ ហើយមានកំរាស់ប្រមាណចាប់ពី ០,៣ម - ០,៧ម **និង**ខាងក្រោមគឺជាស្រទាប់ដីឥដ្ឋល្បាយខ្សាច់ម៉ដ្ឋ ជួនកាលមានលាយថ្មគ្រួស (ដុំថ្មតូចទំហំ ១-៤ ស.ម) ដីនេះងាយជ្រាបទឹក។ រុក្ខជាតិភាគច្រើនដុះលើដីនេះ គឺព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះ និងកន្លែងខ្លះមានព្រៃស្រោងដុះខ្លះជាអន្លើដែរ តែតិចតួចប៉ុណ្ណោះ បើប្រៀបធៀបទៅ និងប្រភេទដី Acid Lithosols ខាងលើ។ (ក្រុមការងារបានជីកដីសិក្សាតាមប្រភេទដីជំរៅ ១ម. មើលរូបថតខាងក្រោម)

ដីប្រភេទ Acid Lithosols រូបថតថ្ងៃ ១៣/០៥/២០០៨



ដីប្រភេទ Red-Yellow Podzols រូបថតថ្ងៃ ១៣/០៥/២០០៨

៣- ភូគព្ភសាស្ត្រ (Geology)

ផ្នែកខាងលើខាងលើនៃផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងអាតៃស្ថិតផ្នែកមួយនៃជួរភ្នំដងរែកជាតំបន់ខ្ពង់រាប និងតំបន់ភ្នំដែលមានសណ្ឋាន II_2 រវាង Mawlamyine Grade IV នៃទំនាបភ្នំពេញ និង Mesozoic sag LL_2 $^{4-2}$ Grade III នៃពោធិ៍សាត់។ ចំពោះលក្ខណៈភូគព្ភសាស្ត្រគឺ Hercynian និង Indosinian។ សកម្មភាពភ្នំភ្លើងបានបង្កើតកំអែលភ្នំភ្លើង Magmatic ជាមួយនឹងការហូរគ្របដណ្តប់ទៅលើសណ្ឋានដី Variscan នៃសម័យកកើត Indosinian-Yanshanian ក្នុងយុគ្គ Neogene Period – Pleistocene (Himalayan period) បង្កើតបានជាសិលាបាសាល ថ្មភក់ និង ថ្មខ្សាច់ នៃតំបន់ទាំងនោះ ។

<u>លក្ខណៈស្រទាប់ដី និង ថ្ម</u>

ភាគច្រើនទីតាំងជំរាលភ្នំ នៃទំនប់គឺមានដីល្បាប់ ដែលកើតឡើងដោយសារលំហូរទឹកភ្លៀង (តាងដោយQ^{Pal}) ហើយកំណកដី (Q^{edl}) នៃស័កទី៤ សព្វថ្ងៃមានគំរបព្រៃដុះពីលើ ហើយមានចំណោទពី ១៥ ទៅ ៣០ អង្សាទេរទៅរកស្ទឹង។ ថ្មបាតស្ទឹងនៅទីតាំងទំនប់គឺរួមមានប្រភេទ ថ្មភក់ និងថ្មខ្សាច់ ដែលស្ថិតនៅពាក់កណ្តាលនៃសក័ហ្សូរ៉ាសិក (Jurassic)។ ផ្អែកតាមលទ្ធផលនៃការខួង ដីអង្កេតរបស់ក្រុមហ៊ុនចិន គេអាចចែកស្រទាប់ដីជាបួនស្រទាប់គឺ (ចាប់រាប់ពីក្រោមមកលើ): ស្រទាប់ទី១គឺថ្មភក់ ស្ថិតភ្ជាប់ និងថ្មល្បាប់ (J_2^1). ស្រទ្រាប់ទី២គឺថ្មខ្សាច់ល្អិត លាយជាមួយថ្មភក់ និង ថ្មល្បាប់ (J_2^2). ស្រទាប់ទី៣គឺជាថ្មភក់ជាមួយ និងថ្មខ្សាច់ល្អិតដែលស្ថិតភ្ជាប់ និងថ្មភក់ (J_2^3). ហើយនិង ស្រទាប់ទី៤ គឺស្រទាប់លើនៃបាតស្ទឹងមាន ថ្មខ្សាច់ល្អិតជាមួយថ្មភក់ និងមានលាយជាតិដីឥដ្ឋ (J_2^4)។ ស្រទាប់ថ្មភក់ដែលនឹងអាចមានស្នាមប្រេះបែកដោយសារតែត្រូវកំដៅថ្ងៃ និងខ្យល់។ ដូច្នេះ គុណភាពថ្មនេះវាខូចក្នុងរយៈពេលខ្លី ។ ស្រទាប់ថ្មបាសាលនៅក្នុងយុគ្គសម័យហិមាល័យ គឺត្រូវបានគេរកឃើញនៅតាមជំរាលភ្នំនៃទំនប់ ផ្នែកខាងស្តាំនៃទំនប់ទី១ផងដែរ។

ថ្មខ្សាច់ល្អិតស្ថិតភ្ជាប់នឹងថ្មភក់នៃស្រទាប់ទី៤ (J_2^4). និងស្រទាប់ទី២ (J_2^2). នេះគឺជាប្រភេទថ្មដែលពិបាកនឹងទទួលរងសំណឹកដែលត្រូវបានចាត់ថ្នាក់ចូលជាប្រភេទ A_{III2} ហើយថ្មដែលរងសំណឹកជាមធ្យម គឺត្រូវបានចាត់ចូលក្នុងប្រភេទ B_{III2} និងចំណែកឯថ្មខ្សាច់ល្អិត និងថ្មភក់លាយដីឥដ្ឋនៃស្រទាប់ទី៣ និង ទី១ដែលងាយរងសំណឹកគឺត្រូវបានគេចាត់ចូលជាប្រភេទ C_{IV2} ។

លក្ខណៈវារីភូគព្ភសាស្ត្រ

ស្រទាប់ថ្មនៅទីតាំងទំនប់មានលក្ខណៈពិសេស uniclinal structure និង រយៈកំពស់ ៣០° ~ ៥០° / SE< ៣° ~ ១២ មាត្រដ្ឋានសំរុតជាមធ្យមគឺមាន F_1, F_2 និង F_3 ។ នៅលើស្រទាប់ថ្មទាំងនេះមានស្នាមប្រេះ ដែលចែកចេញជាបីផ្នែកគឺៈ ស្នាមប្រេះគងលើគ្នា (កាត់គ្នា) ស្នាមប្រេះទៅរកទិសឦសាន (Northeast structural fissure) និងស្រទាប់ស្នាមប្រេះ បែរទៅទិសពាយ័ព្យ (Northwest structural fissure)។ ស្នាមប្រេះទាំងនេះគឺលទ្ធផលនៃបំណាក់ស្រុត ដោយសារការសង្កត់នៅផ្នែក នៅសងខាងទំរង់នៃថ្មភក់ដែលផុយជាងគេ ។

ផ្នែកខាងលើនៃថ្មបាតនៅច្រាំងទំនប់ខាងស្តាំ គឺត្រូវបានចាត់ទុកជាទំរង់ប្រភេទថ្មបាសាល់ ដែលស្ថិតនៅក្នុងយុគ្គនៃ Himalayan (ß) និងផ្នែកខាងក្រោមនៃបាតស្ទឹងត្រូវបានរកឃើញថា ជាទំរង់ថ្មខ្សាច់ និងថ្មភក់កើតនៅពាក់កណ្តាលយុគ្គ យូរ៉ាស៊ិក (J_2) ។ នៅលើថ្មបាសាល់ត្រូវបានគេរកឃើញ មាននៅតាមជំរាលភ្នំ មានការសឹកខិចរីលនៅផ្នែកខាងលើ និងចន្លោះស្រទាប់កណ្តាល មានសារធាតុដីឥដ្ឋ ដោយសារតែលំហូរទឹកក្រោមដី។ ជាទូទៅផ្ទៃខាងលើទេរទៅរកទិសពាយ័ព្យ និងមានការប្រែប្រួលខ្លះ ហើយមានមុំជម្រៅប្រហែល៩° ។ ស្នាមប្រេះទាំងនេះ គឺមានទឹកក្រោមដីហូរឆ្លងកាត់ ដែលបានពីទឹកភ្លៀងធ្លាក់ចូលទៅផ្ទៃរង ទឹកភ្លៀងនៃស្ទឹងអាតៃ។ ដូចបានរៀបរាប់ក្នុងចំណុច ៥.១.១.៤ ខាងលើស្រទាប់ទឹកក្រោមដីនៅក្នុងតំបន់គំរោងមាន ២ស្រទាប់ ដែលស្រទាប់លើជាស្រទាប់ទឹកក្រោមដីមិនខ្ចប់ហូរចាក់ចូលទៅក្នុងស្ទឹងអាតៃ ហើយតាមរយៈស្នាមប្រេះនៃសិលាបាតស្ទឹងទឹក នេះជ្រាបទៅតំបន់ខាងក្រោមបង្កើតបានជាស្រទាប់ទឹកក្រោមដីខ្ចប់ដែលមានសម្ពាធ ។



ប្រភេទសិលានៅបាតស្ទឹងអាតៃខាងលើទីតាំងទំនប់ទី១ នៃតំបន់គំរោងវារីអគ្គិសនីស្ទឹងអាតៃ។

៩- ប្រព័ន្ធធារាសាស្ត្រ (Irrigation system)

នៅក្នុងតំបន់ផ្ទៃអាងដែលនឹងត្រូវលិចនេះ យោងតាមការសិក្សារបស់ក្រុមការងារ SAWAC មាន តែអាងទី១ប៉ុណ្ណោះ ដែលមានដីស្រែចំការ(ដីកសិកម្ម) ដីលំនៅដ្ឋាន និងដីកប់ខ្មោច របស់ប្រជាជនរស់នៅ បីភូមិ ក្នុងឃុំអូរសោម ហើយដីកសិកម្មទាំងនោះពុំមានប្រព័ន្ធស្រោចស្រពទេ។ សព្វថ្ងៃនេះប្រជាកសិករក្នុងតំបន់ពឹងផ្អែក លើទឹកភ្លៀងទាំងស្រុង (របាយការណ៍ពីលោក **កែវ វៃ** ប្រធានមន្ទីរធនធានទឹក និង ឧតុនិយម ខេត្តពោធិ៍សាត់) ។

យោងតាមរបាយការណ៍របស់លោកប្រធានមន្ទីរ តំបន់គំរោងនេះពុំមានផែនការដើម្បីសាងសង់ប្រព័ន្ធស្រោចស្រពដល់ដីស្រែចំការរបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោងនោះទេ ដូច្នេះគ្មានប៉ះពាល់ដល់វិស័យប្រព័ន្ធស្រោចស្រពរបស់មន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក៏ដូចជាក្រសួងនោះទេ ។



ប្រភេទសិលានៅបាតស្ទឹងអាតៃដែលខួងសិក្សាដោយក្រុមហ៊ុន ចិន ។

៥.១.១.៤ ជលសាស្ត្រ (Hydrology)

១- ប្រព័ន្ធអូរទន្លេ និងប្រព័ន្ធបោះទឹកក្នុងតំបន់គំរោង (River System and Drainage Pattern in the Project Area)

យោងតាមផែនទីគំរបព្រៃឈើរបស់រដ្ឋបាលព្រៃឈើ ដែលឧបត្ថម្ភដោយ JICA ឆ្នាំ ២០០២ និងការចុះអង្កេតផ្ទាល់ដល់ទីតាំងគំរោង លើផ្ទៃដីប្រមាណជាង ៨.០០០ ហិកតា មានប្រព័ន្ធដោះទឹកជាលក្ខណៈធម្មជាតិដូចតទៅ :

- ស្ទឹងអាតៃស្ថិតនៅក្នុងផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងឫស្សីជ្រុំ ហើយអាងរងទឹកភ្លៀងរបស់ស្ទឹងអាតៃគិតត្រឹមទំនប់ទី១ (Primary Dam) គឺប្រមាណ ៥៦៧Km^2 និងរបស់ស្ទឹងអាតៃ គិតត្រឹមទំនប់ទី២ (Secondary Dam) គឺប្រមាណ ៥៩០Km^2 (ប្រភពទិន្នន័យ C.H.D (Cambodia) Hydropower Development Co., Ltd.) ។
- ទឹកភ្លៀងត្រូវបានហូរចុះតាមប្រឡាយធម្មជាតិជាច្រើនរួចហូរចុះទៅអូរធម្មជាតិសំខាន់ៗ អូរទាំងនោះហូរចូលទៅដូចជា ស្ទឹង ហើយស្ទឹងទាំងនោះហូរចូលទៅព្រែក រួចហូរចូលទៅសមុទ្រ។ ចំពោះអូរនៅខាងឆ្វេងនៃស្ទឹងអាតៃ (គិតរាប់ពីផ្ទៃអាងទីមួយខាងលើដល់ទំនប់ទី២) មាន: អូរថ្មច្រឡុះ អូរក្តួច អូរវល្លិ៍ពេន អូរក្រញូង អូររំលោះ អូរពាពូត ហើយនិងនៅខាងស្តាំនៃស្ទឹងអាតៃមាន អូរក្របីងាប់ ស្ទឹងតាកង ស្ទឹងភ្លុក ស្ទឹងឆាយលូក។ (សូម បញ្ជាក់ថាមានអូរមួយចំនួនមិនមានឈ្មោះទេ ក្រុមការងារ SAWAC បានសុើបសួរអ្នកស្រុក និងរដ្ឋអំណាចមូលដ្ឋានក៏ពុកគាត់មិនដឹងផង) (មើលផែនទីលេខ២) ។ ស្ទឹង-អូរទាំងនោះហូរចូលស្ទឹងអាតៃ រួចស្ទឹងនេះហូរចូលស្ទឹង ឫស្សីជ្រុំរួចហូរទៅស្ទឹងកោះប៉ោ ទៅព្រែកកោះប៉ោ កាត់តាមទីរួមខេត្តកោះកុង ចុងបញ្ចប់ហូរចូលសមុទ្រ ។
- យោងតាមទិន្នន័យសិក្សាដោយក្រុមហ៊ុន C.H.D (Cambodia) Hydropower Development Co., Ltd.ទៅលើផ្នែកជលសាស្ត្ររបស់ស្ទឹងអាតៃត្រង់ទំនប់ទី១ Primary Dam បានបង្ហាញដូចតទៅ (ទិន្នន័យនេះយកទៅគណនាធ្វើហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនី) :

• ធារទឹកជាមធ្យមប្រចាំឆ្នាំ	41 m^3/s
• ការគណនាធារទឹកជំនន់អតិបរមាសំរាប់ទំនប់ទី១សំរាប់រយៈពេលខួប១០០០ឆ្នាំ	2,811 m^3/s
• ការគណនាធារទឹកជំនន់អតិបរមាសំរាប់ទំនប់ទី២ សំរាប់រយៈពេលខួប១០០០ឆ្នាំ	3,810 m^3/s
• ការគណនាស្តង់ដាទឹកជំនន់ និងធារទឹកសំរាប់ទំនប់ (P=0.2%) Dam Site Design Flood Standard and Flow (P=0.2%)	3,350 m^3/s
• ការគណនាស្តង់ដាទឹកជំនន់ និងធារទឹកសំរាប់រោងចក្រ (P=1%)	2,520 m^3/s

Plant Building Design Flood Standard and Flow (P=1%)

- សីតុណ្ហភាពជាមធ្យមប្រចាំឆ្នាំ 27.9 °C
- សីតុណ្ហភាពអតិបរមាប្រចាំឆ្នាំ 31.9 °C
- សីតុណ្ហភាពអប្បបរមាប្រចាំឆ្នាំ 23.9 °C
- សំណើមជាមធ្យមប្រចាំឆ្នាំ 78 %
- ល្បឿនខ្យល់អតិបរមា 20 m/s
- កំពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ 4,032 mm
- រំហួតជាមធ្យមប្រចាំឆ្នាំ 1,440 mm
- ល្បាប់ដែលវិលវល់ក្នុងទឹកជាមធ្យមប្រចាំឆ្នាំ 0.190 kg/m^3
- ការហូរនាំល្បាប់ជាមធ្យមប្រចាំឆ្នាំ 21,234 t
- កំណកខ្សាច់នៅបាតស្ទឹងជាមធ្យមប្រចាំឆ្នាំ 3,534 t
- មូលដ្ឋានស្នាមប្រេះកើតឡើងពីការរញ្ជួយដី Basic Earthquake Fissure <6°

- *លក្ខណៈជលសាស្ត្ររបស់ស្ទឹងអាតៃ*

យោងតាមលទ្ធផលនៃការគណនាលំហូរប្រចាំឆ្នាំ (Annaul Runoff), ការប៉ាន់ស្មានទឹកជំនន់ និងជំនន់អតិបរមាប្រចាំថ្ងៃ បង្ហាញនៅក្នុងតារាង១៨ខាងក្រោម

តារាង១៨ : លទ្ធផលនៃការគណនាលំហូរប្រចាំឆ្នាំនៃគំរោងវារីអគ្គិសនីស្ទឹងអាតៃ

Site	Average value m^3/s	Cv	Cs/Cv	Each frequency design annual runoff (m^3/s)						
				5%	10%	20%	50%	80%	90%	95%
Dam site of First-stage Plant	31.9	0.15	2	40.2	38.2	35.9	31.7	27.8	25.9	24.5
Dam site of Second-stage Plat	33.2	0.15	2	41.8	39.7	37.3	33.0	29.0	27.0	25.5

ប្រភពទិន្នន័យបានពី China Yunnan Corporation for International Techno-Economic Cooperation (CYC).

តារាង១៩ : លទ្ធផលនៃការគណនាការប៉ាន់ស្មានទឹកជំនន់នៃគំរោងវារីអគ្គិសនីស្ទឹងអាតៃ

Site	Catchments area (km^2)	frequency (%) & peak flow of design flood (m^3/s)								
		0.05	0.1	0.2	0.5	1	2	5	10	20
Dam site of First-stage Plant and powerhouse	567	4,080	3,710	3,350	2,880	2,520	2,170	1,710	1,360	1,030
Dam site of Second-stage Plant	590	4,180	3,810	3,440	2,950	2,580	2,220	1,750	1,400	1,060
Powerhouse of Second-stage Plant	661	4,500	4,100	3,700	3,180	2,790	2,390	1,880	1,510	1,140

ប្រភពទិន្នន័យបានពី China Yunnan Corporation for International Techno-Economic Cooperation (CYC)

តារាង២០ : ការប៉ាន់ស្មានបរិមាណទឹកជំនន់អតិបរមាប្រចាំថ្ងៃនៃគំរោងវារីអគ្គិសនីស្ទឹងអាតៃ

Frequency (%)	0.05	0.2
Daily maximum flood volume designed (thousand m^3)	299,000	244,000

ប្រភពទិន្នន័យបានពី China Yunnan Corporation for International Techno-Economic Cooperation (CYC)

ក្រៅពីលទ្ធផលនៃការគណនាខាងលើ ក្រុមហ៊ុនបានធ្វើការសិក្សាធារទឹកនៅកំណាត់ស្ទឹងអាតៃចំនួន ៣ កន្លែង ដូចមាននៅក្នុងតារាង២១ខាងក្រោម:

តារាង២១ : បរិមាណធារទឹកគណនាតាមមុខកាត់ស្ទឹងអាតៃ ៣ កន្លែង គិតជា ម^{៣}/វិនាទី

Cross section of dam site at First-stage Plant		Cross section of dam site at Second-stage Plant		Cross section of power house at Second-stage Plant	
Water level (m)	Discharge (m^3/s)	Water level (m)	Discharge (m^3/s)	Water level (m)	Discharge (m^3/s)
476.60	10.3	443.50	11.8	278.50	10.9
477.00	25.3	444.00	36.0	280.00	84.4
477.50	56.5	444.50	71.3	280.50	131
478.00	102	445.00	117	281.00	187
478.50	158	445.50	164	281.50	250
479.50	301	446.00	230	282.00	322
480.00	387	447.00	409	282.50	402
481.00	585	448.00	695	283.00	490
482.00	822	449.00	1040	284.00	690
483.00	1100	450.00	1450	285.00	923
484.00	1420	451.00	1930	286.00	1190
485.00	1790	452.00	2450	287.00	1490
487.00	2610	453.00	3040	288.00	1830
488.00	3050	454.00	3680	290.00	2610
490.00	4250	455.00	4370	292.00	3560

ប្រភពទិន្នន័យបានពី China Yunnan Corporation for International Techno-Economic Cooperation (CYC)







តារាង ២២ : បរិមាណធារទឹកមធ្យម និងអប្បបរមា នៅទំនប់ទី២ (សិក្សានៅខែកក្កដា ឆ្នាំ២០០៧ ~ ខែវិច្ឆិកា ឆ្នាំ២០០៨ : m^3/s)

Monthly	Daily Average (m^3/s)	Minimum (m^3/s)
July	65.8	26.9
August	32.3	17.8
September	32.6	18.7
October	48.5	22.1

November	17.1	7.04
December	3.41	1.5
January	1.06	0.83
February	0.89	0.52
March	0.50	0.38
April	2.46	0.83
May	7.19	2.86
June	21.3	1.53
July	5	3.17
August	13.1	2.67
September	28.3	17.2
October	29.3	17.8

សំគាល់ : - Dryseason (Nov- May) :Average= 4.46 m^3/s & Min = 0.38 m^3/s, Average Min (Nov-May)= 1.99m^3/s

- Rainseason (July-October) in 2007: Average = 44.8m^3/s , In 2008 : Average = 19.94 m^3/s
- ប្រភពទិន្នន័យខាងលើបានពី C.H.D (Cambodia) Hydropower Development Co., Ltd.

តារាង២៣ : បរិមាណធារទឹកមធ្យម និងអប្បបរមា ចន្លោះពីទំនប់ទី២ មកអគារថាមពលទី២ (សិក្សានៅខែកក្កដា ឆ្នាំ២០០៧ ~ ខែវិច្ឆិកា ឆ្នាំ២០០៨ : m^3/s)

Monthly	Daily Average (m^3/s)	Minimum (m^3/s)
July	7.95	3.25
August	3.90	2.15
September	3.94	2.26
October	5.86	2.67
November	2.07	0.85
December	0.41	0.16
January	0.13	0.10
February	0.11	0.06
March	0.06	0.05
April	0.30	0.10
May	0.87	0.35
June	2.58	0.19
July	0.60	0.38
August	1.59	0.32
September	3.42	2.08
October	3.54	2.15
Dryseason (Nov-April)	Averag =0.51 m^3/s	Min = 0.05 m^3/s
Discharge ecological flow at phase 2 powerhouse is 10% of the average flow during dry season, namely 1.36 m^3/s		

សំគាល់:- Rainseason (July-September) in 2007: Average = 5.41m^3/s , In 2008 : Average = 2.29 m^3/s

- ប្រភពទិន្នន័យខាងលើបានពី CHD (Cambodia) Hydropower Development Co., Ltd.

យោងតាមទិន្នន័យរបស់ក្រុមហ៊ុន CHD ដែលកត់ត្រាខួបរយៈពេល ៥ឆ្នាំ ពីឆ្នាំ ២០០៥ ដល់ ២០១០ នៅទីតាំងទំនប់ទី២ បានឱ្យដឹងថាធារទឹកអតិបរិមា ហើយច្រើនកើតមានជាងគេក្នុងមួយឆ្នាំ គឺនៅរដូវវស្សាខែ សីហា ៦០.៩ m^3/s កញ្ញា ៤១.២ m^3/s និង តុលា ៤៩.៤ m^3/s ។ ចំណែកឯនៅរដូវប្រាំងធារទឹកដែលតិចជាងគេច្រើនកើតឡើងនៅចន្លោះខែ មករា ១.២៨ m^3/s កុម្ភៈ ១.១ m^3/s និង មិនា ១.២៥ m^3/s (មើលតារាង ២៤ខាងក្រោម)

តារាង ២៤ : បរិមាណធារទឹកមធ្យមប្រចាំខែនៃស្ទឹងអាតៃនៅទីតាំងទំនប់ទី២ (ឆ្នាំ២០០៥~២០១០)

Year	Jan	Feb	Mar	Apr	May	Jun	Jul	Aug	Sep	Oct	Nor	Dec	Yearly Mean
2005	1.31	1.2	1.65	6.64	18.9	14.1	12.9	51.2	35.8	49.4	10.1	3.8	17.25
2006	1.28	1.4	1.57	5.94	17.4	13.5	12.4	53.2	38.8	47.6	9.1	3.69	17.16
2007	1.34	1.1	1.59	5.64	17.1	13.6	12.1	59.1	41.2	45.6	7.1	3.1	17.38
2008	1.8	1.4	1.25	6.21	16.1	16.4	11.2	60.9	36.8	45.9	9.2	4.2	17.61
2009	1.39	1.21	1.35	5.41	17.4	15.9	15.9	56.9	34.8	44.4	10.9	4.3	17.49

2010	1.29	1.1	1.55	5.64	17.9	13.9	12.4	53.2	36.8	47.4	9.07	3.1	16.95
Average	1.4	1.2	1.5	5.9	17.5	14.6	12.8	55.8	37.4	46.7	9.2	3.7	17.31
Min	1.28	1.1	1.25	5.41	16.1	13.5	11.2	51.2	34.8	44.4	7.1	3.1	1.1
Max	1.8	1.4	1.65	6.64	18.9	16.4	15.9	60.9	41.2	49.4	10.9	4.3	60.9

២- ការវិភាគគុណភាពទឹកលើដី (Surface Water Quality Analysis)

ការវិភាគគុណភាពទឹកលើដីនៅក្នុងតំបន់គំរោង ត្រូវបានក្រុមសិក្សារបស់ SAWAC ជ្រើសរើសបីចំណុច គឺនៅខាងលើទំនប់ទី១ នៅលើទំនប់ទី២ នៅខាងក្រោមទីតាំងអគារថាមពលទី២ ។

ទីតាំងយកសំណាកទឹកមានបង្ហាញដូចខាងក្រោមនេះ-:

- ចំណុចទី ១ គឺនៅក្នុងអាងទី១ ខាងលើទំនប់ទី១ ដែលមានកូអរដោនេ X= 301536 និង Y= 1329110 (សំណាកទី១) ។ **សំគាល់:** នៅរដូវប្រាំងក្រុមហ៊ុនបានធ្វើការវិភាគទឹក នៅក្នុងអាងទី១ នៅថ្ងៃទី៥ ខែ ឧសភា ឆ្នាំ២០១១ ផងដែរ ទិន្នន័យនេះក៏យកមកវិភាគរួមគ្នាផងដែរ ។
- ចំណុចទី ២ នៅក្នុងអាងទី២ ក្រោមទំនប់ទី២ ដែលមានកូអរដោនេ X= 300683 និង Y= 1328766 (សំណាកទី២) ។ **សំគាល់:** នៅរដូវប្រាំងក្រុមហ៊ុនបានធ្វើការវិភាគទឹក នៅក្នុងអាងទី២ នៅថ្ងៃទី៥ ខែ ឧសភា ឆ្នាំ២០១១ ផងដែរ ទិន្នន័យនេះក៏យកមកវិភាគរួមគ្នាផងដែរ ។
- ចំណុចទី ៣ នៅខាងក្រោមអគារថាមពលទី២ ដែលមានកូអរដោនេ X= 294735 និង Y= 1321876 (សំណាកទី៣) ។ **សំគាល់:** នៅរដូវប្រាំងក្រុមហ៊ុនបានធ្វើការវិភាគទឹក នៅខាងក្រោមអគារថាមពលទី២ នៅថ្ងៃ ទី៥ ខែ ឧសភា ឆ្នាំ២០១១ ផងដែរ ទិន្នន័យនេះក៏យកមកវិភាគរួមគ្នាផងដែរ ។ (សូមមើលផែនទីទី២)

(សូមមើលផែនទី ៣ & ៥ : ទីតាំងយកសំណាកទឹក និងការសិក្សារាប់ព្រៃឈើឧបសម្ព័ន្ធ ៣) ។

សំណាកទឹកនៃខ្សែទឹកខាងលើត្រូវបានយក និងធ្វើការវិភាគក្នុងអំឡុងពេលសិក្សាវាយតំលៃបរិស្ថាន ខែឧសភា ២០០៨ នេះ និងរៀងរាល់ ២ខែម្តង ឆ្នាំ២០១១ ហើយលទ្ធផលគុណភាពទឹកមានបង្ហាញជូនក្នុងតារាង២៥ ។

តារាង២៥ : លទ្ធផលការពិសោធន៍គុណភាពទឹកលើដី នៃចំណុចទី១ (សំណាកទី១)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវសាស្ត្រចំរុះ MoE	ស្តង់ដាគុណភាពទឹកផឹក MIME	លេខសំណាក ១			
					១៣ ឧសភា ២០០៨ (មុនពេលសាងសង់)	០៥ ឧសភា ២០១១ (កំពុងសាងសង់)	២៣ កក្កដា ២០១១ (កំពុងសាងសង់)	២២ កញ្ញា ២០១១ (កំពុងសាងសង់)
					ក្នុងអាងទី១ខាងលើទំនប់ទី១	ក្នុងអាងទី ១ខាងលើទំនប់ទី១	ក្នុងអាងទី១ខាងលើទំនប់ទី១	ក្នុងអាងទី១ខាងលើទំនប់ទី១
1	Manganese (Mn)	mg/l	-	0.1	0	0.00	[illegible]	0.1
2	Fluoide (F)	mg/l	-	1.5	-	-	-	
3	Iron (Fe)	mg/l	-	0.3	0.12	0.30	1.5	1.5
4	Asemic (As)	mg/l	-	0.05	-	0.00	0	0
5	Dissolved Oxygen (DO)	mg/l	2 - 7.5	-	7.29	3.00	6.02	6.23
6	BODs	mg/l	10-Jan	-	8.21	-	0.8	0.40
7	COD	mg/l	< 1 - 8	-	11.64	1.00	4.7	2.05
8	Total Coliform	MPN/100ml	< 1000	0	[illegible]	250	7500	11000
9	Nitrite-N(NO_2-N)	mg/l		-	-	0.002	0.003	0.008
10	True Nitrate-N(T-N)	mg/l		-	-	5.492	2.797	0.392
11	Nitrate-N(NO_3-N)	mg/l		-	-	1.25	2.8	0.4
12	Nitrate (NO_3)	mg/l		≤ 50	-	5.50	12.32	1.76
13	Nitrate (NO_2)	mg/l		≤ 2	-	0.008	0.0099	0.0264
14	pH	No Unit	6.5 - 8.5	6.5 - 8.5	7.7	6.50	6.4	5.4
15	Temperature (t°c)	°c	-	-	26.1	25.40	25.6	23.3
16	Conductivity	µS/Cm	-	1500	13	11.00	14.6	10.8

17	TDS	mg/l		800	7	5.50	7.3	5.4
18	Turbidliy	NTU		5	[illegible]	[illegible]	[illegible]	[illegible]
19	Total Nitrogen (TN)	mg/l	0.1 - 0.6	-	0.41	0.40	-	
20	Total Phoshorus (TP)	mg/l	0.005 - 0.05	-	0.014	0.01	0.02	0.01

- MoE : ក្រសួងបរិស្ថាន (កំរិតស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈ សំរាប់អភិរក្សជីវសាស្ត្រចំរុះ ចំពោះទន្លេ និង អាងស្តុកទឹក)
- MIME : ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ចំណាំ:

- **លេខពណ៌ក្រហម** តំណាងលើសកំរិតស្តង់ដាគុណភាពទឹក របស់ក្រសួងបរិស្ថាន។
- លេខពណ៌ទឹកក្រូច តំណាងលើសកំរិតស្តង់ដាគុណភាពទឹក របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- **លេខពណ៌ផ្កាឈូក** តំណាងលើសកំរិតស្តង់ដាគុណភាពទឹក របស់ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

<u>តារាង ២៦</u>: លទ្ធផលការពិសោធន៍គុណភាពទឹកលើដី នៃចំណុចទី២ (សំណាកទី២)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវសាស្ត្រចំរុះ MoE	ស្តង់ដាគុណភាពទឹកផឹក MIME	លេខសំណាក ២			
					១៣ ឧសភា ២០០៨ (មុនពេលសាងសង់)	០៥ ឧសភា ២០១១ (កំពុងសាងសង់)	២៣ កក្កដា ២០១១ (កំពុងសាងសង់)	២២ កញ្ញា ២០១១ (កំពុងសាងសង់)
					ក្នុងអាងទី២ខាងលើទំនប់ទី២	ក្នុងអាងទី២ខាងលើទំនប់ទី២	ក្នុងអាងទី២ខាងលើទំនប់ទី២	ក្នុងអាងទី២ខាងលើទំនប់ទី២
1	Manganese (Mn)	mg/l	-	0.1	0	0.00	0.1	0.1
2	Fluoide (F)	mg/l	-	1.5	-		-	
3	Iron (Fe)	mg/l	-	0.3	13	0.20	0.59	0.39
4	Asemic (As)	mg/l	-	0.05	-	0.00	0	0
5	Dissolved Oxygen (DO)	mg/l	2 - 7.5	-	7.31	5.00	5.41	5.11
6	BODs	mg/l	10-1	-	8.09	-	1.1	3.05
7	COD	mg/l	< 1 - 8	-	7.76	2.00	4.96	5.17
8	Total Coliform	MPN/100ml	< 1000	0	936	420	46000	46000
9	Nitrite-N(NO_2-N)	mg/l		-	-	0.212	0.265	0.116
10	True Nitrate-N(T-N)	mg/l		-	-	5.300	2.535	2.984
11	Nitrate-N(NO_3 N)	mg/l		-	-	1.36	2.8	3.1
12	Nitrate (NO_3)	mg/l	-	≤ 50	-	6.00	12.32	13.64
13	Nitrate (NO_2)	mg/l	-	≤ 2	-	0.70	0.8745	0.3828
14	pH	No Unit	6.5 - 8.5	6.5 - 8.5	7.6	6.60	6.7	5.9
15	Temperature (°c)	°c	-	-	25.6	24.80	25	23.7
16	Conductivity	µS/Cm	-	1500	14	12.20	14.5	12.71
17	TDS	mg/l	-	800	7	6.10	7.25	6.355
18	Turbidliy	NTU	-	5	[illegible]	[illegible]	[illegible]	[illegible]
19	Total Nitrogen (TN)	mg/l	0.1 - 0.6	-	0.45	0.30	-	
20	Total Phoshorus (TP)	mg/l	0.005 - 0.05	-	0.009	0.02	0.03	0.03

<u>តារាង ២៧</u>: លទ្ធផលការពិសោធន៍គុណភាពទឹកលើដី នៃចំណុចទី៣ (សំណាកទី៣)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវសាស្ត្រចំរុះ MoE	ស្តង់ដាគុណភាពទឹកផឹក MIME	លេខសំណាក ៣			
					១៣ ឧសភា ២០០៨ (មុនពេលសាងសង់)	០៥ ឧសភា ២០១១ (កំពុងសាងសង់)	២៣ កក្កដា ២០១១ (កំពុងសាងសង់)	២២ កញ្ញា ២០១១ (កំពុងសាងសង់)
					ក្រោមអគារថាមពលទី២	ក្រោមអគារថាមពលទី២	ក្រោមអគារថាមពលទី២	ក្រោមអគារថាមពលទី២
1	Manganese (Mn)	mg/l	-	0.1	0	0.00	0.2	0.3
2	Fluoide (F)	mg/l		1.5	-		-	
3	Iron (Fe)	mg/l		0.3	0.15	0.30	0.13	0.31
4	Asemic (As)	mg/l		0.05		0.00	0	0
5	Dissolved Oxygen (DO)	mg/l	[illegible] - 7.5	-	7.35	6.00	6.8	5.42
6	BODs	mg/l	10-Jan	-	5.17	-	0.65	1.30
7	COD	mg/l	< 1 - 8	-	15.52	1.00	3.14	3.75
8	Total Coliform	MPN/100ml	< 1000	0	[illegible]	1020	46000	46000

9	Nitrite-N(NO_2-N)	mg/l		-	-	0.012	0.066	0.010
10	True Nitrate-N(T-N)	mg/l		-	-	4.960	6.934	2.49
11	Nitrate-N(NO_3-N)	mg/l	-	-	-	1.14	7	2.5
12	Nitrate (NO_3)	mg/l	-	≤ 50	- -	5.00	30.8	11
13	Nitrate (NO_2)	mg/l	-	≤ 2	-	0.04	0.2178	0.033
14	pH	No Unit	6.5 - 8.5	6.5 - 8.5	7.5	7.1	6.9	6.9
15	Temperature (t°c)	°c	-	-	26.9	23.50	23.9	24.1
16	Conductivity	µS/Cm	-	1500	16	11.40	14.1	11.2
17	TDS	mg/l	-	800	8	5.70	7.05	5.6
18	Turbidliy	NTU	-	5	26	29.00	30	32
19	Total Nitrogen (TN)	mg/l	0.1 - 0.6	-	0.42	0.35	-	-
20	Total Phoshorus (TP)	mg/l	0.005 - 0.05	-	0.016	0.02	0.02	0.03

៣- ការវិភាគគុណភាពទឹកក្រោមដី (Ground Water Quality Analysis)

ដូចគ្នានិង ការវិភាគគុណភាពទឹកលើដីដែរនៅក្នុងតំបន់គំរោង ត្រូវបានក្រុមសិក្សារបស់ SAWAC ជ្រើសរើសពីរចំណុច គឺនៅក្នុងអណ្តូងខួងសិក្សារបស់ចិន តែនៅពេលដែលសិក្សាអណ្តូងនេះបានលប់ក្នុងការសាងសង់ទំនប់អស់ទៅហើយ ដូចនេះក្រុមការងារសំរេចយកអណ្តូងជីកដៃមិនមានខ្ទោះ របស់ប្រជាជន ឃុំអូរសោម និងអណ្តូងខួងប្រើប្រាស់ ក្នុងទីតាំងការិយាល័យរបស់ក្រុមហ៊ុនចិន នៅទំនប់ទី២ មកធ្វើការវិភាគ ហើយទីតាំងយកសំណាកទឹកមានបង្ហាញដូចខាងក្រោមនេះ

- ចំណុចទី ១ គឺនៅអណ្តូងជីកដៃមិនមានខ្ទោះ ភូមិអូរសោម ដែលមានកូអរដោនេ X= 306675 និង Y= 1335373 (សំណាកទី៤) ។
- ចំណុចទី ២ គឺនៅអណ្តូងខួងទឹកប្រើប្រាស់នៅការិយាល័យក្រុមហ៊ុន ទំនប់ទី២ ដែលមានកូអរដោនេ X= 298665 និងY=1325063(សំណាកទី៥) ។ **សំគាល់:** នៅរដូវប្រាំងក្រុមហ៊ុនបានធ្វើការវិភាគទឹកផងដែរទិន្នន័យនេះក៏យកមកវិភាគរួមគ្នាដែរ ។ (សូមមើលផែនទីទី១.៤: ទីតាំងយកសំណាកទឹក និងការសិក្សារាប់ព្រៃឈើឧបសម្ព័ន្ធ ៣) ។

ក្រុមការងារ SAWAC ក៏បានសិក្សាបរិមាណទឹកក្រោមដីផងដែរ ។ វីធិសាស្ត្រមានចែងក្នុងជំពូក ២ខាងលើ ហើយលទ្ធផលយកមកធ្វើការវិភាគ ដូចខាងក្រោម:

- ស្រទាប់ទឹកក្រោមដីមិនខ្ទប់ (Unconfined Aquifer) ស្រទាប់នេះគឺមានជំរៅរាក់ បើប្រៀបធៀបទៅនឹងនីវ៉ូផ្ទៃដីខាងលើមានជំរៅចាប់ពី ០.៥ ម ទៅ ៥ ម (តាមនីវ៉ូដី) ហើយមានទិសដៅហូរចុះទៅស្ទឹងអាតៃ។ ស្រទាប់នេះមានចារទឹកតិចប្រមាណពី ១២០ ទៅ ៣០០០ ល/ម៉។ ចំពោះបរិមាណទឹកនៅរដូវប្រាំងមានការថយចុះខ្លាំងរហូតមានអណ្តូងខ្លះរីងគ្មានទឹកទៀតផង ។
- ស្រទាប់ទឹកក្រោមដីខ្ទប់ (Confined Aquifer) ជាស្រទាប់ទឹកក្រោមដីដែលមានជំរៅចាប់ពី ១៥ ម ទៅ ៣៥ ម ហើយមានសម្ពាធទឹកដែលមាននីវ៉ូស្តាទិកគិតពីផ្ទៃដីខាងលើប្រមាណ ៨ ម ទៅ ១៥ ម ។ ស្រទាប់ទឹកក្រោមដីនេះមានបរិមាណចារទឹកប្រមាណពី ១ ទៅ ៨ ម^{៣}/ម៉ ។

តារាង ២៨: លទ្ធផលការពិសោធន៍គុណភាពទឹកក្រោមដីចំណុចទី១ (សំណាកទី៤)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវសាស្ត្រចុះ MoE	ស្តង់ដាគុណភាពទឹកផឹក MIME	លេខសំណាក ៤		
					១៣ ឧសភា ២០០៨ (មុនពេលសាងសង់)	២៣ កក្កដា ២០១១ (កំពុងសាងសង់)	២២ កញ្ញា ២០១១ (កំពុងសាងសង់)
					អណ្តូងជីកដៃ	អណ្តូងជីកដៃ	អណ្តូងជីកដៃ
1	Manganese (Mn)	mg/l	-	0.1	0.1	0.1	0.1
2	Fluoide (F)	mg/l		1.5	0.21	0.8	0.26
3	Iron (Fe)	mg/l		0.3	0.03	0.15	0.03
4	Asernic (As)	mg/l	-	0.05	0	0	0
5	Total Coliform	MPN/100ml	< 1000	0	150	2100	46000
6	Nitrite-N(NO_2-N)	mg/l	-	-	-	0.011	0.216
7	True Nitrate-N(T-N)	mg/l	-	-	-	4.089	2.984

8	Nitrate-N(NO_3-N)	mg/l	-	-	-	4.1	3.2
9	Nitrate (NO_3)	mg/l	-	≤ 50	-	18.04	14.08
10	Nitrate (NO_2)	mg/l	-	≤ 2	-	0.0363	0.7128
11	pH	No Unit	6.5 - 8.5	6.5 - 8.5	6.7	4.2	4.8
12	Temperature (t°c)	°c	-	-	26.7	27.8	23.5
13	Conductivity	µS/Cm	-	1500	18.8	15.6	17.1
14	TDS	mg/l	-	800	9.4	7.8	8.55
15	Turbidliy	NTU	-	5	5		
16	Total Nitrogen (TN)	mg/l	0.1 - 0.6	- -	-	0.09	0.07
17	Total Phoshorus (TP)	mg/l	0.005 - 0.05	-	-	0.03	0.02

តារាង២៩ : លទ្ធផលការពិសោធន៍គុណភាពទឹកក្រោមដីចំណុចទី២ (សំណាកទី៥)

ល.រ	ប៉ារ៉ាម៉ែត្រ	ឯកតា	ស្តង់ដាគុណភាពទឹកក្នុងប្រភពទឹកសាធារណៈសំរាប់រក្សាជីវសាស្ត្រ ចុំះ MoE	ស្តង់ដាគុណភាពទឹកផឹក MIME	លេខសំណាក៥			
					អណ្តូងក្រុមហ៊ុន ០៦ មិនា ២០១០	អណ្តូងក្រុមហ៊ុន ០៦ ឧសភា ២០១០	អណ្តូងក្រុមហ៊ុន ១០ មិថុនា ២០១០	អណ្តូងក្រុមហ៊ុន ១២ តុលា ២០១១
1	Manganese (Mn)	mg/l	-	0.1	0.00	0.00	0.00	0.10
2	Fluoide (F)	mg/l	-	1.5	0.60	0.80	0.50	0.28
3	Iron (Fe)	mg/l	-	0.3	0.30	0.20	0.30	0.00
4	Asernic (As)	mg/l	-	0.05	0.00	0.00	0.00	0.00
5	Total Coliform	MPN/100ml	< 1000	0	0.0	0.0	12	0.00
6	Nitrite-N(NO_2-N)	mg/l	-	-	0.242	0.009	0.012	0.020
7	True Nitrate-N(T-N)	mg/l	-	-	4.758	5.671	5.888	3.58
8	Nitrate-N(NO_3-N)	mg/l	-	-	5.000	5.680	5.900	3.6
9	Nitrate (NO_3)	mg/l	-	≤ 50	22.000	24.992	25.960	15.84
10	Nitrate (NO_2)	mg/l	-	≤ 2	0.799	0.030	0.0396	0.066
11	pH	No Unit	6.5 - 8.5	6.5 - 8.5	7.00	6.60	7.20	5.20
12	Temperature (t°c)	°c	-	-	26	25.5	24	24.50
13	Conductivity	µS/Cm	-	1500	9.00	7.00	9.00	26.50
14	TDS	mg/l	-	800	4.50	3.50	4.50	13.10
15	Turbidliy	NTU	-	5	1.60	1.40	1.50	5.00
16	Total Nitrogen (TN)	mg/l	0.1 - 0.6	-	0.20	0.40	0.30	0.08
17	Total Phoshorus (TP)	mg/l	0.005 - 0.05	-	0.02	0.02	0.02	0.01

ប្រភពទិន្នន័យខាងលើបានពី C.H.D (Cambodia) Hydropower Development Co., Ltd.

យោងតាមតួលេខនៃការវិភាគទឹកលើដីខាងលើបានបង្ហាញថា មានប៉ារ៉ាម៉ែត្រដូចជា Fe, Mn, Total Coliform, pH និងភាពល្អក់ លើសពីតំលៃស្តង់ដាសំរាប់ទឹកផឹករបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល (MIME) ។ ចំណែកឯ COD, pH, និង Totall Cooliform មានតំលៃលើសពីស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹកសាធារណៈសំរាប់អភិរក្សជីវចំរុះ ក្នុងទឹករបស់ក្រសួង បរិស្ថាន (MoE) ។

៤- សន្និដ្ឋានលើគុណភាពទឹកក្នុងតំបន់គំរោងវារីអគ្គិសនីដែលកំពង់បំណើរការសាងសង់គំរោង

ក. គុណភាពទឹកលើដី

គុណភាពទឹកលើដីយោងតាមការវិភាគទឹកទាំងបីចំណុចខាងលើ យើងអាចធ្វើការសន្និដ្ឋាន ដោយប្រៀបធៀបលទ្ធផលមុនការអភិវឌ្ឍន៍គំរោង ទៅនឹងដំណាក់កាលសាងសង់គំរោង ដើម្បីធ្វើការសន្និដ្ឋានដូចតទៅ:

- ក្នុងអាងទី១ ខាងលើទំនប់ទី១: មានប៉ារ៉ាម៉ែត្រខ្លះដូចជា Turbidity, COD, Mn, Fe, និង Total Coliform មានការលើសស្តង់ដារបស់ក្រសួងទាំងពីរក៏ពិតមែន តែចំពោះការបំពុលក្នុងពេលសាងសង់នេះមានកំរិតតិចតួច នៅឡើយ កត្តាទាំងនេះគឺកើតឡើងពីធម្មជាតិដូចជា Fe, Mn មានការប្រែប្រួល ពី 0.១២-0.៥៤ mg/l ជាពិសេសវា មានការកើនឡើងនៅរដូវវស្សា។ មុនពេលសាងសង់ COD: 11.46 mg/l មានកំរិតលើសក្នុងពេលសាងសង់ ដូចនេះមានន័យថាមុនពេល

សាងសង់ ព្រៃឈើមិនបានកាប់សំអាតបាតអាងទេ ធ្វើឱ្យមានសារធាតុគីមីសរីរាង្គ ដូចជាការរលួយពុកផុយនៃស្លឹក ដើមឈើ និងការបំបែកធាតុពីអតិសុខុមប្រាណ ហើយបណ្តាលឱ្យ COD របស់ទឹកស្ទឹងអាតៃ ត្រង់អាងទី១មានការកើនឡើង។ ចំណែកឯក្នុងពេលសាងសង់ ការយកសំណាកទឹក ធ្វើឡើងនៅពេលដែលបាតអាងត្រូវបានសំអាតព្រៃឈើរួចអស់ទៅហើយ ដូចនេះ វាក៏មានកំរិត ចុះទាប មកវិញ ដោយប្រែប្រួលពី ១-៤.៧ mg/l ។ ចំណែកឯ Total Coliform មានការ កើន ឡើង ជាលំដាប់ទាំងរដូវប្រាំង និងវស្សា គឺដោយសារពេលសាងសង់នេះ មានមនុស្សចូលមក តំបន់គំរោងច្រើន ដូចនេះពួកគេរាល់គ្នាត្រូវការ ងូតទឹក បោកគក់ បញ្ចេញសំណល់រាវ-រឹង ជាពិសេសបំពុលពីលាមកកក្តាទាំងនេះ ធ្វើឱ្យបំពុលទឹកស្ទឹងនេះ ហើយ Total Coliform មានការកើនឡើងយ៉ាងនេះ។

<u>តារាង ៣៥(ក)</u>: ចំណាត់ថ្នាក់ឈើនៅក្នុងព្រៃល្បាយឫស្សីដែលនឹងត្រូវប៉ះពាល់ដោយសារគំរោង ដែលមានអង្កត់ផ្ចិតចាប់ពី៣០០មមឡើងទៅ

ល.រ	ឈ្មោះឈើ	អំបូរ	ចំនាត់ថ្នាក់	ចំនាត់ថ្នាក់	មុខកាត់ឈើសិក្សាលើផ្ទៃដី ២៥.៥០០ ម²					
#	Name	FANAM	QUACLA	QUACLA	0.3	0.4	0.5	0.6	0.7	សរុប
01	ផ្ទៀក	DIPTERACARPACEAE	*Anishoptera grabra*	ឈើលេខ២	0	1	1	1	0	3.00
02	ឈើទាល	DIPTERACARPACEAE	*Dipterocarpus alatus*	ឈើលេខ២	0	1	0	0	0	1.00
03	គគីរខ្សាច់	DIPTERACARPACEAE	*Hopea pierrei, Pierre*	ឈើលេខ២	2	0	0	0	0	2.00
04	កញ្ឆាន	DIPTERACARPACEAE	*Shorea hypochra, Hance*	ឈើលេខ២	2	1	0	0	0	3.00
05	នាងដែង	DIPTERACARPACEAE	*Dipterocarpus costatus, Gaertn*	ឈើលេខ២	0	0	2	0	0	2.00
06	ធ្នូក	ROSACEAE	*Parinarium anamensis, Hance*	ឈើលេខ៣	0	0	1	0	0	1.00
07	កំពីងរាជ	MILIACEAE	*Sandricum indicum, Cav.*	ឈើលេខ៣	1	0	0	0	0	1.00
08	ផ្លុង	GUTTIFERES	*Callophyllum sp*	ឈើលេខ៣	1	2	0	0	1	4.00
09	ស្មាក្របី	MYRISTICACEAE	*Knema corticosa, Lour.*	ឈើលេខ៣	1	0	0	0	0	1.00
10	ពពាលខែ	COMBRITACEAE	*Terminalia bialata*	ឈើក្រៅលំដាប់	1	0	0	0	0	1.00
11	ពពូលបាយ			ឈើក្រៅលំដាប់	0	0	0	0	1	1.00
12	បង្គួតទ្រ			ឈើក្រៅលំដាប់	1	0	0	0	0	1.00
13	ចំបក់	IRVINGIACEAE	*Irvingia malayana*	ឈើក្រៅលំដាប់	0	1	0	1	0	2.00
14	ឈើអង្គារ			ឈើក្រៅលំដាប់	1	0	0	0	0	1.00

លរ	ឈ្មោះឈើ	អំបូរ	ចំនាត់ថ្នាក់	ចំនាត់ថ្នាក់	មុខកាត់ឈើសិក្សាលើផ្ទៃដី ២៥.៥០០ ម²					
#	Name	FANAM	QUACLA	QUACLA	0.3	0.4	0.5	0.6	0.7	សរុប
15	ឈើអង្គុល			ឈើក្រៅលំដាប់	1	0	0	0	0	1.00
16	សេមាន់	POACEAE	*Nephelium xerospermum*	ឈើក្រៅលំដាប់	1	0	0	0	0	1.00
17	ស្មៅព្រៃ			ឈើក្រៅលំដាប់	1	0	0	0	0	1.00
18	កំសួលមង			ឈើក្រៅលំដាប់	1	0	0	0	0	1.00
19	ក្តុរភ្នំ			ឈើក្រៅលំដាប់	0	0	0	1	0	1.00
20	គួលែន		*Litchi chinensis*	ឈើក្រៅលំដាប់	3	2	0	0	0	5.00
21	គុម្ពរមាស់	THEACEAE	*Schima sp*	ឈើក្រៅលំដាប់	2	3	1	0	0	6.00
22	ទី		*Palaquium obovatum*	ឈើក្រៅលំដាប់	1	0	0	0	0	1.00
23	ភ្លូ	DILLENIACEAE	*Dillenia ovata*	ឈើក្រៅលំដាប់	1	0	0	0	0	1.00
24	រាំងភ្នំ		*Lecythidaceae*	ឈើក្រៅលំដាប់	1	1	0	0	0	2.00
25	ព្រីងស្រទាប់			ឈើក្រៅលំដាប់	2	0	1	0	0	3.00
26	រយោង	MIMOSACEAE	*Parkia streptocarps \ parkia sumatrana*	ឈើក្រៅលំដាប់	1	1	0	0	0	2.00
27	ក្រសាំងភ្នំ	RUTACEAE	*Feroniella lucida*	ឈើក្រៅលំដាប់	0	1	0	0	0	1.00
28	ត្របែកព្រៃ		*Lagerstroemia floribumba*	ឈើក្រៅលំដាប់	1	0	0	0	0	1.00
29	ត្រយោង	MELIACEAE	*Agiaia odorata*	ឈើក្រៅលំដាប់	0	1	0	0	0	1.00
30	ស្មាច់ដុំ	MYRTACEAE	*Eugenia xeylanica*	ឈើក្រៅលំដាប់	1	1	0	0	0	2.00
31	គាឡាត់	BURSERRACEAE	*Canarium album*	ឈើក្រៅលំដាប់	1	0	0	0	0	1.00
32	ខ្ចាស់			ឈើក្រៅលំដាប់	0	0	1	0	0	1.00
33	ខ្នាញ់ក្ដាម			ឈើក្រៅលំដាប់	0	1	0	0	0	1.00
34	ខ្ទះ		*Fagaceae*	ឈើក្រៅលំដាប់	5	3	0	0	0	8.00
35	តាត្រាវ	LOGANIACEAE	*Fagraea fagrans \ afzelia cochinchinensis*	ឈើប្រណិត	0	3	0	0	0	3.00
ចំនួនឈើសរុប					33.00	23.00	7.00	3.00	2.00	68.00
ដង់ស៊ីតេចំនួនឈើសរុប					27					
ដង់ស៊ីតេមាឌឈើ (ម³/ហ.ត)	**ដង់ស៊ីតេមាឌឈើសរុប**				6.36	6.25	3.34	2.44	2.55	20.93
	មាឌឈើប្រណិត				0.00	0.81	0.00	0.00	0.00	0.81
	មាឌឈើលេខ១				0.00	0.00	0.00	0.00	0.00	0.00
	មាឌឈើលេខ២				0.77	0.81	1.43	0.81	0.00	3.83
	មាឌឈើលេខ៣				0.58	0.54	0.48	0.00	1.28	2.87
	មាឌឈើក្រៅលំដាប់				5.01	4.07	1.43	1.62	1.28	13.41
ដង់ស៊ីតេមាឌឈើ: 20.93 m^3/ ha										

ខ. ព្រៃគុម្ពោធ :

សរុបការសិក្សារាប់ព្រៃឈើលើផ្ទៃដី ១.២០០ម² នៃព្រៃគុម្ពោធ មានផ្ទៃដីសរុប ១១០.៦៥ ហិកតា ដែលនឹងត្រូវប៉ះ ពាល់ដោយសារគំរោងវារីអគ្គិសនីនេះ មានដើមឈើ ២៤ ប្រភេទ ក្នុងនោះប្រភេទឈើកម្រមាន ២ប្រភេទគឺក្រញូង និងតាត្រាវ (មើលតារាង ៣៥ (ខ) ខាងក្រោម) ។

តារាង ៣៥(ខ): សរុបពូជឈើដែលនឹងត្រូវប៉ះពាល់ដោយសារគំរោងវារីអគ្គិសនីនៃព្រៃក្នុងម្តោងសិក្សាលើទំហំផ្ទៃដីសរុប ១.២០០ម²
(សិក្សា២គំរូសាក) ថ្ងៃទី ២២/៤ ដល់ ០៩/៦/២០០៨

ល.រ	ឈ្មោះឈើ	ចំនាត់ថ្នាក់	មុខកាត់ឈើ សិក្សាលើផ្ទៃដី ១.២០០ ម²				
#	Name	QUACLA	0.1	0.2	0.3	0.4	សរុប
01	ស្តី	ឈើលេខ១	1	1	0	0	2.00
02	ស្រឡៅ	ឈើលេខ១	1	0	0	0	1.00
03	ក្រឡាញ់	ឈើលេខ១	1	0	0	0	1.00
04	ត្រមូង	ឈើលេខ៣	1	0	1	0	2.00
05	ធ្នូក	ឈើលេខ៣	2	1	0	1	4.00
06	រង្គ	ឈើលេខ៣	1	0	0	0	1.00
07	ផ្ទុង	ឈើលេខ៣	1	0	1	0	2.00
08	ត្រមែង	ឈើលេខ៣	2	0	0	0	2.00
9	ព្រីង	ឈើក្រៅលំដាប់	2	0	0	0	2.00
10	ភ្នង	ឈើក្រៅលំដាប់	1	1	0	0	2.00
11	ព្រះពន្លៅ	ឈើក្រៅលំដាប់	1	1	0	0	2.00
12	គ្រង់	ឈើក្រៅលំដាប់	1	1	0	0	2.00
13	កន្ទុំរុយ	ឈើក្រៅលំដាប់	2	0	0	0	2.00
14	ឈើស	ឈើក្រៅលំដាប់	2	0	0	0	2.00
15	កំជិលពុក	ឈើក្រៅលំដាប់	0	1	0	0	1.00
16	ស្មាច់ដី	ឈើក្រៅលំដាប់	2	0	0	0	2.00
17	ភ្ញៀវ	ឈើក្រៅលំដាប់	2	0	0	0	2.00
18	កំទិចរាល	ឈើក្រៅលំដាប់	1	0	0	0	1.00
19	គុម្ពរមាស់	ឈើក្រៅលំដាប់	1	0	0	0	1.00
20	ប៉ប្រេក	ឈើក្រៅលំដាប់	1	0	0	0	1.00
21	ភ្នួ	ឈើក្រៅលំដាប់	2	0	0	0	2.00
22	កន្ទ្រោបព្រៃ	ឈើក្រៅលំដាប់	1	0	0	0	1.00
23	ក្រញូង	ឈើប្រណិត	1	0	1	0	2.00
24	តាត្រាវ	ឈើប្រណិត	0	0	1	0	1.00
ចំនួនឈើសរុប			30.00	6.00	4.00	1.00	41.00
ដង់ស៊ីតេចំនួនឈើសរុប (ដើម/ហ.ត)			300.00		41.67		
ដង់ស៊ីតេមាឌឈើ (ម³/ហ.ត)	ដង់ស៊ីតេមាឌឈើសរុប		10.62	7.07	16.37	5.77	39.83
	ឈើប្រណិត		0.35	0.00	8.19	0.00	8.54
	ឈើលេខ១		1.06	1.18	0.00	0.00	2.24
	ឈើលេខ២		0.00	0.00	0.00	0.00	0.00
	ឈើលេខ៣		2.48	1.18	8.19	5.77	17.61
	ឈើក្រៅលំដាប់		6.73	4.71	0.00	0.00	11.44
ដង់ស៊ីតេមាឌឈើសរុប: 39.83 m^3/ ha							

រុក្ខជាតិស្រទាប់ក្រោម: កូនពញា. ឈាមអន្ទង់. ស្មៅតាសិត. កូនពួច. កូនខ្នាំភ្លូ. វល្លិ៍តាន. វល្លិ៍តាជិត. កូនភ្លង. ស្មៅមើម. វល្លិ៍គុយ. ជំឡូងព្រៃ. ញិញ. វល្លិ៍ជើងក្អែក ។

យោងតាមតារាង ៣៦ (ក) ឈើដែលមានអង្កត់ផ្ចិតចាប់ពី ៣០០មម ឡើងទៅដើម្បីធ្វើចំណាត់ថ្នាក់គឺ :

តារាង ៣៦(ក): ចំណាត់ថ្នាក់ឈើនៅក្នុងព្រៃគុម្ពោតដែលនឹងត្រូវប៉ះពាល់ដោយសារគំរោង ដែលមានអង្កត់ផ្ចិតចាប់ពី៣០០មមឡើងទៅ

ល.រ	ឈ្មោះឈើ	អំបូរ	ឈ្មោះវិ.សាស្ត្រ	ចំនាត់ថ្នាក់	សិក្សាលើផ្ទៃដី ១.២០០ ម²		
#	Name	FANAM	SPENAM	QUACLA	0.3	0.4	សរុប
01	ក្រមូង	GUTTIFERES	*Garcinia oliveri, Pierre*	ឈើលេខ៣	1	0	1.00
02	ធ្លក	ROSACEAE	*Parinarium anamensis, Hance*	ឈើលេខ៣	0	1	1.00
03	ផ្ទីង	GUTTIFERES	*Callophyllum sp*	ឈើលេខ៣	1	0	1.00
04	ក្រញូង	PAPILIONACEAE	*Dalbergia cochinchinensis*	ឈើប្រណិត	1	0	1.00
05	តាត្រាវ	LOGANIACEAE	*Fagraea fagrans \ afzelia cochinchinensis*	ឈើប្រណិត	1	0	1.00
ចំនួនឈើសរុប					4.00	1.00	5.00
ដង់ស៊ីតេចំនួនឈើសរុប (ដើម/ហ.ត)					41.67		
ដង់ស៊ីតេមាឌ	**ដង់ស៊ីតេមាឌឈើសរុប (ម³/ហ.ត)**				16.37	5.77	22.14
	ឈើប្រណិត				8.19	0.00	8.19
	ឈើលេខ៣				51.85	1.93	53.79
ដង់ស៊ីតេមាឌឈើសរុប: 22.14 m³/ ha							

<u>សំគាល់:</u> *ដង់ស៊ីតេមាឌឈើជាមធ្យមនៃព្រៃឈើ៥ប្រភេទ គឺ ៧៩.៨០ ម³ /ហ.ត (សិក្សាតំបន់ ១ តំបន់២ និងតំបន់៣) ចំណែកឯទិន្នន័យរបស់ក្រុមហ៊ុនគឺ ៦៩.៩៦ ម³ /ហ.ត (សិក្សាតែក្នុងតំបន់ ១ នៃអាងទំនប់វារីអគ្គិសនី) ដូចនេះមានការខុសគ្នា +១២% ។*

៥.១.២.២ សត្វព្រៃ និងមច្ឆជាតិក្នុងតំបន់គំរោង

ការសិក្សាសត្វព្រៃ នៅតំបន់គំរោងគឺជាការងារអនុវត្តជាក់ស្តែងទៅតាមវិធីសាស្ត្រ ដូចបានចែងក្នុងជំពូក ២ ខាងលើ។ ចំពោះ សត្វព្រៃ មានពពួកថនិកសត្វ បក្សី ល្មូន និងមច្ឆជាតិ មានចែងក្នុងតារាង បន្តបន្ទាប់ ខាងក្រោម ។

ក. សត្វព្រៃ-ថនិកសត្វ

ថនិកសត្វដែលនៅសល់សព្វថ្ងៃក្នុងតំបន់គំរោងមាននៅ មានចំនួន៥០ប្រភេទ ដូចមានក្នុងតារាងលេខ ៣៧។ ប៉ុន្តែក្នុងពេលសិក្សា ESIA មិនឃើញមានថនិកសត្វ ដូចជា ដំរី, ខ្លាធំ, ខ្លាឃ្មុំ, ខ្លាលឿងមាស, ក្ដាន់, ភេរោមច្រមុះ និងកេះ ពីព្រោះ ព្រៃឈើក្នុងតំបន់ទាំងបី ត្រូវបានកាប់សំអាតបាតអាង និងសាងសង់រចនាសម្ព័ន្ធគំរោង ជាពិសេសមានមនុស្សចូលព្រៃក្បែរ តំបន់គំរោងច្រើនធ្វើឱ្យពួកវាភ័យខ្លាចមានហ៊ានចូលមកតំបន់នេះ ។

<u>តារាង៣៧</u> : ឈ្មោះថនិកសត្វមាននៅតំបន់គំរោង សិក្សាថ្ងៃទី ២២/៤ ដល់០៩/៦/២០០៨ និង ១៥/៧ ដល់ ៣០/៨/២០១១

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
១	ពង្រួល	*Manis javanica*	Sunda Pangolin	I,Cr, Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
២	ដំរី	*Elephas maximus*	Asian Elephant	I, En Z1	
៣	កែះ	*Naemirhedys sumatraensis*	Southern Serow	I, r Z1,Z2	
៤	ភេរោមច្រមុះ	*Lutra sumatrana*	Hairy-nosed Otter	II, r Z1,Z2	
៥	ភេខ្លួនរលោង	*Lutrogale perspicillata*	Smooth Otter	II Z1,Z2,Z3	
៦	ឆ្កែចចក	*Canis aureus*	Asiatic Jackal	II Z1	
៧	ប្រើស	*Cervus unicolor*	Sambar	Z1,Z2,Z3	
៨	ទោចថ្ពាល់លឿង	*Hylobates gabriellae*	Yellow-cheecked Gibbon	I, r Z1,Z2,Z3	
៩	ទោចម្កុដ	*Hulobates pileatus*	Pileated Gibbon	I, r Z1,Z2,Z3	
១០	កាំប្រមា	*Hystrix brachyura*	East Asian Porcupine	r Z1,Z2,Z3	
១១	កញ្ជ្រោង		Fox	r Z1,Z2,Z3	
១២	កំប្រុកធំ	*Retufa bicolor*	Black Giant Squirrel	II Z1,Z2,Z3	
១៣	កណ្ដុរភ្លុំធំ	*Rhizomys sumatrensis*	Large Bamboo Rat	Z1,Z2,Z3	
១៤	ក្ដាន់	*Axis porcinus*	Hog Deer	I, En Z1	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
១៥	ឆ្មាដាវ	*Prionailurus beengalensis*	Eurasian Cat	II Z1,Z2,Z3	
១៦	ឈ្លូសយក្ស	*Megamuntiacus vuquangensis*	Large-antlered Munjac	I, r Z1,Z2,Z3	
១៧	ជ្រូកព្រៃ	*Sus scrofa*	Wild Pig (Boar)	Z1,Z2,Z3	
១៨	ជ្រឹងអង្កាមកន្ទុយខ្លី	*Megaerops niphanae*	Northern Tail-less Fruit Bat	r Z1,Z2,Z3	
១៩	ជ្រឹងអង្កាមអណ្តាតធំ	*Macroglossus sobrinus*	Greater Long-tongued Fruit	r Z1,Z2,Z3	
២០	ប្រចៀវ	*(Order: CHIROPTERA)*	Bats	r Z1,Z2,Z3	
២១	រញ៉ីផេះ	*Nycticebus coucang*	Slow Loris	II	
២២	រញ៉ីភ្លើង	*Nycticebus pygmaeus*	Pygmy Loris	II Z1,Z2,Z3	
២៣	ស្កាធំ	*Herpestes urva*	Crab-eating Mongoose	III Z1,Z2,Z3	
២៤	ស្កាតូច	*Herpestes javanicus*	Smail Asiun Mongoose	Z1,Z2,Z3	
២៥	សំពោចកលឿង	*Martes flavigula*	Yellow-throated Marten	III Z1,Z2,Z3	
២៦	សំពោចក្រអូប/ត្លោត	*Paradoxurus hermaphroditus*	Common palm Civet	III Z1,Z2,Z3	
២៧	ស្វាគ្រោស	*Macaca nemestrina*	Pig-tailed Macaque	II Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
២៨	ស្វាអង្គត់	*Macaca arctoides*	Stump-tailed Macaque	II, r Z1,Z2,Z3	
២៩	ស្វាក្តាម	*Macaca fascicularis*	Long-tailed Macaque	II Z1,Z2,Z3	
៣០	ស្វាព្រាម	*semnopithecus cristatus*	Silvered Languor	II Z1,Z2,Z3	
៣១	ខ្លាពពក	*Neofelis nebulosa*	Clouded Leopard	I, En Z1,Z2,Z3	
៣២	ខ្លាល្បឿងមាស	*Catopuma temmincki*	Asian Golden Cat	I, r Z1,Z2,Z3	
៣៣	ខ្លាធំ (ដំបង)	*Panthera tigris*	Tiger	I, En Z1,Z2	
៣៤	ខ្លាត្រីថ្មកែវ	*Pardofeis marmorata*	Marbled Cat	I, r Z1,Z2,Z3	
៣៥	ខ្លាត្រី	*Prionailurus viverrinus*	Fishing Cat	II Z1,Z2,Z3	
៣៦	ខ្លារខិន	*Panthera pardus*	Leopard	I, r Z1,Z2,Z3	
៣៧	ខ្លាឃ្មុំធំ	*Ursus thibetanus*	Asiatic Black Bear	En Z1,Z2,Z3	
៣៨	ខ្លាឃ្មុំតូច	*Ursus malayanus*	Sun Bear	I Z1,Z2,Z3	
៣៩	ខ្ទីង	*Bos gaurus*	Gaur	III Z1	
៤០	ភេក្បាលសំប៉ែត	*Lutra lutra*	Eurasian Cat	I, r Z1,Z2	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៤១	ក្តាន់ញ្ជែង ឬជ្ជូង តូច	*Tragulus javanicus*	Lesser Mousedeer	Z1,Z2,Z3	
៤២	ក្តាន់ញ្ជែង ឬជ្ជូង ធំ	*Tragulus napu*	Greater Mousedeer	Z1,Z2,Z3	
៤៣	ខ្វីន	*Viverra zibetha*	Large Indian Civet	III Z1,Z2,Z3	
៤៤	សំពោចវល្លិ៍/ឈ្មុសវល្លិ៍	*Viverricula india*	Small Indian Civet	III Z1,Z2,Z3	
៤៥	កន្ធីក	*Tupaia belangeri*	Northern Treeshew	II Z1,Z2,Z3	
៤៦	ឆ្កែព្រៃ	*Cuon alpinus*	Dholes	II Z1	
៤៧	កង្ហែន	*Menetes berdmorei*	Berddmore's Squirrel	r Z1,Z2,Z3	
៤៨	ឈ្លូសប្រែង ឬសំពោចភ្នំ	*Arctictis binturong*	Binturong	III Z1,Z2,Z3	
៤៩	កំប្រុកស្វាបរោមជើង	*Trogopterus pearsonii*	.Hiry-footed Flying Squirrel	r Z1,Z2,Z3	
៥០	កង្ហិច	*Tamiops maritimus*	Eastern Striped Squirrel	r Z1,Z2,Z3	

<u>សំគាល់</u>: I, II, III ជាលេខឧបសម្ព័ន្ធអនុសញ្ញា CITES ។ តាមរដ្ឋបាលព្រៃឈើ En: ប្រភេទជិតផុតពូជ. Cr: ប្រភេទកំពុងរងគ្រោះ. r: ប្រភេទកម្រ. Vu: ប្រភេទងាយរងគ្រោះ ។ ការជួបប្រទះឃើញ ក្នុង Z1: តំបន់១, Z2: តំបន់២, Z3: តំបន់៣

ខ. បក្សី

ចំពោះសត្វស្លាបដែលរស់នៅក្នុងតំបន់គំរោងមាន ១៣០ ប្រភេទ ដូចដែលបានចែងក្នុងតារាងលេខ៣៨ខាងក្រោម:

<u>តារាង៣៨</u>: ឈ្មោះបក្សីដែលមាននៅក្នុងតំបន់គំរោង សិក្សាថ្ងៃទី ២២/៤ ដល់ ០៩/៦/២០០៨ និង ១៥/៧ ដល់៣០/៨/២០១១

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
១	ពពិចបំពង់ក ស ទ្រូងលឿងចាស់	*Alophoixus pallidus*	Puff-throated Bulbul	Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
២	ពពិចពុកមាត់លឿង	*Pycnonotus finlaysoni*	Stripe-throated Bulbul	Z1,Z2,Z3	
៣	ពពិចខ្មៅ	*Hypsipetes leucocephalus*	Black Bulbul	Z1,Z2,Z3	
៤	ពពិចក្បាលខ្មៅចុងខ្នង ស	Pycnonotus aurigaster	Sooty-headed Bulbul	Z1,Z2,Z3	
៥	ពពិចក្បាលខ្មៅកំប៉ោយ	*Pycnonotus melanicterus*	Black-crested Bulbul	Z1,Z2,Z3	
៦	ពពិចត្រចៀកឆ្នូត	*Pynonotus blanfordi*	Streak-eared Bulbul	Z1,Z2,Z3	
៧	ពពិចត្រចៀកក្រហមស	*Pycnonotus jocosus*	Red-whiskered Bulbul	Z1,Z2,Z3	
៨	ពញ្លាក់ចង់	*Caprimulgus macrurus*	Large-tailed Nightjar	Z1,Z2,Z3	
៩	ពញ្លាក់ជុំរិត	*Caprimulgus affinis*	Savanna Nightjar	Z1,Z2,Z3	
១០	ពពុះទឹក	*Tachybaptus ruficollis*	Little Grebe	Z1	
១១	ពពូលបំពង់ក លឿង	*Treron pompadora*	Pompadour Green Pigeon	Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
១២	ពពូលទំពុះធំលឿង ឬ កំប្អុក	*Treron curvirostra*	Thick-billed Green Pigeon	Z1,Z2,Z3	
១៣	ពពូលជើងលឿង	*Treron phoenicoptera*	Yellow-footed Green Pigeon	Z1,Z2,Z3	
១៤	ពពូលទឹក	*Heliopais personata*	Masked Finfoot	r Z1	
១៥	ញ៉ាំង ឬពវ៉ាំង	*Aceros undulatus*	Wreathed Hornbill	II, r Z1,Z2,Z3	
១៦	ចាបចង្រុង	*Lonchura punctulata*	Scaly-breasted Munia	Z1,Z3	
១៧	ចាបចង្រុងចុងខ្នងស	*Lonchura striata*	White-rumped Munia	Z1,Z3	
១៨	ចាបចង្រុងក្បាលខ្មៅ	*Lonchura malacca*	Black-headed Munia	Z1,Z3	
១៩	ចាបដង្គូវពណ៌ស្លាបច្រេះ	*Prinia rufescens*	Rufescent Prinia	Z1,Z2,Z3	
២០	ចាបដង្គូវចិញ្ចើមស	*Prinia inornata*	Plain Prinia	Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
២១	ចាបដង្កូវលឿង	*Prinia flaviventris*	Yellow-bellied Prinia	Z1,Z2,Z3	
២២	ចាបដង្កូវទ្រូងប្រផេះ	*Prinia hodgsonii*	Grey-breasted Prinia	Z1,Z2,Z3	
២៣	ចាបដូនតា	*Acrocephalus orientalis*	Oriental Reed Wabler	Z1,Z3	
២៤	ចាបដូនតាចិញ្ចើមខ្មៅ-ស	*Acrocephalus bistrigiceps*	Black-browed Reed Wabler	Z1,Z3	
២៥	ចាបតេត	*Orthotomus sutorius*	Common Tailorbird	Z1,Z2,Z3	
២៦	ចាបតេតព្រៃ	*Orthotomus atrogularis*	Dark-necked Tailorbird	Z1,Z2,Z3	
២៧	ចាបកន្ទង់	*Nectarinia jugularis*	Olive-backed Sunbird	Z1,Z2,Z3	
២៨	ចាបកន្ទង់ពោះក្រហម	*Nectarinia sperata*	Purple-throated Sunbird	Z1,Z2,Z3	
២៩	ចាបកន្ទង់ក្រហម	*Aethopyga siparaja*	Crimson Sunbird	Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៣០	ចាបផ្ទះ	*Passer montanus*	Eurasian Tree Sparrow	Z1	
៣១	ចាបក្រច	*Pycnonotus goiavier*	Yellow-vented Bulbul	Z1,Z2,Z3	
៣២	ចាបក្រុក	*Megalurus palustris*	Striated Grassbird	Z1,Z2,Z3	
៣៣	ចាបស្រុក	*Passer flaveolus*	Plain-backed Sparrow	Z1,Z2,Z3	
៣៤	ចចាតក្រឹម	*Alcedo atthis*	Common Kingfisher	Z1	
៣៥	ចកវិកកំប៉ោយស ឬត្រលែងវែក	*Garrulax leucolophus*	White-crested Laughingthrush	Z1,Z2,Z3	
៣៦	ចកវិកវល្លទ្រូងខ្មៅ	*Garrulax monileger*	Lesser Necklaced Laughingthrush	Z1,Z2,Z3	
៣៧	ចេកទុំខៀវ	Irena puella	Asian Fairy Bluebird	Z1,Z2,Z3	
៣៨	ចេកទុំក្បាលខ្មៅ	*Oriolus xanthornus*	Black-hooded Oriole	Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៣៩	ចេកខ្ចីថ្ងាសភ្លើង	*Chloropsis aurifrons*	Golden-fronted Leafbird	Z1,Z2,Z3	
៤០	ចេកខ្ចីស្លាបខៀវ	*Chloropsis cochinchinensis*	Blue-winged Leafbird	Z1,Z2,Z3	
៤១	ក្អែក	*Corvus macrohynchos*	Large-billed Crow	Z1,Z3	
៤២	ក្អែកទឹកធំ	*Phalacrocorax carbo*	Great Cormorant	Z1	
៤៣	ក្ងោកបៃតង	*Pavo muticus*	Green Peafowl	II Z1	
៤៤	កេងកងពណ៌ត្នោត	*Anorrhinus tic[illegible]*	Brown Hornbill	II Z1,Z2,Z3	
៤៥	កេងកងធំ	*Buceros bicomis*	Great Hornbill	I, r Z1,Z2,Z3	
៤៦	កេងកងតូច	*Anthracoceros albirostris*	Oriental Pied Hornbill	II Z1,Z2,Z3	
៤៧	មៀមតូចព្រៃ	*Glaucidium cucloides*	Asian Barred Owlet	II Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៤៨	សេកសោម	*Psittacula eupatria*	Alexandrine Parakeet	II, r Z1,Z2,Z3	
៤៩	សេកអាត់	*Psittacula roseata*	Blossom-headed Parakeet	II Z1,Z3	
៥០	សេកកន្ទុយខៀវលឿង	*Psittacula finschii*	Grey-headed Parakeet	II Z1,Z3	
៥១	ស្តេចកូលីត	*Lophura diardi*	Siamese Fireback	Z1	
៥២	ទោម	*Porphyrio porphyrio*	Purple Swamphen	Z1	
៥៣	ខ្លែងឆាបលឿងក្រម៉ៅ	*Haliastur indus*	Brahminy Kite	II Z1,Z2,Z3	
៥៤	ខ្លែងស្រាក	*Tyto alba*	Barn Owl	II Z1,Z2,Z3	
៥៥	ខ្វែក	*Nycticorax nycticorax*	Black-crowned Night Heron	Z1	
៥៦	ខ្វែកត្រោកធម្មតា (ត្រោក)	*Gallinago gallinago*	Common Snipe	Z1	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៥៧	ចាបពពិចព្រៃគម្លោច	*Saxicola caprata*	Pied Bushchat	Z1	
៥៨	ចាបពពិចស្រែ	*Anthus rufulus*	Paddyfield Pipit	Z1	
៥៩	ងាវកក	*Halcyon capensis*	Stork-billed Kingfisher	Z1,Z2,Z3	
៦០	អន្ទេបខ្មៅ	*Dicrurus macrocercus*	Black Drongo	Z1,Z2,Z3	
៦១	អន្ទេបខ្មៅផ្លេក	Dicrurus aeneus	Bronzed Drongo	Z1,Z2,Z3	
៦២	អន្ទេបប្រផេះ	Dicrurus leucophaeus	Ashy Drongo	Z1,Z2,Z3	
៦៣	អន្ទេបទងកន្ទ្រៃ	Dicrurus paradiseus	Greater Racket-tailed Drongo	Z1,Z2,Z3	
៦៤	អកពស់ព្រៃ	*Spilornis cheela*	Crested Serpent Eagle	II Z1,Z2,Z3	
៦៥	អកត្រីក្បាលប្រផេះ	*Icthyophaga icthyaetus*	Grey-headed Fish-Eagle	II Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៦៦	កញ្ជាក់ស្ទាវីល្អកខ្មៅ	*Rhipidura javanica*	Pied Fantail	Z1,Z2,Z3	
៦៧	កដបខ្មៅស	*Ceryle rudis*	Pied Kingfisher	Z1,Z2,Z3	
៦៨	កដបខៀវស	*Todiramphus cholris*	Collared Kingfisher	Z1,Z2,Z3	
៦៩	កដបក្បាល ខ្មៅ ឬប៉កតាវ	*Halcyon pileata*	Black-capped Kingfisher	Z1,Z2,Z3	
៧០	កដបទ្រូងស	*Halcyon smymensis*	White-throated Kingfisher	Z1,Z2,Z3	
៧១	កុកគោ	*Bubulcus ibis*	Cattle Egret	iII Z1	
៧២	កុកម្ទេសទុំ	*Ixobrychus cinnamomeus*	Cinnamon Bittern	Z1	
៧៣	កុកគ្រោងធំ	*Egretta alble*	Great Egretta	III Z1	
៧៤	កុកគ្រោងមធ្យម	*Egretta intermedia*	Intermediate Egret	III Z1	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៧៥	កុកខ្មៅថ្នើមអណ្តើក	*Bupetor flavicollis*	Black Bittern	Z1	
៧៦	កុកសំបកត្រពាំង	*Ixobrychus sinensis*	Yellow Bittern	Z1	
៧៧	ល្អូតធំ	*Centropus sinensis*	Greater Coucal	Z1,Z2,Z3	
៧៨	លលកបាយ	*Streptopelia chinensis*	Spotted Dove	Z1,Z2,Z3	
៧៩	លលកទ្រាំង	*Streptopelia tranquebarica*	Red Collared Dove	Z1,Z3	
៨០	ល្វាចេកព្រៃ	*Copsychus malabaricus*	White-rumped Shama	Z1,Z2,Z3	
៨១	ល្វាចេកស្រុក	*Copsychus saularis*	Oriental Magpie Robin	Z1,Z3	
៨២	មាន់ព្រៃ	*Gallus gallus*	Red Junglefowl	Z1,Z2,Z3	
៨៣	មាន់ទោពណិប្រាក់	*Lophura nycthemera*	Silver Pheasant	II Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៨៤	មាន់ទឹកខ្មៅ	*Gallinula chloropus*	Common Moorhen	Z1	
៨៥	មាន់ទឹកទ្រូងស	*Amauromis phoenicurus*	White-breasted Waterhen	Z1	
៨៦	ឆ្លងឆ្លុតលឿង	*Dendrocitta vagabunda*	Rufous Treepie	Z1,Z2,Z3	
៨៧	ឆ្លងឆ្លុតខៀវ	*Urocissa eryihrothyncha*	Red-billed Blue Magpie	Z1,Z2,Z3	
៨៨	ព្រាបកោះ	*Caloenas nicobarica*	Nicobar Pigeon	r Z1,Z2,Z3	
៨៩	ព្រាបព្រៃ	*Ducula aenea*	Green Imperial Pigeon	Z1,Z2,Z3	
៩០	ប្រវែក	*Nettapus coromandelianus*	Cotton Pygmy-goose	Z1	
៩១	ប្រម៉ង់	*Pandion haliaetus*	Osprey	II Z1,Z2,Z3	
៩២	ប្រវីក	*Dendrocygna javanica*	Lesser Whistling Duck	Z1,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
៩៣	ររអាតត្នោត	*Butastur liventer*	Rufous-winged Buzzard	II Z1,Z2,Z3	
៩៤	គ្រួចអិន	*Mirafra assamica*	Rufous-winged Bushlark	Z1	
៩៥	គ្រួចអ៊ិត	*Tumix suscitator*	Barred Buttonquail	Z1	
៩៦	ត្រចៀកកាំ	*Hirundo rustica*	Barn Swallow	Z1,Z2,Z3	
៩៧	ត្រចៀកកាំខ្មៅចុងខ្នងស	*Apus affinis*	House Swift	Z1,Z2,Z3	
៩៨	ត្រដេវក្បាលបៃតង	*Merops philipinus*	Blue-tailed Bee-eater	Z1,Z2,Z3	
៩៩	ត្រដេវតូច	*Merops orientailis*	Green Bee-eater	Z1,Z2,Z3	
១០០	ត្រដេវិចក្បាលប្រផេះ	*Vanellus cinereus*	Grey-headed Lapwing	Z1,Z2,Z3	
១០១	ត្រដេវិចទូល	*Vanellus indicus*	Red-wattled Lapwing	Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
១០២	ត្រសេះបៃតង ទ្រូងពក្នាក់	*Picus xanthopygaeus*	Streak-throated Woodecker	Z1,Z2,Z3	
១០៣	ត្រសេះខ្មៅ-សតូច	*Dendrocopos canicapillus*	Grey-capped Pygmy Woodpecker	Z1,Z2,Z3	
១០៤	ត្រសេះធំ ពោះស	*Dryocopus javensis*	White-bellied Woodpecker	Z1,Z2,Z3	
១០៥	ត្រសេះធំកំប៉ោយលឿង	*Picus flavinucha*	Greater Yellownape	Z1,Z2,Z3	
១០៦	ត្រសេះខ្នងភ្លើងតូច	*Dinopium javanense*	Common Flameback	Z1,Z2,Z3	
១០៧	សារិកាកែវក្របី	*Acridotheres javanicus*	White-vented Myna	Z1,Z2,	
១០៨	សារិកាកែវវែង	Gracula religiosa	Hill Myna	II Z1,Z2,Z3	
១០៩	ស្ទាំងលលក	*Elanus coeruleus*	Black-shouldered Kite	II Z1,Z2,Z3	
១១០	ស្ទាំងស្លាបផែក	*Accipiter badius*	Shikra	II Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
១១១	ស្ទាំងស្ទាបផែកត្នោត កំប៉ោយ	*Aviceda jerdoni*	Jerdon's Baza	II, r Z1,Z2,Z3	
១១២	ស្ទាំងស្ទាបផែកខ្មៅ-ស	*Aviceda leuphotes*	Black Baza	II Z1,Z2,Z3	
១១៣	ស្ទាំងស្ទាបស្រួចចុងខ្នង ស	*Polihierax insignis*	White-rumped Falcon	II Z1,Z2,Z3	
១១៤	ស្ទាំងស្ទាបស្រួចតូច	*Microhierax caerulescens*	Collared Falconet	II Z1,Z2,Z3	
១១៥	ពាវៅ	*Eudynamys scolopacea*	Common Koel	Z1,Z2,Z3	
១១៦	ទាកាបព្រៃ	*Anas poecilorhyncha*	Spot-billed Duck	Z1,Z2,Z3	
១១៧	ទាវព្រៃ	*Eurystomus orientalis*	Dollarbird	Z2,Z3	
១១៨	ទាវខៀវ	*Coracias benghalensis*	Indian Roller	Z1,Z2,Z3	
១១៩	ទីទុយធំព្រៃ	*Bubo nipalensis*	Spot-bellied Eagle Owl	II Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
១២០	ទីទុយត្រីថ្មសក្អោត	*Ketupa zeylonensis*	Brown Fish Owl	II Z1,Z2,Z3	
១២១	ទីទុយត្រីថ្មសស	*Ketupa Ketupu*	Buffy Fish Owl	II Z1,Z2,Z3	
១២២	តុកកាគូ	*Phaenicophaeus tristis*	Green-billed Malkoha	Z1	
១២៣	ខ្ទប់ដីលឿងក្រោម	*Motacilla flava*	Yellow Wagtail	Z1	
១២៤	ខ្ទប់ដីព្រៃ	*Dendronanthus indicus*	Forest Wagtail	Z1	
១២៥	ខ្ទប់ដីខ្មៅ-ស	*Motacilla alba*	White Wagtail	Z1	
១២៦	អកភ្នំ	*Spizaetus nipalensis*	Mountain Hawk Eagle	II Z1,Z2,Z3	
១២៧	លួតស្បូវ	*Centropus bengalensis*	Lesser Coucal	Z1,Z2,Z3	
១២៨	លលកស្លាបបៃតង (លលកខ្មោច)	*Chalcophaps indica*	Emerald Dove	Z1,Z2,Z3	

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបភាព
១២៩	ទីទុយឡឹក	*Otus bakkamoena*	Collared Scops Owl	II Z1, Z2	
១៣០	ទីទុយក្របី	*Phodilus badius*	Oriental Bay Owl	II Z1, Z2	

សំគាល់: I, II, III ជាលេខឧបសម្ព័ន្ធអនុសញ្ញា CITES ។ តាមរដ្ឋបាលព្រៃឈើ En: ប្រភេទជិតផុតពូជ, r: ប្រភេទកម្រ, ។ ការជួបប្រទះក្នុង Z1: តំបន់១, Z2: តំបន់២, Z2: តំបន់៣ ។

ត. ពពួកឧរង្គសត្វ (ល្មូន) និង កង្កែប

យោងតាមក្រុមការងាររបស់ SAWAC បានរកឃើញ នៅក្នុងតំបន់គំរោងមានពពួកឧរង្គសត្វ និងកង្កែប ៣៦ ប្រភេទ ដូចមានចែងនៅក្នុងតារាងលេខ ៣៩ ខាងក្រោម ។ ក្នុងពេលសិក្សា IESIA មានល្មូន២ប្រភេទមិនឃើញមានដូចជា អណ្តើកមាស និងអណ្តើកក្របីក្បាលលឿង ។

តារាង ៣៩: ឈ្មោះពពួកឧរង្គសត្វ ដែលមាននៅក្នុងតំបន់គំរោង សិក្សាថ្ងៃទី ២២/៤ ដល់ ០៩/៦/២០០៨ និង ១៥/៧ ដល់ ៣០/៨/២០១១

ល.រ	ឈ្មោះភាសាខ្មែរ	ឈ្មោះវិទ្យាសាស្ត្រ	ឈ្មោះភាសាអង់គ្លេស	សំគាល់	រូបថត
១	បង្កួយសួនច្បារ	*Calotes versicolor*	Garden Fence Lizard	Z1,Z2,Z3	
២	បង្កួយស្នែង		Horned Lizard	Z1,Z2,Z3	
៣	ពស់ក្រាយខ្លួនឆ្នូតខ្មៅ	*Bungarus candidus*	Malayan Krait	Z1,Z2,Z3	
៤	ពស់ព្រៃ	*Ptyas mucosus*	Common Ratsnake	II Z1,Z2,Z3	
៥	ពស់ព្រៃខ្មៅ	*Ptyas korros*	Indochinese Ratsnake	Z1,Z2,Z3	
៦	ពស់ព្រៃក្បាលវិល្លិ ស	*Rhabdophis chrysargus*	Speckel-bellied Keelback	Z1,Z2,Z3	
៧	ពស់វែកជីបូក	*Naja siamensis*	Indochinese Spitting Cobra	II Z1,Z2,Z3	

៨	ពស់វែកគ្របី	*Naja kaouthia*	Monocle Cobra	II Z1,Z2,Z3	
៩	ពស់វែករនាម	*Ophiophagus hannah*	King Cobra	II Z1,Z2,Z3	
១០	ពស់ក្រាយ	*Bungarus fasciatus*	Banded Krait	Z1,Z2,Z3	
១១	ពស់ត្រីរស់ ឬ ពស់កាចាន់	*Enhydris bocourti*	Bocourt's Watersnake	Z1	
១២	ថ្លាន់ធំឬពស់ថ្លាន់ក្បាលលឿង	*Python reticulatus*	Reticulated Python	Z1,Z2,Z3	
១៣	ថ្លាន់តូច ឬ ពស់ថ្លាន់ក្បាលខ្មៅ	*Python molurus bivittatus*	Burmese Python	Z1,Z2,Z3	
១៤	ពស់ស្មាអឡេង	*Amphiesma stolata*	Striped Keelback	Z1,Z2,Z3	
១៥	ពស់ហនុមានបៃតង	*Boiga cyanea*	Green Cat Snake	Z1,Z2,Z3	
១៦	ពស់កកុកបៃតងច្រមុះវែង	*Ahaetulla nasuta*	Long-nosed Whip Snake	Z1,Z2,Z3	
១៧	ពស់ពព្លាក់ភ្នំខ្លួនខ្ចី	*Calloselasma rhodostoma*	Malayan Pit-viper	Z1,Z2,Z3	
១៨	ពស់ពព្លាក់ក្បាលខ្មៅ	*Oligodon mouhoti*	Cambodian Kukri Snake	Z1,Z2,Z3	
១៩	ពស់ពព្លាក់ភ្នំក្បាលធំ	*Ovophis monticola*	Montain Pit-viper	Z1,Z2,Z3	
២០	អណ្ដើកបិទមុខស្នូកខ្មៅ	*Cuora amboinensis*	Asian Box Turtle	II Z1,Z2,Z3	
២១	អណ្ដើកភ្នំ/ព្រិច/ដំបូក	*Indotestudo elongata*	Elongated Tortoise	Z1,Z2,Z3	
២២	អណ្ដើកមាស/អណ្ដើកខ្នាយ	*Manouria impressa*	Impressed Tortoise	II, Vu Z1,Z2	

២៣	អណ្តើកក្របីក្បាលលឿង	*Heosemys annandalii*	Yellow-headed Temple Turtle	Cr Z1	
២៤	អណ្តើកស្រែ	*Malayemys subtrijuga*	Rice-field terrapin Turtle	En Z1	
២៥	កញ្ចាញ់ចេក		Flying Frog	Z1,Z2,Z3	
២៦	កង្កែប	*Hoplobatrachus tigerinus*	Tiger Frog	Z1,Z2,Z3	
២៧	គីង្គក់		Toad	Z1,Z3	
២៨	កន្ធាយ	*Amyda cartilaginea*	Asiatic Softshell Turtle	Vu Z1,Z2,Z3	
២៩	កន្ធ្រង	*Physignathus cocincinus*	Water Dragon	Z1,Z2,Z3	
៣០	ក្រពើត្រី . ក្រពើភ្នំ	*Crocodylus siamensis*	Siamese Crocodile	I, Vu Z2	
៣១	ព្រពូច	*Varanus bengalensis*	Common Monitor	Z1,Z2,Z3	
៣២	តុកកែ		Tokay Gecko	Z1,Z2,Z3	
៣៣	បង្គួយស្លាបបំពង់លឿង	*Draco maculatus*	Spotted Gliding Lizard	Z1,Z2,Z3	
៣៤	បង្គួយខ្នងខ្មៅ	*Calotes emma alticristatus*	Northern Forest Crested Lizard	Z1,Z2,Z3	
៣៥	អន្សង	*Vararus salvator*	Water Monitor	II Z1,Z2,Z3	
៣៦	ពស់ព្រៃខ្លួនក្រហម-បៃតង	*Rhabdophis nigrocinctus*	Green Keelback	Z1,Z2,Z3	

<u>**សំគាល់**</u>: I, II, III ជាលេខឧបសម្ព័ន្ធអនុសញ្ញា CITES ។ តាមរដ្ឋបាលព្រៃឈើ En: ប្រភេទជិតផុតពូជ. r: ប្រភេទកម្រ. ។ ការជួបប្រទះក្នុង Z1: តំបន់១. Z2: តំបន់២. Z3: តំបន់៣ ។

រូបថតខាងក្រោមនេះក្រុមការងារថតបានសត្វមួយចំនួនដូចតទៅៈ



ស្វាក្ដាម រូបថត ថ្ងៃ ១០/៧/២០១១ ក្នុងតំបន់១



ជ្រូកព្រៃ រូបថត ថ្ងៃ ១៦/៧/២០១១ ក្នុងតំបន់ ២



ពស់ពេ្លាក់ រូបថត ថ្ងៃ ២២/៧/២០១១ ក្នុងតំបន់ ៣



កូនក្រពើភ្នំ រូបថត ថ្ងៃ ១០/៨/២០១១ ក្នុងតំបន់ ២ អន្លងល្អះក្រោមទំនប់ទី២



សត្វក្អែក រូបថត ថ្ងៃ ១១/៨/២០១១ ក្នុងតំបន់ ១



ស្ដេចកូលីត រូបថត ថ្ងៃ ២០/៧/២០១១ ក្បែរតំបន់អាងទី១ (តំនប់១)



អកពស់ព្រៃ រូបថត ថ្ងៃ ១២/៨/២០១១ ក្នុងតំបន់ ២

អណ្ដើកភ្នំ/ព្រិចប្រជាជនចាប់បាន ក្បែរតំបន់ ២រូបថត ថ្ងៃ ១២/៨/២០១១



កេងកងធំ រូបថត ថ្ងៃ ១០/៧/២០១១ ក្នុងតំបន់ ១

ទាវខៀវ រូបថត ថ្ងៃ ១៥/៧/២០១១ ក្បែរតំបន់ ១

ឃ. ធនធានជលផល

ឃ.១ គោលបំណងក្នុងការសិក្សា:

គោលបំណងសិក្សាធនធានជលផលនៅក្នុងតំបន់គំរោងនេះគឺធ្វើនៅស្ទឹងអាតៃ ដោយមានគោលបំណងដូចតទៅ:

- ស្ថិតិគ្រួសារនេសាទ ប្រភេទ និងចំនួនឧបករណ៍នេសាទ ។
- ព័ត៌មានបច្ចេកទេសនេសាទ
- បរិមាណផលចាប់ត្រី តាមប្រភេទឧបករណ៍ ដែលនេសាទនៅតំបន់គំរោង និងក្រោមតំបន់គំរោង ក្នុងដំណាក់កាលមុន និងកំពុងសាងសង់គំរោង ។
- ការប៉ាន់ប្រមាណបរិមាណផលចាប់ត្រី ក្នុងដំណាក់កាលមុនការសាងសង់ និងកំពុងសាងសង់គំរោង ។
- ប្រភេទផលចាប់ត្រីក្នុង និងក្រោមតំបន់គំរោង ។
- ការធ្វើចរាចរត្រី ពីតំបន់គំរោង ។

សំគាល់: វិធីសាស្ត្រនៃការសិក្សាធនធានជលផលមានចែងក្នុងជំពូក ២ ។

ឃ.២ លទ្ធផលនៃការសិក្សា

១. ស្ថិតិគ្រួសារនេសាទ និងចំនួនឧបករណ៍

តារាង ៤០: ស្ថិតិគ្រួសារនេសាទ និងឧបករណ៍នេសាទ

លេខរៀង	ឈ្មោះភូមិ	ចំនួនគ្រួសារនេសាទ	ចំនួនឧបករណ៍នេសាទ 2008-2011			
			សំណាញ់	មងត្រី (៣-៨ ស.ម)	សន្ទូច	អង្រុត
1	អូរសោម	44	4	18	39	4
2	ត្បៀនជង្រុក	50	4	19	43	5
3	កណ្ដាល	22	7	7	17	0
4	ឆាយលូក	51	17	17	35	0
	សរុប	167	32	60	134	9

២. ព័ត៌មានបច្ចេកទេសនេសាទគ្រួសារ ឆ្នាំ២០០៩ -២០១១

តារាង ៤១: ព័ត៌មានបច្ចេកទេសនេសាទគ្រួសារ ឆ្នាំ២០០៩-២០១១

ប្រភេទឧបករណ៍	ផលចាប់ មធ្យម	ចំនួន ឧបករណ៍	រយៈពេល (D/m)	រយៈពេល ១ខែ/ឆ្នាំ	ទិន្នផល មធ្យម(Kg)	ម៉ោង/ថ្ងៃ	ចំនួន ឬ ទំហំ ឧបករណ៍/ម្នាក់	CPUE	ផលចាប់មធ្យម /ឧបករណ៍ /ឆ្នាំ
មងត្រី	2.65	60.00	15.00	8.00	19080	12	$225m^2$	0.0010	318
សន្ទូចដៃ	0.65	50.00	25.00	2.00	1625	4	2ដៃ	0.0813	33
អង្រុត	2.35	9.00	25.00	3.00	1586	5	1អង្រុត	0.4700	176
សន្ទូចរនងបោះ	2.50	46.00	15.00	5.00	8625	12	50ដៃ	0.0042	188
សំណាញ់	2.25	32.00	20.00	4	5760	4	$5m^2$	0.1125	180
Total Yield					36676				

សំគាល់ : បច្ចេកទេសក្នុងដំណាក់កាលសាងសង់នេះមានលំនាំដូចៗគ្នា ។

ការប្រែប្រួល បរិមាណផលចាប់ត្រីក្នុងដំណាក់កាលមុនការសាងសង់ និងកំពុងសាងសង់គំរោង ។

- យោងតាមការសំភាសន៍ ចំនួន៥០គ្រួសារ បានឲ្យដឹងថា : បរិមាណផលចាប់ត្រីមធ្យម ជាលក្ខណៈគ្រួសារចំនួនសរុប ១៦៧គ្រួសារ នៅឆ្នាំ២០០៩ មានចំនួន 36676Kg ។
- បរិមាណផលចាប់មធ្យម ឆ្នាំ២០១០ មានចំនួន 31175Kg តាមការសំភាសន៍ : បរិមាណផលចាប់ ថយចុះ មធ្យម ១៥ភាគរយ ធៀបឆ្នាំ២០០៩ ដោយសារ ការប្រើឧបករណ៍ខុសច្បាប់ ។
- បរិមាណផលចាប់មធ្យម ឆ្នាំ២០១១ មានចំនួន 12470Kg (តាមការសំភាសន៍ និង ការសិក្សាផ្ទាល់ បរិមាណផលត្រីចាប់ថយចុះមធ្យម ៦០ភាគរយ ធៀបឆ្នាំ២០០៩ ដោយសារ ការកើនឡើង អ្នកចំណូលថ្មី កម្មករសំអាត ឈើក្នុងអាង ដែលប្រើ ឧបករណ៍នេសាទខុសច្បាប់ នៅក្នុងតំបន់អាងទី១ និងគុណភាពទឹកថយចុះ ។



៤.៣ ប្រភេទត្រី ដែលមានក្នុងតំបន់គំរោង

តាមរយៈការសិក្សាផ្ទាល់នៅក្នុងតំបន់គំរោងផ្នែកខាងក្រោមតំបន់គំរោងតាមប្រភេទឧបករណ៍នេសាទបានបង្ហាញថាមាន២១ប្រភេទ ដូចមានបង្ហាញក្នុងតារាងខាងក្រោម :

តារាង៤២ : ឈ្មោះមច្ឆជាតិដែលមាននៅក្នុងអូរ ដៃស្ទឹង និងស្ទឹងអាតៃ ផ្នែកខាងលើ និងខាងក្រោម សម្រាប់ឆ្នាំ២០១១

ល.រ	ឈ្មោះខ្មែរ	តំបន់នេសាទ	សំគាល់
១	ត្រីខ្យារ	Upst,Dost	ការសិក្សានេះ ពុំទាន់អាចដាក់ឈ្មោះ វិទ្យាសាស្ត្របានទេ ដោយសារ ប្រភេទត្រីភាគច្រើននៅតំបន់ភ្នំ វាអាចខុសគ្នាពីតំបន់ទន្លេសាប ទោះបីវាមានឈ្មោះខ្មែរដូចគ្នាក៏ដោយ។ ដូចនេះ ឈ្មោះត្រីនេះ អាចឱ្យអ្នកវិទ្យាសាស្ត្រជលផលស្រាវជ្រាវបន្ត ជាឈ្មោះវិទ្យាសាស្ត្រ បន្ថែមទៀត។
២	ត្រីខ្យា	Dost	
៣	ត្រីច្រកែង	Dost	
៤	ត្រីស្រកាក្តាម	Upst,Dost	
៥	ត្រីខ្មៅ	Dost	
៦	ត្រីកញ្ជូនជ័យ	Upst,Dost	
៧	ត្រីខ្ទីង	Upst,Dost	
៨	ត្រីក្រុស	Upst	
៩	ត្រីក្រុសភ្នំ	Dost	
១០	ត្រីកំភ័រ	Upst,Dost	
១១	ខ្ទាន់	Upst,Dost	
១២	ត្រីទ្រនុងខ្នងបញ្ច្រាស	Dost	
១៣	ត្រីអណ្តែង	Upst,Dost	
១៤	ត្រីអណ្តែងម៉ាង	Dost	
១៥	ត្រីថ្ម/កញ្ចុះដាវ	Dost	
១៦	ត្រីខ្យាន	Upst,	
១៧	ត្រីពពកេស	Upst,	
១៨	ត្រីស្រការ៉ែង	Upst,	
១៩	ត្រីក្រាញ់	Upst,	
២០	កន្ធ្រប់ រស់	Upst,	
២១	អន្ទង់	Upst,	

សំគាល់: ការជូបប្រទះក្នុង Upst: ផ្នែកខាងលើនៃស្ទឹងអាតៃ គឺចាប់ពីចំណុចឆាយប្រ៊ុយ ដល់ទំនប់អាងទី១. Dost: ផ្នែកខាងក្រោមស្ទឹងអាតៃដល់ស្ទឹងឬស្សីជ្រុំ។

៣.៤ ប្រភេទត្រី ដែលសិក្សានៅតំបន់នេសាទក្នុងតំបន់គំរោង និងស្ទឹងអាតៃផ្នែកខាងក្រោមគំរោង

ប្រភេទត្រីដែលចាប់បានក្នុងតំបន់គំរោង និងផ្នែកខាងក្រោមតំបន់គំរោង : តាមការសិក្សាប្រភេទត្រី ដែលចាប់ចំនួនប្រភេទដូចខាងក្រោមនេះ គឺក្រុមការងារបានសិក្សា ដោយចែកជាបីតំបន់នេសាទ រួមមាន : តំបន់នេសាទទី១ (ស្ទឹងអាតៃ អូរធម្មជាតិក្នុងអាងទី១) និងតំបន់នេសាទ២ ចាប់ពីស្ទឹងអាតៃ ចន្លោះទំនប់ទី១ មកទី២ និងតំបន់នេសាទទី៣ នៃស្ទឹងអាតៃផ្នែកខាងក្រោមតំបន់គំរោង។

១- ប្រភេទត្រីខ្នាវ



<u>ទីជំរករបស់ត្រីខ្នាវ :</u> អន្លង់ តាមស្ទឹងអាតៃ នៅក្នុងតំបន់គំរោង និងផ្នែកខាងក្រោមតំបន់គំរោង។
<u>ទីតាំងនេសាទត្រីខ្នាវ :</u> ស្ទឹងអាតៃ និងដៃស្ទឹងអាតៃ នៅក្នុង និងផ្នែកខាងក្រោមតំបន់គំរោង ។
គំរូត្រី: ១០ត្រី Lo=165-215mm, D= 3/8, A=3/5, P=1/11, V=1/8, L1=27

ត្រីខ្នាវ មានសំបុរពណ៌ខៀវប្រាក់មានឆ្នូតត្រែតូចៗមួយខ្សែ នៅតាមបណ្តោយដងខ្លួន។ រដូវពងកូននៅខែឧសភារហូតដល់បំណាច់ខែសីហា។ គេតែងចាប់វាបានច្រើន នៅស្ទឹងអាតៃ នៅក្នុង និងផ្នែកខាងក្រោមនិង ខាងលើនៃស្ទឹងអាតៃ ដោយឧបករណ៍មងក្រឡា ៤ហ៊ុន ទៅ៦ហ៊ុន។ បរិមាណផលត្រីខ្នាវខ្ពស់ជាងប្រភេទត្រីផ្សេងទៀត។

២- ប្រភេទត្រីក្រុស



ប្រភេទត្រីក្រុស (*Osteochilus hasseltii*)

គំរូត្រី: ៥ត្រី Lo = 120-165mm
D = 3/12-13 , A=3/5 , P=1/10-11
V=1/8 , L1=31-32

ប្រភេទត្រីក្រុសភ្នំ

គំរូត្រី: ៥ត្រី Lo = 170-200mm
D = 3/15 , A=3/5 , P=2/10-11
V=12 , L1=32-33

ទីជំរករបស់ត្រី : - ត្រីក្រុស ***Osteochilus hasseltii*** នៅតាមអន្លង់ និងស្ទឹងអាតៃ និងដៃស្ទឹងអាតៃ ក្នុងតំបន់គំរោង។
- ត្រីក្រុសភ្នំ រស់នៅតាមអន្លុង និងតាមស្ទឹងអាតៃផ្នែកខាងក្រោម នៃតំបន់គំរោង ។

ទីតាំងនេសាទ: - ត្រីក្រុស ***Osteochilus hasseltii*** ដៃស្ទឹងអាតៃ និងស្ទឹងអាតៃ ក្នុងតំបន់គំរោង។
- ត្រីក្រុសភ្នំ : នេសាទនៅស្ទឹងអាតៃផ្នែកខាងក្រោម នៃតំបន់គំរោង។

ត្រីក្រុស ***Osteochilus hasseltii*** ជាប្រភេទត្រីស៊ីបួងគុង រស់នៅស្រទាប់កណ្តាល ដងខ្លួនរបស់វាមានលឿងព្រើងៗ កន្ទុយពណ៌ក្រហម មានចំណុចខៀវ ៩ជួរតាមបណ្តោយដងខ្លួន។ រដូវពងកូន នៅខែកក្កដា រហូតដល់ចុងខែសីហា។ គេតែងនេសាទវាដោយឧបករណ៍មងត្រី ក្រឡា៤ ទៅ ៦ស.ម ។

ត្រីក្រុសភ្នំ ជាប្រភេទត្រីស៊ីបួងគុង រស់នៅស្រទាប់កណ្តាល ដងខ្លួនរបស់វាមានពណ៌ខៀវស្លែ ព្រុយពណ៌ ប្រផេះ ហើយមានទំហំធំជាងត្រីក្រុស ផ្សេងទៀត ។

៣- ប្រភេទត្រីច្រកែង



ទីជំរករបស់ត្រីច្រកែង : នៅតាមអន្លង់ និងស្ទឹងអាតៃផ្នែកខាងក្រោមនៃតំបន់គំរោង ។

ទីតាំងនេសាទ: ស្ទឹងអាតៃផ្នែកខាងក្រោម នៃតំបន់គំរោង ។

គំរូត្រី: ១០ត្រី Lo=190-210mm, D= 3/9, A= 3/5, P=1/9, V=1/8, L1=35

ជាប្រភេទត្រីស៊ីប្លង់តុង រស់នៅស្រទាប់បាត និងកណ្ដាល ដងខ្លួនរបស់វាមានពណ៌ក្រហាំ ... ពណ៌ផ្កាឈូកប្រផេះ មានខ្សែឆ្នូតមួយខ្សែតាមបណ្ដោយដងខ្លួន។។ រដូវពងកូន នៅខែឧសភា រហូតដល់ចុងខែសីហា ។ ...នេសាទវាបាន ដោយឧបករណ៍មងត្រីក្រឡា៤ ទៅ ៨ស.ម ។

៤- ប្រភេទត្រីស្រកាក្ដាម

ទីជំរក : អន្លង់ និងដងស្ទឹងអាតៃ នៅក្នុង និងផ្នែកខាងក្រោមតំបន់គំរោង ។

ទីតាំងនេសាទ : ស្ទឹងអាតៃក្នុង និងផ្នែកខាងក្រោមតំបន់គំរោង ។

គំរូត្រី: ៥ត្រី L0=120-130mm , D= 3/9 , P=9 , A=3/5 , V=10 , L1=33

៥- ប្រភេទត្រីខ្មៅ



ទីជំរករបស់ត្រីខ្មៅ : អន្លង់ និងដងស្ទឹងអាតៃ ផ្នែកខាងក្រោម នៃតំបន់គំរោង ។

ទីតាំងនេសាទ : ដៃស្ទឹងអាតៃ និងស្ទឹងអាតៃផ្នែកខាងក្រោមតំបន់គំរោង ។

គំរូត្រី: ១០ត្រី L0=175-210mm , D= 3/10 , P=1/18-19 , A=3/5 , V= 1/8-9 , L1=22

រដូវពងកូន នៅខែកក្កដា រហូតដល់ សីហា ។ គេតែងចាប់វាបានច្រើន នៅស្ទឹងអាតៃផ្នែកខាងក្រោម នៃតំបន់គំរោង (ចាប់ពីល្បាក់ឆាយប្រុយ មកផ្នែកខាងក្រោម) ។ គេមិនប្រទះឃើញវានៅផ្នែកខាងលើទំនប់ទី២ទេ ដោយសារត្រីនេះពុំអាចឆ្លងកាត់ល្បាក់ឆាយប្រុយបាន ។ គេប្រទះឃើញវាចុះមកទំលាក់ពងនៅព្រែកកោះប៉ោផងដែរ នៅពេលទឹកជំនន់ខែកក្កដា និង សីហារៀងរាល់ឆ្នាំជាមួយត្រីក្រុសតែមានបរិមាណតិចតួចប៉ុណ្ណោះ ។ គេតែងចាប់វាបានដោយឧបករណ៍មងក្រឡា៤ប៉ុនទៅ៥ប៉ុននៅស្ទឹងអាតៃផ្នែកខាងក្រោមនៃតំបន់គំរោងគ្រប់រដូវ ។

៦- ប្រភេទត្រីកំភ័រ/ខ្ទាន់


ត្រីកំភ័រ


ត្រីខ្ទាន់

ទីជំរករបស់ត្រីកំភ័រ : អន្លង់ ដងស្ទឹងអាតៃ ក្នុង និងផ្នែកខាងក្រោមនៃតំបន់គំរោង ។

ទីតាំងចាប់បានត្រីកំភ័រ/ខ្ទាន់ : នៅស្ទឹងអាតៃក្នុង និងផ្នែកខាងក្រោម នៃតំបន់គំរោង ។

គំរូត្រី: ១០ត្រី Lo=215-323mm, D= 3/ 8, A=3/5, P=1/14, V=1/8, L.1= 25

រដូវពងកូន នៅខែឧសភា រហូតដល់ សីហា គេតែងចាប់វាបាន នៅស្ទឹងអាតៃក្នុង និងផ្នែកខាងក្រោម នៃតំបន់គំរោង ដោយ ឧបករណ៍មងត្រី ក្រឡា៦-៨ហ៊ុន ។

៧- ប្រភេទត្រីទ្រនុងខ្នងបញ្ច្រាស



ទីជំរករបស់ត្រីទ្រនុងខ្នងបញ្ច្រាស: អន្លង់ និងតាមដងស្ទឹងអាតៃ ផ្នែកខាងក្រោមតំបន់គំរោង ។

ទីតាំងចាប់បានត្រីទ្រនុងខ្នងបញ្ច្រាស: ស្ទឹងអាតៃផ្នែកក្រោម នៃតំបន់គំរោង ។

គំរូត្រី: ១០ត្រី Lo=105-110mm, D= 3/I/8, A=3/9, P=8, V=9, L.1= 26

រដូវពងកូន នៅខែឧសភា រហូតដល់សីហា គេតែងចាប់វាបាន នៅស្ទឹងអាតៃផ្នែកខាងក្រោមនៃតំបន់គំរោង (តាមការសិក្សាកន្លងមកត្រី នេះ ក៏មានចាប់បាននៅស្ទឹងកំចាយ ខាងក្រោមទំនប់ទី២) ផងដែរ ដោយ ឧបករណ៍មងត្រី ក្រឡា៤ហ៊ុន ។ ខ្លួនវាពណ៌ប្រាក់ ព្រុយខ្នង ពណ៌ផ្កាឈូក និងខ្មៅខាងចុង រីឯព្រុយកន្ទុយ ព្រុយគូថ ព្រុយទ្រូង និងព្រុយពោះ មានពណ៌លឿង ។

៨- ប្រភេទត្រីស្រកាវឹង



ទីជំរករបស់ត្រីស្រកាវឹង: អន្លង់ នៃស្ទឹងអាតៃក្នុងតំបន់គំរោង ។

ទីតាំងចាប់បានត្រីស្រកាវឹង: ស្ទឹងអាតៃ ក្នុងតំបន់គំរោង ។

គំរូត្រី: ២ត្រី Lo=130-132mm, D= 3/8, A=3/5, P=8, V=9, L.1= 28-29

រដូវពងកូន នៅខែឧសភា រហូតដល់សីហា គេតែងចាប់វាបាន នៅដៃស្ទឹង និងស្ទឹងអាតៃផ្នែកខាងក្នុងតំបន់គំរោង ដោយ ឧបករណ៍មងត្រីក្រឡា ៤-៦ហ៊ុន ។ ខ្លួនវាពណ៌ប្រាក់ ព្រុយខ្នង ព្រុយកន្ទុយ ព្រុយគូថ និងព្រុយពោះ មាន ពណ៌ត្នោតខ្មៅ ។

៩- ប្រភេទត្រីលលកស



ទីជំរករបស់ត្រីលលកស: អន្លង់ ឬថ្លុក នៃស្ទឹងអាតៃក្នុងតំបន់គំរោង ។

ទីតាំងចាប់បានត្រីលលកស: ស្ទឹងអាតៃ ក្នុងតំបន់គំរោង ។

គំរូត្រី: ៩ត្រី Lo=40-50mm, D= 3/12-14, A=2/5, P= 8

រដូវពងកូន នៅខែឧសភា រហូតដល់សីហា គេតែងចាប់វាបាន នៅដៃស្ទឹង និងស្ទឹងអាតៃផ្នែកខាងក្នុងតំបន់គំរោង ដោយឧបករណ៍មងត្រីក្រឡា ៤ហ៊ុន ។ ខ្លួនវាពណ៌ប្រាក់ ព្រុយខ្នង ព្រុយកន្ទុយ មានពណ៌ត្នោតខ្មៅ រីឯព្រុយគូថ និងព្រុយពោះ លឿងស្រាល ។

១០- ប្រភេទត្រីអណ្តែង



ត្រីអណ្តែង

ត្រីអណ្តែងងាំង

ទីជំរករបស់ត្រី : - ត្រីអណ្តែង : នៅតាមអន្លង់ និងស្ទឹងអាតៃ និងដៃស្ទឹងអាតៃ ក្នុង និងផ្នែកខាងក្រោមតំបន់គំរោង ។

- ត្រីអណ្តែងងាំង :នៅតាមអន្លង់ នៃស្ទឹងអាតៃផ្នែកខាងក្រោមតំបន់គំរោង ។

ទីតាំងនេសាទ: - ត្រីអណ្តែងទន់ :ដៃស្ទឹងអាតៃ ក្នុង និងក្រោមតំបន់គំរោង ។

- ត្រីអណ្តែងងាំង : ស្ទឹងអាតៃផ្នែកខាងក្រោម តំបន់គំរោង ។

គំរូត្រីអណ្តែងទន់: ៩ត្រី Lo = 150-220mm, D= 73,A=45-46, P=I/8-9, V=7

គំរូត្រីអណ្តែងងាំង: ២ត្រី Lo = 160-240mm ពុំបានរាប់ចំនួនទ្រនង់ ទេ

ត្រីអណ្តែងទន់ជាប្រភេទត្រីរស់នៅស្រទាប់បាតស៊ីស្លែ និងZooplankton ដងខ្លួនរបស់វាមានត្នោតក្រម៉ៅ ដែលតែងនេសាទវាបានដោយឧបករណ៍សន្ទូចបោះ នៅស្ទឹង ឬដៃស្ទឹងក្នុង និងផ្នែកខាងក្រោមតំបន់គំរោង។ រដូវពងកូន នៅខែឧសភា រហូតដល់ចុងខែសីហា។ រីឯត្រីអណ្តែងងាំង មានពណ៌លឿង វែង គេតែងចាប់វាបានដោយសន្ទូច មងត្រី នៅស្ទឹងផ្នែកខាងក្រោមតំបន់គំរោង ។

១១- ប្រភេទត្រីខ្យាន



ទីជំរករបស់ត្រីខ្យាន : នៅតាមស្ទឹងអាតៃ និងដៃស្ទឹងអាតៃ ក្នុង និងផ្នែកខាងក្រោមតំបន់គំរោង ជាពិសេស នៅតាមល្បាក់មានទឹកហូរខ្លាំង ។

ទីតាំងនេសាទត្រីខ្យាន: ដៃស្ទឹងអាតៃ និងតាមដងស្ទឹងអាតៃ ក្នុង និងផ្នែកខាងក្រោមតំបន់គំរោង ។

គំរូត្រី: ៥ត្រី Lo = 130-140mm, D=34, A=22, P=15, L.1= 41

ត្រីខ្យានគេតែងចាប់វាបាន នៅតាមផ្លូក នៃដៃស្ទឹងអាតៃ និងត្រង់ល្បាក់ទឹកហូរខ្លាំង ជាពិសេស នៅផ្នែកខាងក្រោម ល្បាក់ឆាយប្រុយ ។ វាជាប្រភេទ ត្រីស៊ីសាច់ជាអាហារ និងZooplankton ។ ដងខ្លួនរបស់វាមានត្នោតក្រម៉ៅ ព្រុយកន្ទុយ និងព្រុយខ្នងពណ៌ត្នោតខ្មៅ ហើយរឹមព្រុយនេះ មានពណ៌ក្រហម ។ ដែលតែងនេសាទ វាបានដោយឧបករណ៍សន្ទូច ។ រដូវពងកូន នៅខែឧសភារហូតដល់ចុងខែសីហា ។

១២- ត្រីជញ្ជូនជ័យ

ទីជំរករបស់ត្រី : ត្រីជញ្ជូនជ័យ នៅតាមស្ទឹង និងដៃស្ទឹងអាតៃ និងស្ទឹងក្រោមទំនប់ទី២ ។

ទីតាំងនេសាទ: ស្ទឹង និងដៃស្ទឹងអាតៃ និងស្ទឹងក្រោមទំនប់ទី២ ។

គំរូត្រី: ៥ត្រី Lo = 180-210mm, D= 38-40, A=28, P=18, L1= 19+5+41=65

១៣- ប្រភេទត្រីខ្យា

ទីជំរករបស់ត្រី : ត្រីខ្យា នៅតាមស្ទឹងអាតៃផ្នែកខាងក្រោម ។

ទីតាំងនេសាទ: ស្ទឹងអាតៃផ្នែកខាងក្រោម តំបន់គំរោង ។

គំរូត្រី: ៥ត្រី Lo = 350-470mm, D= I/7, A=3/9, P=I/8

១៤- ប្រភេទត្រីខ្ទីងខ្មៅ

ទីជំរករបស់ត្រីខ្ទីងខ្មៅ : អន្លង់ នៃស្ទឹងអាតៃ ក្នុង និងផ្នែកខាងក្រោមតំបន់គំរោង ។

ទីតាំងនេសាទត្រីខ្ទីងខ្មៅ: ស្ទឹងអាតៃក្នុង និងផ្នែកខាងក្រោម តំបន់គំរោង ។

ធំរូត្រី: ៥ត្រី Lo=165- 350mm, D= XXXV-XXXVII/ 80-85, A=III/80 , P=30

ត្រីខ្ចឹងស្ទឹងផ្នែកខាងក្រោមទំនប់ទី២នេះ មានសំបុរត្នោតក្រម៉ៅមានរាងមូលវែង វាជាប្រភេទត្រីរស់នៅទឹកស្រទាប់បាត ដែលមានល្បាយខ្សាច់ ក្បែរថ្ម ។ រដូវពងកូន នៅខែឧសភា រហូតដល់ខែសីហា។ គេតែងចាប់វាបានច្រើននៅស្ទឹងអាតៃ ដោយឧបករណ៍សន្ទូចរនង និងមង។

១៥- ប្រភេទត្រីថ្ម

ទីជំរករបស់ត្រីថ្ម/កញ្ចុះជំរ: អន្លង់ នៃស្ទឹងអាតៃផ្នែកខាងក្រោមនៃតំបន់គំរោង។

ទីតាំងនេសាទត្រីថ្ម/កញ្ចុះជំរ : ស្ទឹងអាតៃផ្នែកខាងក្រោម នៃតំបន់គំរោង។ ត្រីនេះ មិនបានកំណត់អត្តសញ្ញាណរបស់វាទេ។

ក្រៅពីនេះ នៅមានចាប់បានប្រភេទត្រីស្រែ និងតាមបឹងមួយចំនួន ដូចជា ត្រីក្រាញ់ អន្ទង់ ត្រីកន្ទ្រប់ ។

  

ខ.៥ ការវិភាគប្រភេទផលចាប់ត្រី ដែលសិក្សានៅតំបន់នេសាទ នៃស្ទឹងអាតៃផ្នែកខាងក្រោមតំបន់គំរោង

យោងតាមសិក្សា របស់ក្រុមការងារ ក្នុងឆ្នាំ២០១១ នេះ បានបង្ហាញថា : ត្រីខ្នាវ មានអត្រាខ្ពស់រហូតដល់៣១ភាគរយ បន្ទាប់ប្រភេទត្រីក្រុស ១៣ភាគរយ ជាពិសេសត្រីក្រុសភ្នំ ត្រីទ្រនុងខ្នងបញ្ញាស ៩ភាគរយ ត្រីច្រកែង ៩ភាគរយ ត្រីកញ្ជនជ័យ ៥ភាគរយ ត្រីស្រកាក្តាម និងត្រីខ្មៅ ៤ភាគរយ ត្រីអណ្តែង ៣ភាគរយ និងត្រីកញ្ជនជ័យ ៣ភាគរយ ត្រីខ្ចឹង ១ភាគរយ និងត្រីកញ្ចុះជំរ១ ភាគរយ ដែលនេសាទ ដោយ ឧបករណ៍មងត្រី និងត្រីខ្យា ១២ភាគរយ ត្រីអណ្តែង ៤ភាគរយ និងត្រីកញ្ជនជ័យ ២ភាគរយ និង ត្រីខ្ចឹង១ភាគរយ ដែលនេសាទឧបករណ៍សន្ទូចរនង ។ ដូចមានបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោម :



គ.៣.២ ប្រភេទផលចាប់ត្រី ដែលសិក្សានៅតំបន់នេសាទ នៃស្ទឹងអាតៃ ក្នុងតំបន់គំរោង



គ.៤ ការធ្វើចរាចរត្រី :

យោងតាម សិក្សាអំពីការធ្វើចរាចរត្រីនេះ បានឱ្យដឹងថាៈ ប្រភេទត្រីដែលមានក្នុងស្ទឹងអាតៃ និងដៃរបស់វា ផ្នែកខាងក្រោម នៃតំបន់គំរោង មានប្រភេទត្រីមួយចំនួនរស់នៅមានទំនាក់ទំនងជាមួយតំបន់ទឹកភ្លាវ (តំរេន់មាត់ពាមព្រែកកោះប៉ោ) ដើម្បីបន្តពូជ នៅពេលមានទឹកជំនន់នៅខែកក្កដា និងខែសីហា ដូចជា ត្រីខ្នាៅ ត្រីក្រុស និងត្រីខ្សា។ ត្រីទាំងនេះ បានផ្លាស់ទីឡើងមកវិញ នៅពេលទំលាក់ពង រួចរាល់ នៅតំបន់មាត់ពាមព្រែកកោះប៉ោ ។

ដោយសារ ស្ទឹងអាតៃនៅផ្នែកខាងលើមានល្បាក់ជ្រៅប្រមាណ៥៥ម ត្រង់ចំណុចឆាយប្រុយ ទើបយើងសិក្សា ពុំមានឃើញមានប្រភេទត្រីមួយ ចំនួនខាងលើនេះ មាននៅផ្នែកខាងលើ ក្នុងតំបន់គំរោងឡើយ ដោយសារ វាមិនអាចឡើងល្បាក់ឆាយប្រុយនេះរួច ។

៥.១.២.៣ ទីជំរក (Habitat)

យោងតាមផែនទគំរបព្រៃឈើរបស់ពីរដ្ឋបាលព្រៃឈើ ដែលផលិតដោយ JICA ឆ្នាំ ២០០២ និង DANIDA 2006 មាត្រដ្ឋាន ១/១.០០០.០០០ និងផែនទី ព្រៃការពារ និងតំបន់ការពារនៃប្រទេសកម្ពុជា គំរោងនេះមានផ្ទៃដីស្ថិតនៅក្នុងតំបន់ព្រៃការពារដងទុង ដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ ដោយមានការសហការជាមួយអង្គការ WILDLIFE ALLIANCE, តំបន់ដែនជំរកសត្វព្រៃភ្នំសំកុសដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន, និងតំបន់ព្រៃការពារអភិរក្សជីវចំរុះជួរភ្នំក្រវាញភាគកណ្តាល ដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើសហការជាមួយអង្គការ CI ក្នុងនោះក៏មានតំបន់ព្រៃការពារក្រវាញឃុំអូរសោមផងដែរ ។ ចំណែកផ្ទៃដីគំរោង លំអិតនោះមើលតារាងខាងក្រោមៈ

តារាង ៤៣: ផ្ទៃដីតំបន់គំរោងស្ថិតនៅក្នុងតំបន់ព្រៃការពារ និងតំបន់ការពារ សិក្សាថ្ងៃទី ថ្ងៃទី ១៥ ខែកក្កដា ដល់ ៣០ ខែសីហា ឆ្នាំ២០១១

ID	ឈ្មោះតំបន់ព្រៃការពារ និង តំបន់ការពារ	សរុប (ha)	សំគាល់
1	ព្រៃការពារដងទង់ - Wildlife Alliance	972.86	រដ្ឋបាលព្រៃឈើគ្រប់គ្រង

ID	ឈ្មោះតំបន់ព្រៃការពារ និង តំបន់ការពារ	សរុប (ha)	សំគាល់
2	ដែនជំរកសត្វព្រៃភ្នំសំកុស	2438.28	ក្រសួងបរិស្ថានគ្រប់គ្រង
3	ព្រៃការពារអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញភាគកណ្តាល	1687.53	ក្នុងនោះមាន ២៧.៦១ ហ.ត ជាដីព្រៃការពារក្រវាញ ឃុំអូរសោម
	Total	5098.67	

តំបន់ព្រៃការពារទាំងពីរ និងតំបន់ការពារដែនជំរកសត្វព្រៃនេះ ជាទីជំរកយ៉ាងសំខាន់ដែលគ្របដណ្តប់លាតសន្ធឹងជាប់ៗគ្នាទៅដោយព្រៃទឹកភ្លៀងតំបន់ត្រូពិក ដែលមានព្រៃស្រោង ព្រៃពាក់កណ្តាលស្រោង ព្រៃល្បាយឫស្សី ព្រៃគម្ពោធ និងវាស្មៅរួមទាំងមានអូរ ស្ទឹង បឹងធម្មជាតិមួយចំនួន បង្កលក្ខណៈជាទីជំរកយ៉ាងប្រសើរសំរាប់ពពួកសត្វព្រៃមួយចំនួនធំ ជាពិសេសពពួកថនិកសត្វធំៗ ដូចជា ដំរី ខ្លាធំ ខ្លារខិន ខ្លាឃ្មុំធំ ជាដើម ។ សព្វថ្ងៃនេះ តំបន់ទីជំរកសត្វព្រៃត្រូវបានកាត់ផ្តាច់ជាតំបន់ផ្សេងៗពីគ្នា ដោយសារការធ្វើផ្លូវគមនាគមន៍ចូលតំបន់គំរោង ធ្វើគន្លងខ្សែបញ្ជូនចរន្តអគ្គិសនី ។ល។ ពេលក្រុមការងារចូលទៅសិក្សា បានឮស្នូរកាំភ្លើង ដែលអ្នកប្រមាញ់ សត្វព្រៃនៅពេលយប់ អ្នកអារឈើខុសច្បាប់ អ្នករកក្រញូងជាច្រើនបានបានចូលក្នុងព្រៃក្បែរខាងគំរោងដែលធ្វើឱ្យសត្វព្រៃ បាត់ជំរក ហើយភ័យខ្លាចរត់ទៅតំបន់ឆ្ងាយ និងបាត់បង់មួយចំនួនទៀតផង ។

ចំពោះទីជំរករបស់មច្ឆជាតិគឺនៅតាមស្ទឹងអាតៃ មានពីរសណ្ឋានដីចេញពីគ្នាដោយសារទឹកធ្លាក់ឆាយប្រុយ ដែលមានកំពស់រហូតដល់ ៥៥ម.។ តំបន់អាងទី១ អាងទី២ និងតំបន់ខាងក្រោមទំនប់ទី២ ដល់ចំណុចឆាយប្រុយនេះ យើងហៅថា ផ្នែកខាងលើនៃស្ទឹងអាតៃ។ រីឯចាប់ពីខាងក្រោមទឹកធ្លាក់ភ្ជាប់ជាមួយស្ទឹងតាសុក ដល់ស្ទឹងឫស្សីជ្រុំ រួចបន្តដល់ចំណុចក្បាលឆាយទឹកដីកោះកុង ហៅថាផ្នែកខាងក្រោមនៃស្ទឹងអាតៃ ឬស្ទឹងឫស្សីជ្រុំក្រោម ។ នៅតាមពោះស្ទឹងអាតៃមានរណ្តៅជាអន្លង់ ដែលមានផ្ទាំង ដុំថ្មជាច្រើនកន្លែង និងមានដីទំនាប នៅតំបន់អាងទី១ ធ្វើឱ្យពពួកមច្ឆជាតិដែលបានថែងខាងលើរស់នៅ និងលាក់ខ្លួនបានស្រួលទៀតផង ។ បន្ថែមលើនេះទៅទៀត យោងតាមការវិភាគ គុណភាពទឹក៣ កន្លែងនៅក្នុងស្ទឹងអាតៃ បានបង្ហាញថា កំរិតអុកស៊ីសែនរលាយក្នុងទឹកមានចាប់ពី ៤.៩១mg/l ទៅ ៦.៨mg/l នេះ បង្ហាញថាស្ទឹងនេះមិនទាន់មានការបំពុលធ្ងន់ធ្ងរពីសកម្មភាពរបស់មនុស្សទេ ទោះបីជា មានប្រជាជនរស់នៅតំបន់ខាងលើទំនប់ទី១នៃតំបន់អូរសោម និងការបំពុលពីការសាងសង់គំរោងនេះតិចតួចពិតមែនក៏ដោយ ។ ទោះជាយ៉ាងនេះក្តីទៅអនាគតសង្ឃឹមថា នៅដំណាក់កាលប្រត្តិបត្តិថែទាំគំរោង នឹងមានការកើនឡើងនូវមច្ឆជាតិ ពីពោះជំរៅទឹកក្នុងអាងទី១ តំបន់អូរក្របីងាប់ ស្ទឹងតាកង ស្ទឹងភ្លក់ ជាមធ្យមប្រមាណពី ៨ម ទៅ ២០មប៉ុណ្ណោះ(មិនគិតពោះស្ទឹង) ម្យ៉ាងទៀតអ្នកចំណូលថ្មី នឹងដកចេញពីតំបន់ខ្ពង់ស្រល់ដល់ចំណុចស្ទឹងតាកង ពីព្រោះដំណាក់កាលមុនសាងសង់គំរោង ឆ្នាំ២០០៨ គ្មានមនុស្សរស់នៅទេទីនេះ ហើយតំបន់នេះស្ថិតក្នុងដែនជំរកសត្វព្រៃភ្នំសំកុសទៀតផង ។

៥.១.២.៤ ជីវចំរុះ និងជីវសាស្ត្រចមទាំងប្រពន្ធ័អេកូឡូស៊ី (Biodiversities and Bio-Ecological Systems)

ដូចបានថែងក្នុង ចំណុចទីជំរកខាងលើតំបន់គំរោងស្ថិតក្នុងតំបន់ព្រៃការពារ និង តំបន់អភិរក្ស ដែលមានប្រពន្ធ័អេកូឡូស៊ីយ៉ាងច្រើន ដែលពាក់ពន្ធ័គ្នាយ៉ាងសាំញ៉ាំ រួមទាំងចង្វាក់ចំណីអាហារ និងទីជំរករបស់សត្វព្រៃទៀតផង ។ តំបន់នេះត្រូវបានយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការថែរក្សា និងអភិរក្ស ព្រមទាំងមានការសហប្រតិបត្តការជាមួយ អង្គការ CI និង WILDLIFE ALLIANCE ហើយគេបានធ្វើសេចក្តីរាយការណ៍ថា តំបន់អាតៃជាតំបន់ជួរភ្នំ ខ្ពង់រាប និងជ្រលង ដែលតភ្ជាប់គ្នាជាមួយប្រពន្ធ័តំបន់អេកូឡូស៊ីព្រៃទឹកភ្លៀងក្រាស នៃតំបន់ត្រូពិកក្រវាញខាងត្បូងទៅនិងតំបន់ក្រវាញកណ្តាល ហើយនិងភ្ជាប់ជាមួយតំបន់អភិរក្សដែនជំរកសត្វព្រៃភ្នំសំកុសទៀតផង។ ដូចនេះក្នុងការអភិវឌ្ឍន៍គំរោងក្នុងតំបន់នេះគប្បីពិចារណារ និងធ្វើការកាត់បន្ថយឱ្យដល់កំរិតតិចបំផុត ដែលអាចទទួលយកបាន (ដូចជាការប្រមាញ់សំលាប់ ការកាត់ផ្តាច់របៀង រំខានដោយការចូលព្រៃរបស់មនុស្សយ៉ាងច្រើន

បំផ្លាញជំរកសត្វព្រៃដែលគ្មានពីក្នុងលោកទាំងនេះ គឺតាមរយៈការធ្វើ តន្លងខ្សែបញ្ជូនចរន្ត ការសាងសង់ផ្លូវចូល ក្នុងតំបន់ ការធ្វេសប្រហែសក្នុងការអនុវត្តន៏ច្បាប់ពាក់ពន្ធ័ ក្នុងការទប់ស្កាត់បទល្មើស ជាដើម ។ល ។)

៥.១.២.៥ ប្រព័ន្ធដីសើម

យោងតាមសៀវភៅ A Natual Resources Based Development Strategy for the Tonle Sap Area ដែលរៀបរាងដោយ Mekong River Commission Secretariat ខែមិថុនា ឆ្នាំ១៩៩៩ និងសៀវភៅ Mapping wetlands in the Lower Mekong Basin for wetland resource and conservation management using Landsat ETM images and field survey data ដែលរៀបរាងដោយ Mekong River Commission Secretariat ឆ្នាំ២០០៩ បានបញ្ជាក់ថា ប្រព័ន្ធដីសើមគឺ មាននៅតែជុំវិញបឹងទន្លេសាប និងតាមបណ្តោយទន្លេមេគង្គប៉ុណ្ណោះ ដែលជាតំបន់ទំនាបកណ្តាល ដោយឡែកនៅតំបន់គំរោងជាតំបន់ខ្ពង់រាប ដែលសំបូរទៅដោយជួរភ្នំ ជ្រោះជ្រង់ជ្រលងជងអូរ មិនមានប្រព័ន្ធដីសើមទេ ។

៥.២ បរិស្ថានសេដ្ឋកិច្ច_សង្គមនៅក្នុងតំបន់គំរោង (Socio-Ecomomic Environment)

ការសិក្សាវាយតំលៃបរិស្ថានសេដ្ឋកិច្ច-សង្គម លើគំរោងវារីអគ្គិសនីអាតៃនេះគឺត្រូវបានធ្វើឡើងចំពោះតែគ្រួសារ ដែលរងផលប៉ះពាល់ផ្ទាល់ពីគំរោងតែប៉ុណ្ណោះ ដើម្បីធ្វើការវិភាគលើសេដ្ឋកិច្ចក៏វិតជីវភាពរស់នៅរបស់ពួកគាត់ រីឯអ្នកមិនប៉ះពាល់គឺមិនបានធ្វើការវិភាគលើសេដ្ឋកិច្ចរបស់ពួកគាត់ទេ ក៏ប៉ុន្តែក្រុមការងារបានប្រជុំផ្សព្វផ្សាយ និងទទួលយកមតិសំណូមពររបស់ពួកគាត់ផងដែរ ។

៥.២.១ ប្រជាសាស្ត្រ និងការតាំងទីលំនៅ

ទីតាំងភូមិសាស្ត្រគំរោងវារីអគ្គិសនីស្ទឹងអាតៃ ស្ថិតនៅក្នុងដែនដីគ្រប់គ្រងរដ្ឋបាលរបស់ស្រុកវាលវែងនៃឃុំអូរសោម ក្នុងខេត្តពោធិ៍សាត់ (ផ្ទៃ អាង ទំនប់ រទូបំពង់ទូរនេល អគារថាមពល ការិយាល័យ កន្លែងស្នាក់នៅ ខ្សែចម្លងចរន្ត ១១៥Kv) ។ គំរោងនេះ ក៏ស្ថិតនៅក្នុង ដែនជំរកសត្វព្រៃភ្នំសំកុសជារបស់ក្រសួងបរិស្ថាន. តំបន់ព្រៃអភិរក្សភ្នំក្រវាញកណ្តាលដែលគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ សហការណ៏ជាមួយអង្គការ CI និង Wildlife Alliance ផងដែរ ។ ចំពោះភូមិដែលប៉ះពាល់ដោយសារអាងទី១ (តំបន់១) មានតែ ៣ប៉ុណ្ណោះភូមិគឺ ,

- ភូមិអូរសោម
- ភូមិកណ្តាល និង
- ភូមិឆាយលូក

ស្ថានភាពប្រជារាស្ត្រនៅក្នុងខេត្តពោធិ៍តាត់ : ខេត្តពោធិសាត់ មានផ្ទៃដីសរុបចំនួន ១២.៦៩២ គ.ម[២] និង មានសណ្ឋានដីជាដីតំបន់ភ្នំ និងខ្ពស់រាប ភាគខាងលិច និងតំបន់ទំនាបភាគខាងកើតនៃផ្លូវរទេះភ្លើង ។ ខេត្តនេះមានស្រុកចំនួន ០៥ ក្រុង ០១ ឃុំចំនួន ៤៩ ភូមិចំនួន ៥០១ និងមានព្រំប្រទល់ខាងកើតទល់នឹងខេត្តកំពង់ឆ្នាំង និងបឹងទន្លេសាប. ខាងលិច ទល់ខេត្តបាត់ដំបង និងប្រទេសថៃឡង់មានខ្សែបន្ទាត់ព្រំដែនប្រមាណ៨០គម. ខាងជើងទល់នឹងបឹងទន្លេសាបប្រវែងប្រ មាណ៨០គម. ហើយនិងខាង ត្បូងទល់នឹងខេត្តកំពង់ស្ពឺ និងខេត្តកោះកុង ។ ខេត្តនេះមានប្រជាជនសរុបប្រមាណ ៤៣៥០០១ នាក់ (ទិន្នន័យឆ្នាំ ២០១១ បានពីរបាយការណ៍សន្និបាតបូកសរុបការងារគ្រប់វិស័យប្រចាំឆ្នាំ២០១០ និងទិសដៅការងារឆ្នាំ២០១១ នៃសាលាខេត្តពោធិសាត់) រួមមានប្រុសចំនួន ២១២១៥១ នាក់ និងស្រីចំនួន ២២២៨៥០នាក់ ប្រភពទិន្នន័យបាន ពីខុទ្ទកាល័យខេត្តពោធិ៍សាត់ ។ ដង់ស៊ីតេប្រជាជនមានប្រហែល ៣៣ នាក់/គ.ម[២] ។

៥.២.១.១ អំបូរជនជាតិ

យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងាររបស់ SAWAC បានឱ្យដឹងថា នៅក្នុងតំបន់គំរោងនេះមានអំបូរជនជាតិផ្សេងគ្នា គឺ ជនជាតិខ្មែរ ជនជាតិជង ជនជាតិព័រ ដូចមានចែងក្នុងតារាងលេខ ៤៤ ខាងក្រោម ។ ជនជាតិជងគឺជាជនជាតិមួយដែលកើតមកពីជនជាតិខ្មែរដើមមួយក្រុម ដែលរស់នៅក្នុងឃុំឫស្សីជ្រុំ តាទៃលើ ជនាប់ ចំណារនៃស្រុក ថ្មបាំង ខេត្តកោះកុង កាត់ពូជសាសន៏ជាមួយប្រភពខ្មែរបែកចេញពីក្រុងឧត្តុង្គ និងលង្វែកសម័យសង្គ្រាម នៅលង្វែកលើកទី២ (ឯកសារស្រាវជ្រាវ :ប្រវត្តិជន

ជាតិជងខ្នងភ្នំនៅខេត្តពោធិ៍សាត់. សហការបោះសេចក្តីព្រាងលើកទី១ដោយ: មន្ទីរវប្បធម៌ និងវិចិត្រសិល្បះ ខេត្តពោធិ៍សាត់ និង អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (COCD) ដែលឧបត្ថម្ភថវិការដោយអង្គការដែនដីមនុស្ស-អាលឺម៉ង់ (tdh-G).២០០៩។

តារាង ៤៤ : អំបូរជនជាតិដែលមាននៅក្នុងតំបន់គំរោង (សិក្សាថ្ងៃទី ១៥ កក្កដា ដល់ ៣០សីហា ២០១១)

ល.រ	ឈ្មោះភូមិ	អំបូរជនជាតិ គិតជាភាគរយ (%)						សំគាល់
		ខ្មែរ	ជង	អ៊ីស្លាម	ចិន	វៀតណាម	សរុប	
១	អូរសោម	១%	៩៦%	0	៣%	0	១00%	ស្រុកវាលវែង. ឃុំអូរសោម
២	កណ្តាល	២៦%	៧៤%	0	0	0	១00%	ស្រុកវាលវែង. ឃុំអូរសោម
៣	ឆាយលូក	២៨%	៧២%	0	0	0	១00%	ស្រុកវាលវែង. ឃុំអូរសោម

៥.២.១.២ ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គំរោង

នៅក្នុងតំបន់ គំរោងនេះមានប្រជាពលរដ្ឋ ០១ឃុំ មាន ០៣ ភូមិ ដែលរស់នៅក្នុងតំបន់គំរោង លំអិតមានចែងក្នុងតារាង៤៥ ខាងក្រោម ។

តារាង ៤៥: ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់គំរោង (សិក្សា២២/៤ ដល់ ០៩/៦/២០០៨ និង ថ្ងៃទី ១៥ កក្កដា ដល់ ៣០សីហា ២០១១)

ល.រ	ឈ្មោះភូមិ	ឃុំ	ទិន្នន័យឆ្នាំ ២០០៨			ទិន្នន័យឆ្នាំ២០១១			ប៉ែរប៉ួល (%)	សំគាល់
			គ្រួសារ	មនុស្ស	ស្ត្រី	គ្រួសារ	មនុស្ស	ស្ត្រី		
១	អូរសោម	អូរសោម ស្រុកវាលវែង	៦៣	២៥៤	១២៦	៧៤	២៩៤	១៤១	១៥%	ប្រជាពលរដ្ឋចំណូលថ្មី
២	កណ្តាល	អូរសោម ស្រុកវាលវែង	៣២	១១៥	៦២	៤៧	១៧៥	៨៦	៣២%	ប្រជាពលរដ្ឋចំណូលថ្មី
៣	ឆាយលូក	អូរសោម ស្រុកវាលវែង	៧៣	៣៣១	១៥៩	៨៩	៣៧៦	១៦៥	១៨%	ប្រជាពលរដ្ឋចំណូលថ្មី
សរុប			១៦៨	៧០០	៣៤៧	២១០	៨៤៥	៣៩២	២០%	

នៅក្នុងឆ្នាំ២០១១នេះចំនួនគ្រួសារនៃប្រជាពលរដ្ឋក្នុងឃុំអូរសោមទាំងមូលបានកើនឡើងរហូតដល់២០% (មើលតារាង៤០ខាងលើ) មូលហេតុដែលនាំអោយមានកំណើននេះដោយសារមកពី:

- ដោយសារការឈូសឆាយធ្វើផ្លូវរបស់ក្រុមហ៊ុនវិនិយោគវារីអគ្គិសនីស្ទឹងអាតៃ ដែលបង្ករលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងឃុំ និងខាងក្រៅក្នុងការធ្វើដំណើរចាប់ពីខេត្តពោធិ៍សាត់ រហូតខេត្តកោះកុងតាមរថយន្ត .ម៉ូតូ ក្នុងការដឹកជញ្ជូនផលិតផលកសិកម្មទៅកាន់ទីផ្សារជាដើម ។ល។
- លំហូរចូលនៃជនចំណូលថ្មីមកតាំងទីលំនៅដើម្បីប្រកបមុខរបរផ្សេងៗដូចជា(ចំការពោត.សណ្តែក.ល្ង.ដំឡូងមី ដោយសារ ទឹកដីនេះមានភាពអំណោយផលផ្នែកកសិកម្ម) ។
- ការបំបែកគ្រួសារថ្មីដែលទើបរៀបអាពាហ៍ពិពាហ៍ ។

៥.២.១.៣ ប្រជាជនដែលប៉ះពាល់ដោយសារគំរោងក្នុងអាងទី១

ការសាងសង់អាងទី១នៃគំរោងវារីអគ្គិសនីស្ទឹងអាតៃនេះបានធ្វើអោយប៉ះពាល់ផ្ទាល់ដល់ប្រជាពលរដ្ឋចំនួនបីភូមិ (ភូមិអូរសោម. ភូមិកណ្តាល និងភូមិឆាយលូក) មានប្រជាពលរដ្ឋប៉ះពាល់សរុបចំនួន៣៧គ្រួសារ ដែលមានមនុស្សសរុប១៤៥នាក់ ក្នុងនោះមាន៤គ្រួសារនៅភូមិឆាយលូក ដែលត្រូវផ្លាស់ប្តូរទីលំនៅទៅកាន់ទីទួលមានសុត្ថិភាពស្ថិតនៅក្នុងភូមិអូរសោម ដែលមានកំរិតនីវ៉ូលើសពី ៥២០ម ។ ចំពោះប្រជាជនដែលត្រូវប្តូរលំនៅដ្ឋាននោះមាន ដើមឈើហូបផ្លែ និង ដំណាំចំនួន១៩៩៤ ដើម/គុម្ព. ផ្ទះ០៤ខ្នង (មានផ្ទះ២ប្រភេទ). និងមានសំណង់ផ្សេងៗដូចជាទ្រុងមាន់. ជង្រុកស្រូវត្រូវប៉ះពាល់ និងរុះរើចេញពីក្នុងអាងនេះផងដែរ. ។

ជាក់ស្តែងពេលដែលក្រុមការងារSAWAC ចុះទៅធ្វើការសិក្សាផ្ទាល់ចំពោះប្រជាពលរដ្ឋដែលប៉ះពាល់ដោយគំរោងវារីអគ្គិសនីអារ៉ែងក្នុងអាងទី១នៃទំនប់ទី១មានចំនួន៣៧គ្រួសារក្នុងនោះគ្រួសារ ដែលត្រូវបានចូលរួមសំភាសន៍តែមាន៣៣គ្រួសារគឺស្មើនិង ៨៩% ប៉ុណ្ណោះ ។ ចំណែកឯគ្រួសារដែលមិនបានជួបសំភាសន៍មានចំនួន៤ គ្រួសារស្មើនិង១១% គឺដោយសារពួកគាត់រវល់ទៅធ្វើចំការនៅឆ្ងាយពីភូមិ និងស្នាក់នៅទីនោះដើម្បីប្រមូលផលដំណាំរបស់ពួកគាត់ ហើយក៏មានគ្រួសារខ្លះទៀតមានធុរះដោយមិនអាចខកខានបាន និងមិនបានមកសំភាសនផងដែរ។ ប្រជាពល រដ្ឋដែលប៉ះពាល់ ដូចមានបង្ហាញក្នុងតារាង៤៦ (ក) ដូចខាងក្រោម:

<u>តារាង ៤៦(ក)</u>: ប្រជាពលរដ្ឋដែលនឹងត្រូវប៉ះពាល់នៅក្នុងអាង(សិក្សាថ្ងៃទី ១៥ កក្កដា ដល់ ៣០សីហា ២០១១)

ល.រ	ឈ្មោះភូមិ	ចំនួនគ្រួសារ ប៉ះពាល់សរុប ក្នុងភូមិ	ចំនួនគ្រួសារសរុបក្នុងភូមិ	ភាគរយនៃការប៉ះពាល់ /ភូមិ	ចំនួនមនុស្ស /គ្រួសារ	សំគាល់
		គ្រួសារ	គ្រួសារ			
1	អូរសោម	15	74	20%	4.93	ប៉ះដីនៅក្នុងអាងទី១
2	កណ្តាល	3	47	6%	15.67	ប៉ះដីនៅក្នុងអាងទី១
3	ឆាយលូក	19	89	21%	4.68	ប៉ះដី និងផ្ទះនៅក្នុងអាងទី១
សរុប		37	210	17.6%	5.68	មធ្យមភាគមនុស្សក្នុងគ្រួសារ

<u>តារាង ៤៦(ខ)</u>: ប្រភេទផ្ទះប្រជាជនដែលនឹងត្រូវប៉ះពាល់ដោយសារគំរោង (សិក្សាថ្ងៃទី ១៥កក្កដា ដល់៣០ សីហា ២០១១)

#	ឈ្មោះភូមិ	ឈ្មោះឃុំ	ប្រភេទផ្ទះ-1C (គិតជាខ្នងផ្ទះ)	ប្រភេទផ្ទះ-2D (គិតជាខ្នងផ្ទះ)	សរុប (ផ្ទះ)	ផ្ទះ-1C (m^2)	ផ្ទះ-2 D (m^2)	សរុបផ្ទះប៉ះពាល់ (m^2)	មិនមានដី	សំគាល់
១	អូរសោម	អូរសោម	0	0	0	0.00	0.00	0.00	0	
២	កណ្តាល	អូរសោម	0	0	0	0.00	0.00	0.00	0	
៣	ឆាយលូក	អូរសោម	២	២	៤	៧៨.៤៩	៨៩.២៤	១៦៧.៧៣	៤	ត្រូវប្តូរទីតាំងថ្មី
សរុប			២	២	៤	៧៨.៤៩	៨៩ .២៤	១៦៧ .៧៣	៤	

<u>កំណត់</u>: - **ផ្ទះប្រភេទ ១** :ចែកចេញជា ៣

- (១ក): គឺផ្ទះប្រក់ ស្លឹក ឬស្បូវដែលមានជញ្ជាំងស្លឹក ឬស្បូវ គ្មានកំរាល សសរធ្វើពីឫស្សី/កូនឈើ (ជាផ្ទះផ្ទាល់ដី) ។
- (១ខ): គឺផ្ទះប្រក់ស្លឹក ឬស្បូវដែលមានជញ្ជាំងស្លឹក ឬស្បូវ ចាក់សាប សសរធ្វើពីឫស្សី/កូនឈើ (ជាផ្ទះផ្ទាល់ដី) ។
- (១គ): គឺផ្ទះប្រក់ស្លឹក ឬស្បូវដែលមានជញ្ជាំងមានគុណភាពលើស២៥% . កំរាលមានគុណភាពលើស២៥% សសរធ្វើពីឫស្សី/កូនឈើ (ជាផ្ទះផ្ទាល់ដី) ។

- **ផ្ទះប្រភេទ ២** :ចែកចេញជា ៥

- (២ក): គឺផ្ទះប្រក់សង្កសី/ហ្វីប្រូ/ប្លាស្ទិកដែលមានជញ្ជាំងស្លឹក ឬស្បូវ គ្មានកំរាល សសរធ្វើពីកូនឈើ/ឈើ (ជាផ្ទះផ្ទាល់ដី) ។
- (២ខ): គឺផ្ទះលោហះ/ហ្វីប្រូ/ប្លាស្ទិកដែលមានជញ្ជាំងសង្កសី/ហ្វីប្រូគ្មានកំរាលសសរធ្វើពីកូនឈើ/ឈើ (ជាផ្ទះផ្ទាល់ដី)
- (២គ): គឺផ្ទះលោហះ/ហ្វីប្រូ/ប្លាស្ទិកដែលមានជញ្ជាំងឈើ គ្មានកំរាល សសរធ្វើពីកូនឈើ/ឈើ (ជាផ្ទះផ្ទាល់ដី)
- (២ឃ): គឺផ្ទះលោហះ/ហ្វីប្រូ/ប្លាស្ទិកដែលមានជញ្ជាំងឈើ កំរាលឈើ/បេតុង សសរធ្វើពីឈើ(ជាផ្ទះផ្ទាល់ដី)
- (២ង): គឺផ្ទះលោហះ/ហ្វីប្រូ/ប្លាស្ទិកដែលមានជញ្ជាំងឥដ្ឋ កំរាលបេតុង សសរធ្វើពីបេតុង(ជាផ្ទះផ្ទាល់ដី)
- (២ង): គឺផ្ទះលោហះ/ហ្វីប្រូ/ប្លាស្ទិកដែលមានជញ្ជាំងឈើ/ឥដ្ឋ កំរាលឈើ/ បេតុង សសរធ្វើពីឈើ/បេតុង ច្រើនជាងពីរជាន់។

តារាង ៤៧: សង្ខេបផលប៉ះពាល់លើប្រជាពលរដ្ឋដោយសារគំរោង (សិក្សាថ្ងៃទី១៥កក្កដា ដល់៣០ សីហា ២០១១)

Qu.Number	Household Name	Affected villages	HH Age	APs Elderly	Vulnerable	Total member of families	Kitchens	Barn	Affected house (m²)		Affected Land (m²)				Income restoration	% Affected of Agri-Land	Compensation Rice Land ($US)	Compensation Chamkar Land ($US)	Compensation Bos Land ($US)	Compensation Cost for orther Structure ($US)	Compensation Cost for Prod.Tree ($US)	Compensation Cost for None Prod.Tree ($US)	Disruption Allowance ($US)	Vulnerable Group Allowance ($US)	Transportation Allowance ($US)	Income Restoration Allowance ($US)	Amount ($US)	Compensation Resdentia Land (m2)	Compensation House-2D (m2)
			HH	HH	HHs				House-2D	House-1C	Rice Land	Chamkar land	Recident Land	Bos Land															
001	សោម ឡុក	អូរសោម	74	1	1	02								22,454	0	0%	0	0	1,796.32	0	0	0	40.00	150.00	0	[illegible]	1,986.32	0	0
002	មូ ចាន់	អូរសោម	70	1	1	03								3,818	0	0%	0	0	305.44	0	0	0	40.00	150.00	0	0	495.44	0	0
003	ក្រូច ហ៊ុន	អូរសោម	70	1	1	02								1,428	0	0%	0	0	114.24	0	0	0	40.00	150.00	0	0	304.24	0	0
004	កាក់ទ្រី	អូរសោម	61	1	1	09								665	0	0%	0	0	53.20	0	0	0	40.00	150.00	0	0	243.20	0	0
005	ម៉ាក់ ផល	អូរសោម	33		0	06								1,397	0	0%	0	0	111.76	0	0	0	40.00	0.00	0	0	151.76	0	0
006	ខ្សៃវ ធី	អូរសោម	33		0	04								10,509	0	0%	0	0	840.72	0	0	0	40.00	0.00	0	0	880.72	0	0
007	ឡាង ទូញ	អូរសោម	61	1	1	02								13,969	0	0%	0	0	1,117.52	0	0	0	40.00	150.00	0	0	1307.52	0	0
008	យិន ម៉ោះ	អូរសោម	50		0	05								1,098	0	0%	0	0	87.84	0	0	0	40.00	0.00	0	0	127.84	0	0
009	លេវ លីន	អូរសោម												35,264	0		0	0	2,821.12	0	0	0	40.00	0.00	0	0	2,861.12	0	0
010	ទិត្យ ប៊ុច	អូរសោម	28		0	05								225	0	0%	0	0	18.00	0	0	0	40.00	0.00	0	0	58.00	0	0
011	ញ៉ាំង ភួង	អូរសោម	31		0	06								3,715	0	0%	0	0	297.20	0	0	0	40.00	0.00	0	0	337.20	0	0
012	ទិត្យ កែវ	អូរសោម	29		0	04								1,782	0	0%	0	0	142.56	0	0	0	40.00	0.00	0	0	182.56	0	0
013	ប៉ោយ ភី	អូរសោម	32		0	06								629	0	0%	0	0	50.32	0	0	0	40.00	0.00	0	0	90.32	0	0
014	វេត ភឿន	អូរសោម	27		0	04								663	0	0%	0	0	53.04	0	0	0	40.00	0.00	0	0	93.04	0	0
015	សឹង វេត	អូរសោម	54		0	06								204	0	0%	0	0	16.32	0	0	0	40.00	0.00	0	0	56.32	0	0
016	តិល ផង់	កណ្ដាល	26		0	02						5,321			·	29%	0	796.15	0.00	0	0	0	40.00	0.00	0	413	1,251.15	0	0
017	ចាន់ ទីក	កណ្ដាល	62	1	1	02						5,309		1,366	·	23%	0	796.35	109.28	0	0	0	40.00	150.00	0	413	1,508.63	0	0
018	ជួប ពីទី	កណ្ដាល	43		0	04						19,497			·	16%	0	2,924.55	0.00	0	0	0	40.00	0.00	0	413	3,377.55	0	0
019	ញ៉ែម កង	ឆាយលូក	47		0	08						2,280		4,684	0	4%	0	342	374.72	0	0	0	40.00	0.00	0	0	756.72	0	0
020	ប្រុក វ៉ន	ឆាយលូក	50		0	05					5,429	4,518			:	33%	814.35	677.7	0.00	0	0	0	40.00	0.00	0	413	1,945.05	0	0
021	ថុន ព្រៅ	ឆាយលូក	29		0	05						8,522			·	28%	0	1,278.3	0.00	0	0	0	40.00	0.00	0	413	1,731.30	0	0
022	វណ្ណ សាម៉ាន	ឆាយលូក	57		0	02						11,203		1,859	1	17%	0	1,680.45	146.72	0	0	0	40.00	0.00	0	413	2,282.17	0	0
023	វណៈ ឆក	ឆាយលូក	20		0	01						477			0	2%	0	71.55	0.00	0	0	0	40.00	0.00	0	0	111.55	0	0
024	អ៊ិម ភឿន	ឆាយលូក									1,359	4,868			0		203.85	730.2	0.00	0	0	0	40.00	0.00	0	0	974.05	0	0

Qu.Number	Household Name	Affected villages	HH Age	APs Elderly	Vulnerable	Total member of families	Kitchens	Barn	Affected house (m²)		Affected Land (m²)				Income restoration	% Affected of Agri-Land	Compensation Rice Land ($US)	Compensation Chamkar Land ($US)	Compensation Bos Land ($US)	Compensation Cost for orther Structure ($US)	Compensation Cost for Prod.Tree ($US)	Compensation Cost for None Prod.Tree ($US)	Disruption Allowance ($US)	Vulnerable Group Allowance ($US)	Transportation Allowance ($US)	Income Restoration Allowance ($US)	Amount ($US)	Compensation Residential Land (m2)	Compensation House-2D (m2)
			HH	HH	HHs				House-2D	House-1C	Rice Land	Chamkar land	Recident Land	Bos Land															
025	លឹម សឿម	ឆាយលូក										4,217			0		0	632.55	0.00	0	0	0	40.00	0.00	0	0	672.55	0	0
026	ញ៉ឹក បេ	ឆាយលូក	35		0	04						507			0	1%	0	76.05	0.00	0	111	540	40.00	0.00	0	0	767.05	0	0
027	ព្រំ ម៉ុយ	ឆាយលូក	43		0	07						391			0	1%	0	58.85	0.00	0	0	0	40.00	0.00	0	0	98.65	0	0
028	ករ សោភា	ឆាយលូក	47		0	03						26,962		1,4813	1	18%	0	4,044.30	1,185.04	0	0	0	40.00	0.00	0	413	5,682.34	0	0
029	វណ្ណ ផុន	ឆាយលូក	56		0	03						6,144			1	18%	0	921.60	0.00	0	0	0	40.00	0.00	0	413	1,374.60	0	0
030	វណ្ណ គេម	ឆាយលូក	28		0	03					5,477			20,623	0	9%	821.55	0	1,649.84	0	0	0	40.00	0.00	0	0	2,511.39	0	0
031	ពែក ហឿន	ឆាយលូក	51		0	09						7,539			1	13%	0	1,130.85	0.00	0	0	0	40.00	0.00	0	413	1,583.85	0	0
032	ឡុន ធី	ឆាយលូក	50		0	05						1,804			0	7%	0	270.6	0.00	0	0	0	40.00	0.00	0	0	310.60	0	0
033	កង ហៀន	ឆាយលូក	20		0	03								26,000	0	0%	0	0	2,080.00	0	0	0	40.00	0.00	0	0	2,120.00	0	0
034	ពេជ គោយ	ឆាយលូក	51		0	04	1		50.55			32,685	2,500		1	100%	0	4,902 75	0.00	30	2,863.6	538	40.00	0.00	40.00	413	8,827.35	2500	35
035	សារ៉ាយសុខ	ឆាយលូក	53		0	08	1	1		41.08		18,393	2,500		1	100%	0	2,758.95	0.00	70	1050	925.2	40.00	0.00	40.00	413	5,297.15	2500	35
036	លី ស្រីម៉ាប់	ឆាយលូក	19		0	03				37.41		6,431			1	100%	0	964.65	0.00	0	0	0	40.00	0.00	40.00	413	1,457.65	2500	35
037	កាំង កទ-សុខ គ្លិប	ឆាយលូក							38.69			9,641			1	100%	0	1,446.15	0.00	0	0	0	40.00	0.00	40.00	413	1,939.15	2500	35
Total		37		6	6	145	2	1	89.24	78.49	12,265	176,709	5,000	167,165	13	356,130	1,840	26,506	13,373	100	4,025	2,003	1,480	900	160	5,369	55,756	10,00֏	140



ផ្ទះ-1C, ម្ចាស់ឈ្មោះ: សារ៉ាយ សុគ
រូបថតថ្ងៃទី ២៥ កក្កដា ២០១១



ផ្ទះ-2D, ម្ចាស់ឈ្មោះ: ពេជ គោយ
រូបថតថ្ងៃទី ២៥ កក្កដា ២០១១



ផ្ទះ-2D, ម្ចាស់ឈ្មោះ: សុគ គ្លិប
រូបថតថ្ងៃទី ២៥ កក្កដា ២០១១



ផ្ទះ-1C, ម្ចាស់ឈ្មោះ: លី ស្រីម៉ាប់
រូបថតថ្ងៃទី ២៥ កក្កដា ២០១១

៥.២.១.៤ ការប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈដោយសារគំរោង

ក្នុងការអភិវឌ្ឍន៍គំរោងវារីអគ្គិសនីស្ទឹងអាតៃនេះក៏បានធ្វើអោយបាត់បង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈមួយចំនួនដូចជា: ផ្លូវលំគ្រួសក្រហម (ស្ថានភាពមធ្យម) ប្រវែង៤.៦៥គម ពីប្រម៉ោយទៅឃុំ អូរសោម, ដីបញ្ចុះសពនៅភូមិអូរសោមចំនួន ២.៤៥៥៨ហ.ត, ព្រៃក្រវាញរបស់សហគមន៍នៅឃុំអូរសោម ចំនួន២៧.៦១ហ.ត ដែលលិចលង់ដោយសារបិទទឹកនៅអាងទី១នេះ ។

៥.២.២ ស្ថានភាពសេដ្ឋកិច្ច-សង្គម

៥.២.២.១ អាជីព និងមុខរបរ

ក. មុខរបរសំខាន់ៗ

យោងតាមទិន្នន័យដែលបានចែងក្នុងតារាង៤៨ខាងក្រោមបង្ហាញថាមុខរបរសំខាន់ៗរបស់មេគ្រួសារនៃប្រជាពលរដ្ឋដែលបានសម្ភាសន៍ នៅក្នុងតំបន់គំរោងមានចំនួន ៧៩% ជាកសិករ ១៥%, ជាមន្ត្រីរាជការ (ជំទប់ឃុំ, មេភូមិ, ទាហ៊ាន) ,៣% ជាអ្នកលក់ដូរ , និងបុគ្គលិកក្រុមហ៊ុន ៣% ។

<u>តារាង ៤៨:</u> **មុខរបររបស់មេគ្រួសារដែលបានសម្ភាសន៍នៅក្នុងតំបន់គំរោង (សិក្សាថ្ងៃទី១៥កក្កដា ដល់៣០/សីហា/២០១១)**

ល.រ	ឈ្មោះភូមិ	មុខរបរដែលសម្ភាសន៍				ភាគរយ					ប្រជាជនដែលសម្ភាសន៍
		កសិករ	មន្ត្រីរាជការ (គ្រូ,មេភូមិ,ទាហ៊ាន)	លក់ដូរ	ក្រុមហ៊ុនឯកជន	កសិករ	មន្ត្រីរាជការ (គ្រូ,មេភូមិ, ទាហ៊ាន)	លក់ដូរ	ក្រុមហ៊ុនឯកជន	សរុប	គ្រួសារ
១	អូរសោម	១១	៣	0	0	៧៩%	២១%	0%	0%	១00%	១៤
២	កណ្តាល	២	0	0	១	៦៧%	0%	0%	៣៣%	១00%	៣
៣	ឆាយលូក	១៣	២	១	0	៨១%	១៣%	៦%	0%	១00%	១៦
សរុប		២៦	៥	១	១	៧៩%	១៥%	៣%	៣%	១00%	៣៣



ខ. មុខរបររួមផ្សំរបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោង

មុខរបររួមផ្សំផ្សេងទៀតរបស់ប្រជាពលរដ្ឋគឺ រកអនុផលព្រៃឈើ ដូចជាប្រមូលជ័រ (ជ័រចុង), បេះក្រវាញ, ផ្តៅ, នេសាទ, កាប់ឈើធ្វើអុស,ដាំដំណាំរួមផ្សំជុំវិញផ្ទះ,និងចិញ្ចឹមសត្វខ្លះទៀតស៊ីឈ្នួលដាំដំឡូងមី,កាច់ពោត,បេះសណ្តែក,ល។មុខរបរទាំងនេះមិនមែនជាមុខរបរសំខាន់ប្រចាំជីវិតទេ ពោលគឺជាមុខរបរបន្ទាប់បន្សំនៅពេលពួកគាត់ទំនេរពីការងារអាជីពប្រចាំថ្ងៃដើម្បីរកចំណូលបន្ថែមក្នុងគ្រួសារ ។

៥.២.២.២ ប្រាក់ចំណូលប្រចាំឆ្នាំ (Gross Domestic Product (GDP))

ចំណូលផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជា ប្រចាំឆ្នាំ ២០១០ គឺ US$១១.៣ កោដ ហើយចំនួនប្រជាជនមាន ១៣,៣៩៥,៦៨២លាននាក់ ដូច្នេះ GDP របស់ប្រជាជនម្នាក់ៗក្នុង ១ ឆ្នាំ គឺ US$៨៣០ per capita (ទិន្នន័យនេះដកស្រង់ចេញពីសៀវភៅស្ថិតិឆ្នាំ ២០១០ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការរបស់ប្រទេសកម្ពុជា) (http/www.nis.gov.kh) ។

យោងតាមការសិក្សា ចំពោះប្រាក់ចំណូលប្រចាំឆ្នាំក្នុងគ្រួសារនីមួយៗរបស់ប្រជាពលរដ្ឋនៅក្បែរតំបន់គំរោងមាននៅក្នុង តារាង៤៩ ខាងក្រោម ។

<u>តារាង ៤៩</u>: ប្រាក់ចំណូលប្រចាំឆ្នាំរបស់គ្រួសារអ្នកដែលបានសម្ភាសន៍ក្នុងតំបន់គំរោង (សិក្សាថ្ងៃទី១៥កក្កដា ដល់៣០/សីហា/២០១១)

ល.រ	ឈ្មោះភូមិ	ប្រាក់ចំណូលរបស់មេគ្រួសារដែលបានសម្ភាសន៍ក្នុងតំបន់គំរោង									
		$១៥-១០០	%	$១០១-៣០០	%	$៣០១-៥០០	%	$៥០១-១០០០	%	>១០០១	%
1	អូរសោម	៤	២៩%	៧	៥០%	២	១៤%	១	៧%	០	០
2	កណ្ដាល	១	៣៣%	១	៣៣%	០	០	១	៣៣%	០	០
3	ឆាយលូក	៤	២៥%	១១	៦៩%	០	០	០	០	១	៦%
សរុប		៩	២៧%	១៩	៥៨%	៣	៦%	២	៦%	១	៣%



យោងតាមតារាង៤៩ ខាងលើនេះបានបង្ហាញថាប្រាក់ចំណូលប្រចាំគ្រួសារក្នុងមួយឆ្នាំនៅក្នុងភូមិទាំង០៣ មានកំរិតចាប់ពី $១៥-$១០០ មាន ២៧% , ពី $១០១-$៣០០ មាន ៥៨% ,ពី $៣០១-$៥០០ មាន ៦%, ពី $៥០១-$១០០០ មាន ៦% និងចាប់ពី $១០០១ឡើងទៅមានតែ ៣ % ប៉ុណ្ណោះ ។

កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់គំរោងគឺប្រាក់ចំណូលមធ្យមម្នាក់ៗមាន ៦៤៧.៩៦ ដុល្លាអាមេរិក ទាបជាងប្រាក់ចំណូលផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសកម្ពុជា គឺ ៨៣០ ដុល្លាអាមេរិក ឆ្នាំ ២០១១ ក្នុងម្នាក់ ក្នុងមួយឆ្នាំ មើលតារាងលេខ ៥០(ក) ខាងក្រោម ។

តារាង ៥០(ក): ប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងតំបន់គំរោងដែលបានសម្ភាសន៍
(សិក្សាថ្ងៃទី ១៥កក្កដា ដល់៣០ សីហា ២០១១)

ប្រាក់ចំណូលសរុបរបស់ប្រជាជនក្នុងភូមិដែលបានសម្ភាស	ចំនួនគ្រួសារដែលបានសម្ភាសន៍	ចំនួនមនុស្សក្នុងមួយគ្រួសា	ចំនួនមនុស្សនៃ គ្រួសារដែលបានសម្ភាសន៍	ចំនួនប្រជាជនអាយុ១៨ឡើង	ប្រាក់ចំណូលជាមធ្យមតាមគ្រួសារ	ប្រាក់ចំណូលម្នាក់ៗក្នុងមួយឆ្នាំ
៩៣៩៥៣ .៤៩ ដុល្លា	៣៣ គ្រួសារ	៤.៣៩ នាក់	១៤៥ នាក់	១៣៦ នាក់	២៨៤៧.០៨ ដុល្លា	៦៤៧.៩៦ ដុល្លា

តារាង ៥០(ខ): ប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់ៗ ក្នុងតំបន់គំរោងដែលបានសម្ភាសន៍
(សិក្សាថ្ងៃទី ២២ មេសា ដល់ ០៩ ឧសភា ២០០៨)

ប្រាក់ចំណូលសរុបរបស់ប្រជាជនក្នុងភូមិដែលបានសម្ភាសន៍	ចំនួនគ្រួសារដែលបានសម្ភាសន៍	ចំនួនមនុស្សក្នុងមួយគ្រួសារ	ចំនួនមនុស្សនៃគ្រួសារដែលបានសម្ភាសន៍	ចំនួនប្រជាជនអាយុ១៨ឡើង	ប្រាក់ចំណូលជាមធ្យមតាមគ្រួសា	ប្រាក់ចំណូលម្នាក់ៗក្នុងមួយឆ្នាំ
៤១៥១៦ ដុល្លា	៣៥ គ្រួសារ	៥.០៦ នាក់	១៧៧ នាក់	៩០ នាក់	១១៤៦ .៤០ ដុល្លា	២២៦.៦៩ ដុល្លា

យោងតាមតារាង ៥០(ក និង ខ) បញ្ជាក់ថាប្រាក់ចំណូលសរុបមធ្យមប្រចាំឆ្នាំរបស់មនុស្សម្នាក់ៗ នៅក្នុងតំបន់គំរោងមានការកើនឡើងច្រើនពី ២២៦.៦៩ ដុល្លា ដល់ ៦៤៧.៩៦ ដុល្លារអាមេរិក (កើន ៤២១.២៧ ដុល្លា ស្មើ៣៥%) មើលតារាង៥០(គ) ខាងក្រោម ។

តារាង ៥០(គ): ប្រៀបធៀបប្រាក់ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់ៗក្នុងតំបន់គំរោង(ចាប់ពីឆ្នាំ២០០៨ ២០១១)

ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋម្នាក់ៗក្នុងមួយឆ្នាំ	២០០៨	២០១១	កំណើនគិតជា (%)
	២២៦.៦៩ ដុល្លា	៦៤៧.៩៦ ដុល្លា	៣៥%

កត្តាដែលនាំអោយមានកំណើនប្រាក់ចំណូលគឺ:

- ការវិនិយោគរបស់ក្រុនហ៊ុនC.H.D ដោយជ្រើសរើសប្រជាពលរដ្ឋរស់នៅក្នុងតំបន់គំរោងធ្វើជាកម្មករ
- ការដេញថ្លៃសំអាតអាងរបស់ក្រុនហ៊ុន MDS ដូច្នេះពួកគាត់មានឱកាសបានការងារ និងរកប្រាក់ចំណូល ។
- ការឈូសឆាយផ្លូវចាប់ពីប្រម៉ោយមកដល់ឃុំអូរសោមដែលបង្ករលក្ខណៈងាយស្រួលសំរាប់ការដឹកផលិតផលដំណាំកសិកម្មដូចជា(ពោតប្រហម.សណ្តែក.ល្ង.....)របស់ពួកគាត់ទៅកាន់ទីផ្សារនៅប្រម៉ោយវិទីរួមខេត្តពោធិ៍សាត់ និងឆ្ពោះទៅកាន់ ខេត្តកោះកុង រឺក៏មានឈ្មួញចូលមកទិញផលិតផលរបស់ពួកគាត់ដល់ទីកន្លែងតែម្តង ។
- ផលចំណេញពីការជួញដូរអនុផលព្រៃឈើ ។

៥.២.៣ ការប្រើប្រាស់ដី និងកាន់កាប់ដីដោយប្រជាជន (Land Use and Land Occupation)

យោងតាមការចុះសិក្សាដោយផ្ទាល់នៅតំបន់គំរោងគិតចាប់ពីអាងទី១នៅឃុំអូរសោម (មើលផែនទី២) បានបង្ហាញឱ្យឃើញថាដីដែលបានប្រើប្រាស់ដោយប្រជាពលរដ្ឋសរុបមានចំនួនប្រមាណ ៤១.៤៣ ហិកតា (ដីកសិកម្ម . ដីបុស្ស . ដីលំនៅ ដ្ឋាន. ដីកប់សាកសព)ដែលប៉ះពាល់ដោយសារគំរោង ចំណែកឯនៅក្នុងអាងទី២ និងកន្លែងសាងសង់ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គិសនីគឺមិនមាន ដីកាន់កាប់ដោយប្រជាពលរដ្ឋទេ។ ចំពោះដីដែលកាន់កាប់ដោយប្រជាជនទាំងនេះគឺ មានការអនុញ្ញាតិពីថ្នាក់ភូមិឬឃុំក៏ប៉ុន្តែប្រជាជនទាំងអស់នោះមិនមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលចេញដោយអគ្គនាយកសុរិយោដី និងភូមិសាស្ត្ររបស់ក្រសួងរៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដីនៅឡើយទេ។ យោងតាមច្បាប់ភូមិបាលមាត្រាលេខ ៥ និង ៣០ ក្នុងជំពូក៣ខាងលើក្នុងទំព័រ ២៩ ប្រជាពលរដ្ឋដែលជាម្ចាស់ដីទាំងនេះត្រូវបានការពារដោយច្បាប់ភូមិបាលនេះ។ ក៏ប៉ុន្តែប្រជាពលរដ្ឋដែលរស់នៅក្នុងគំរោងនេះជាកន្លែងអភិរក្សដែលការពារដោយរដ្ឋបាលព្រៃឈើសហការជាមួយអង្គការអភិរក្សអន្តរជាតិCI និងដែនជំរកសត្វព្រៃភ្នំសំកុសរបស់ក្រសួងបរិស្ថាន។

តារាង ៥១: ការប្រើប្រាស់ដីនៅតំបន់គំរោង (សិក្សាថ្ងៃទី១៥កក្កដា ដល់៣០/សីហា/២០១១)

#	Type of Land Use	Unit	Amount
1	Evergreen Forest	ha	3889.12
2	Semi-evergreen Forest	ha	119.8
3	Mixed Bamboo	ha	70.44
4	Wood and Shrub Land Evergreen	ha	110.65
5	Evergreen Forest (none clearing)	ha	365.6
6	Mixed Bamboo (none clearing)	ha	119.56
7	Grassland	ha	241.86
8	Pond/Lake/River	ha	96.33
9	Road	ha	43.88
	sub total (1)		**5057.24**
10	O Saom Village Burial Land	ha	2.46
11	Chamkar Land	ha	16.7
12	Residential Land	ha	0.5
13	Upland Rice Field	ha	1.23
14	Bos Land	ha	20.54
	sub total (2)		**41.43**
	Grand Total		5098.67

៥.២.៤ ការផ្គត់ផ្គង់ទឹកស្អាត និង អនាម័យ (Water Supply and Sanitation)

យោងតាមការសម្ភាសន៍ផ្ទាល់របស់ក្រុមការងារ SAWAC អំពីការផ្គត់ផ្គង់ទឹក និងអនាម័យនៅក្នុងតំបន់គំរោងបានបង្ហាញថាប្រជាពលរដ្ឋនៅក្នុងតំបន់គំរោងពុំមានប្រព័ន្ធទឹកស្អាតសំរាប់ផ្គត់ផ្គង់ប្រើប្រាស់ទេ។ ប្រភពទឹកដែលប្រជាពលរដ្ឋទាំងបីភូមិយកមកប្រើប្រាស់មានដូចតទៅ : ទឹកស្ទឹង អូរ ៣៩.៣៩% . បឹង.ស្រះ.ត្រពាំង ១៨.១៨ % អណ្តូងជីក និង អណ្តូងលូ ៧៥.៧៦% . ទឹកភ្លៀង ១០០%។ ចំពោះផ្នែកអនាម័យប្រជាពលរដ្ឋភាគច្រើនគ្មានបង្គន់ប្រើបាស់ទេ ពួកគាត់បន្ទោរបង់តាមទីវាល/ជីកដីកប់ រឺក្នុងព្រៃ មានតែ២១%ប៉ុណ្ណោះដែលមានបង្គន់អនាម័យប្រើ ចំពោះអនាម័យផ្នែកសំរាមនៅតាមភូមិពួកគេគរចោលរួចដុតទៅតាមផ្ទះ នីមួយៗ តែមានកន្លែងខ្លះការបោះសំរាមគ្មានសណ្តាប់ធ្នាប់ជាពិសេសកន្លែងលក់ដូរ ការយល់ដឹងពីបញ្ហាថែរក្សាសុខភាព អនាម័យនៅមានកំរិតនៅឡើយ ។ តារាង៣២ខាងក្រោមនេះបង្ហាញអំពីការ ផ្គត់ផ្គង់ទឹក និងការប្រើប្រាសបង្គន់របស់អ្នកភូមិក្នុងតំបន់:

តារាង ៥២: ការផ្គត់ផ្គង់ទឹក និងអនាម័យនៅជុំវិញ និងក្នុងតំបន់គំរោង (គិតជាគ្រួសារអ្នកបានសម្ភាសន៍)

ល.រ	ឈ្មោះភូមិ	ចំ.គ្រួសរុប ដែលបានសម្ភាសន៍	ទឹកស្ទឹង. អូរ.	បឹង/ស្រះ /ត្រពាំង	អណ្តូងជីក. អណ្តូងលូ	ទឹកភ្លៀង	មានបង្គន់ ប្រើប្រាស់	សំគាល់
1	អូរសោម	១៤	៥	១	១៤	១៣	៣	
2	កណ្តាល	៣	០	៣	០	៣	១	
3	ឆាយលូក	១៦	៨	២	១១	១៦	៣	
សរុប		៣៣	១៣	៦	**២៥**	**៣២**	**៧**	

សំគាល់: ក្នុងមួយគ្រួសារអាចប្រើប្រាស់ប្រភពទឹក ២ ឬ ៣ ។

តារាង ៥៣: ការប្រើប្រាស់បង្គន់អនាម័យក្នុងតំបន់គំរោង (គិតជាគ្រួសារអ្នកបានសម្ភាសន៍)

ល.រ	ឈ្មោះភូមិ	ចំ.គ្រួសរុប ដែលបានសម្ភាសន៍	មានបង្គន់ប្រើ	ភាគរយ	គ្មានបង្គន់ប្រើ	ភាគរយ
1	អូរសោម	១៤	៣	២១.៤៣%	១១	៧៨.៥៧%
2	កណ្ដាល	៣	១	៣៣.៣៣%	២	៦៦.៦៧%
3	ឆាយលូក	១៦	៣	១៨.៧៥%	១៣	៨១.២៥%
សរុប		**៣៣**	**៧**	**២១%**	**២៦**	**៧៩%**





៥.២.៥ ការប្រើប្រាស់ថាមពល

៥.២.៥.១ ថាមពលសំរាប់ចំអិន និង ថាមពលសំរាប់បំភ្លឺ

យោងតាមការសម្ភាសន៍ផ្ទាល់របស់ក្រុមការងារ SAWAC អំពីការប្រើប្រាស់ថាមពលគឺមានថាមពលសំរាប់ចំអិន និងថាមពលសំរាប់បំភ្លឺ ។នៅក្នុងតំបន់គំរោងបានបង្ហាញ ថា អំពីប្រភពថាមពលសំរាប់ចំអិនដែលយកមកប្រើប្រាស់មានដូចតទៅៈ អុស/ធ្យូង ១00% . ចង្ក្រានហ្គាស ៣ %។ នៅក្នុងតំបន់គំរោងមិនមានបណ្តាញអគ្គិសនីសំរាប់ប្រើប្រាស់ទេ ដូច្នេះការប្រើប្រាស់ថាមពលសំរាប់បំភ្លឺភាគច្រើនគឺប្រើចង្កៀងដុតម៉ាហ្សូត និងទៀនគឺមាន ៩៣.៩៤ %. អាគុយ ៣.0៣ %. និង ម៉ាស៊ីនភ្លើង ៦.0៣% ។





៥.២.៦ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ (Road Network)

ទីតាំងគំរោងស្ថិតនៅចំងាយប្រមាណ ១៦៨ គ.ម ភាគនិរតីនៃទីរួមខេត្តពោធិសាត់ ហើយមានចំងាយប្រមាណ ៨៦គ.ម ខាងត្បូងនៃទីរួមខេត្តកោះកុង (គិតដល់ទីតាំងការិយាល័យក្រុមហ៊ុននៅទំនប់ទី២)។ ចំពោះការធ្វើដំណើរទៅកាន់តំបន់គំរោងមានដូចតទៅ :

- គេអាចធ្វើដំណើរតាមផ្លូវលេខ៥៥ ដោយគិតចាប់ផ្លូវបំបែកចេញពីផ្លូវជាតិលេខ៥(ទីរួមខេត្តពោធិ៍សាត់) ឆ្ពោះទៅកាន់ទីរួមស្រុកក្រវាញជាប្រភេទផ្លូវកៅស៊ូ ដល់ទីរួមស្រុកក្រវាញត្រង់ស្ពានឆ្លងស្ទឹងពោធិ៍សាត់សម្តេចតេជោ ហ៊ុន សែនមានចំងាយ ៣១ គ.ម។ បន្ទាប់មកបន្តដំណើរចាប់ពីត្រើយម្ខាងនៃស្ពានឆ្លង ស្ទឹងពោធិ៍សាត់នៅ លើកំណាត់ផ្លូវលេខ៥៥នេះដែលជាប្រភេទផ្លូវក្រាលគ្រួសក្រហមស្ថានភាពក្រហេងក្រហូងលំបាកបន្តិច ក្នុងការធ្វើដំណើររហូតដល់ចំនុចវត្តទួលគ្រោះ ហើយចាប់ពីចំនុចវត្តទួលគ្រោះរហូតដល់រង្វង់មូល ទីរួមស្រុកវាលវែង(ស្ថានភាពផ្លូវក្រាលគ្រួសក្រហមល្អ) មានចំងាយប្រមាណ ៨២ គ.មបន្តធ្វើដំណើរបត់ទៅខាងឆ្វេងតាមផ្លូវលំគ្រួសក្រហម(មានសភាព លំបាកធ្វើដំណើរនៅរដូវវស្សា)កាត់តាមភូមិប្រម៉ោយ.ភូមិថ្មីកជ្រុំ.ភូមិឈើទាលជ្រុំស្ថិតនៅក្នុងឃុំប្រម៉ោយ រួច បន្តពីព្រំប្រទល់រវាងឃុំប្រម៉ោយ និងឃុំអូរសោមត្រង់ម្តុំថ្មធំហៅ ទឹករវេរ អូរក្រញូង ភ្នំឆ្អែតដាច់ ខ្ទងស្រល់ (ឡើងភ្នំ ចុះចំណោត) អូរតាកង អូធ្លាយ អង្រុត វាលមាត់ព្រះ អូរក្របីងាប់ ស្ទឹងតាកង(ជិះក្បូនទូកឆ្លងនៅរដូវវស្សាពេលមានភ្លៀងខ្លាំង) ស្ទឹងភ្នុក ភូមិឆាយលូក (មានរូបសំណាកលោកតាសោម) ដល់ឃុំអូរសោម ចំងាយប្រមាណ ៤៥ គ.ម រួចហើយបត់ស្តាំតាមផ្លូវលំត្រង់ផ្លូវបំបែកមុខប៉ុស្តិ៍ត្រួតពិនិត្យរបស់ CI ជាផ្លូវលំមិនក្រាលគ្រួសក្រហម (ពិបាកធ្វើដំណើរក្នុងរដូវវស្សា) ដោយឆ្លងកាត់ស្ទឹងឆាយលូកគ្មានស្ពានឆ្លងទេសព្វថ្ងៃនេះ (តុលា ឆ្នាំ២០១១) ទើបបន្តដំណើរទៅមុខទៀត ដោយឆ្លងកាត់ផ្លូវដីលំបាក ប្រមាណ ជា២គ.ម (ដែលមានក្រលុកជ្រៅហើយរអិលជាប់ផុងទៀតផងនៅរដូវវស្សា)មក ដល់អនុស្ថានីយ៍អូរសោមមានប្រវែង ៥គ.ម។ ក្រុមហ៊ុន C.H.D (Cambodia) Co.,Ltd បានសាងសង់ផ្លូវថ្មីមួយខ្សែទៀតភ្ជាប់ពីអនុស្ថានីយ៍អូរសោមមកទំនប់ទី១ជាប្រភេទផ្លូវគ្រួសក្រហមដែលមានប្រវែងប្រមាណ ៦គ.ម និងផ្លូវភ្ជាប់បន្តមកទំនប់ទី២ មានប្រវែង ៨គ.ម ជាប្រភេទផ្លូវគ្រួសក្រហម ដូចគ្នាទើបដល់ការិយាល័យក្រុមហ៊ុននៅការដ្ឋាននៅទំនប់ទី២។ ទទឹមគ្នានេះដែរ ក្រុមហ៊ុន បានសាងសង់ផ្លូវថ្មីត្រង់ចំនុចអូរក្របីងាប់មកទំនប់ទី១មានប្រវែង១៥.២៤គ.ម ដែលក្រុមការងារឱ្យឈ្មោះថាផ្លូវអូរក្របីងាប់។ សរុបផ្លូវចូលទៅកាន់ការិយាល័យ របស់ក្រុមហ៊ុននៅការដ្ឋានត្រង់ទំនប់ទី២ គិតពីផ្លូវបំបែកផ្លូវជាតិលេខ ៥ ក្រវាញមានចំងាយសរុបប្រមាណ១៦៨គ.ម ។
- គេក៏អាចធ្វើដំណើរចូលទៅកាន់តំបន់គំរោងតាមផ្លូវមួយខ្សែទៀត កាត់តាមក្រុងខេមរៈភូមិន្ទតឹចុះពីទីរួម ខេត្តកោះកុងមក តាមផ្លូវជាតិលេខ៤៨ (ចាស់)ដល់ផ្លូវបំបែកផ្លូវ១៤៨ជាប្រភេទផ្លូវបេតុង និងកៅស៊ូខ្លះមានប្រវែង ៥ គ.ម រួចបន្តចុះមកផ្លូវគ្រួសក្រហម ដល់ប៉ុស្តិ៍ត្រួតពិនិត្យកោះកុងមានប្រវែង ១៨.៣៨គ.ម។ ក្រុមហ៊ុនវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោមបានស្តារពង្រីកផ្លូវចូលទៅបន្ទាយទាហ៊ានចាស់ដោយភ្ជាប់ពីប៉ុស្តិ៍ត្រួតពិនិត្យខាងលើដល់ចំណុចដំណាក់ក្បូនជាប្រភេទផ្លូវគ្រួសក្រហមមានប្រវែង ២០.៥៧គ.ម រួចបត់ស្តាំតាមផ្លូវគ្រួសក្រហមស្តារឡើងវិញដោយឡើងភ្នំចុះចំណោទ ចំងាយ ៧.៣៥ គ.ម ដល់ផ្លូវបំបែកចូលទៅក្រុមហ៊ុនវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម ហើយបត់ឆ្វេងតាមផ្លូវស្តារឡើងវិញផង និងធ្វើថ្មីផងចំងាយប្រមាណ ២១.៥១ គ.ម ដល់ចំណុចត្រួតពិនិត្យឫស្សី ជ្រុំរួចបន្តឆ្លងស្ពានដែករបស់ក្រុមហ៊ុន CHD តាមផ្លូវធ្វើថ្មីចំងាយ ១៣.១៩ គ.ម ដល់ការិយាល័យការដ្ឋានក្រុមហ៊ុន នៅទំនប់ទី២។ សរុបផ្លូវចូលតាមក្រុងខេមរៈភូមិន្ទដល់ការិយាល័យការដ្ឋានក្រុមហ៊ុននៅទំនប់ទី២ ចំងាយ ៨៦ គ.ម ។

<u>សំគាល់:</u> ក្រុមហ៊ុន CHD សំរេចប្រើប្រាស់ផ្លូវពីកោះកុងមកការដ្ឋានរបស់ខ្លួន ដោយមានការថែទាំជាប្រចាំដើម្បីដឹកជញ្ជូនសម្ភារៈសំណង់ និងសម្ភារៈធុនតូចៗ។

ផ្លូវលំពីឃុំអូរសោមប្រមោយត្រង់ចំនុចអូរក្របីងាប់
ដែលត្រូវលិចនៅក្នុងអាងទី១
រូបថតថ្ងៃទី ១៣ កក្កដា ២០១១



ផ្លូវលំគ្រួសក្រហមចាប់ពីចំនុចប៉ុស្តិ៍យាមផ្លូវចូលគំរោងវារីអគ្គិសនីស្ទឹងឫស្សីជ្រុំ
រហូតដល់អគារថាមពលទី២របស់គំរោងអាតៃ ។
រូបថតថ្ងៃទី ១៥ កក្កដា ២០១១

ផ្លូវលំគ្រួសក្រហមត្រង់ចំនុចកិនថ្មរបស់គំរោងវារីអគ្គិសនីអាតៃ
រូបថតថ្ងៃទី ១៥ កក្កដា ២០១១

៥.២.៧ វិស័យអប់រំ និងសិក្សាធិការ (Education)

តាមការសិក្សា និងធ្វើការសម្ភាន៍ជាមួយអាជ្ញាធរភូមិ ឃុំ និងប្រជាពលរដ្ឋនៅជុំវិញ និងក្នុងតំបន់គំរោងបានរកឃើញថា មានសាលាបឋម សិក្សា០១កន្លែងមាន ០២ ខ្នង ដែលមាន ០៦ បន្ទប់ ចំនួនសិស្ស ១៤៨ នាក់ ក្នុងនោះស្រី ៥៦នាក់ និងគ្រូ ០៤ នាក់។ (មើលតារាងខាងក្រោម) ។ តាមតារាងនេះបានបង្ហាញថា នៅសាលាបឋមសិក្សា គ្រូម្នាក់បង្រៀនសិស្សជាមធ្យម ៣៧ នាក់ ហើយនៅក្នុងឃុំអូរសោមមិនមានអនុវិទ្យាល័យទេប្រសិនបើចង់បន្តការសិក្សានៅអនុវិទ្យាល័យវិទ្យាល័យពួកគេត្រូវទៅរៀននៅប្រមោយ ។ ចំពោះកំរិតនៃការសិក្សារៀនសូត្ររបស់អ្នកភូមិមានកំរិតទាបនៅឡើយ ។ តាមតារាងខាងក្រោមនេះបានបង្ហាញថាមេគ្រួសារដែលបានសម្ភាសន៍ចំនួន ៣៣ គ្រួសារ ក្នុងនោះមានមេគ្រួសារ ជាបុរសចំនួន ១៥ នាក់ និង ស្ត្រីដែលជាមេគ្រួសារចំនួន ៧នាក់ដែលចេះអាន និងសរសេរអក្សរខ្មែរ (កំរិតវប្បធម៌ត្រឹមថ្នាក់ទី ៣ ដល់ ទី ៥) ។ បើគិតជាភាគ រយមានមេគ្រួសារ ៦៧%ជាអ្នកចេះអាន និងសរសេរអក្សរខ្មែរនៃចំនួនគ្រួសារសរុបដែលបានសម្ភាសន៍ទាំង ០៣ភូមិ ។ ចំពោះមេគ្រួសារដែលមិនចេះអាន និងសរសេរអក្សរខ្មែរជាបុរសមានចំនួន០៤ នាក់ និងស្ត្រី ០៧ នាក់ ។ បើគិតជាភាគរយមានមេគ្រួសារ៣៣ % ដែលមិនចេះអាន និងសរសេរអក្សរខ្មែរ ។

តារាង ៥៤: ស្ថិតិសាលាបឋមសិក្សានៅក្នុងតំបន់គំរោង (សិក្សាថ្ងៃទី១៥កក្កដា ដល់៣០/សីហា/២០១១)

ល.រ	ឈ្មោះសាលា	ភូមិ	ឃុំ	ស្រុក	ចំនួនខ្នង	ចំនួនបន្ទប់	ចំនួនគ្រូ		ចំនួនសិស្ស	
							សរុប	ស្រី	សរុប	ស្រី
1	អូរសោម	អូរសោម	អូរសោម	វាលវែង	២	៦	៤	0	១៤៨	៥៦
សរុប					**២**	**៦**	៤	0	**១៤៨**	**៥៦**



សាលាបឋមសិក្សា អូរសោម ស្ថិតនៅក្នុងឃុំអូរសោម ស្រុកវាលវែង
រូបថតនៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១១

៥.២.៤ សុខភាព និងសុខមាលភាពសាធារណៈ (Health and Health Education)

យោងតាមការសិក្សាអង្កេតរបស់ក្រុមការងារ SAWAC បានឱ្យដឹងថានៅក្នុងតំបន់គំរោងក្នុងឃុំអូរសោម គ្មានមណ្ឌលសុខភាពទេ គឺមានតែប៉ុស្តិ៍សុខភាពមួយ និងមានគ្រូពេទ្យកំរិតទាប ១នាក់ និងតូបលក់ថ្នាំពេទ្យ ១កន្លែងប៉ុណ្ណោះ ។ សូមបញ្ជាក់ថាប៉ុស្តិ៍សុខភាពគឺស្ថិតនៅជាមួយសាលាឃុំអូរសោមដោយខ័ណចែកមួយបន្ទប់ ហើយមិនមានថ្នាំសង្កូវគ្រប់គ្រាន់ទេ។ ពេលអ្នកភូមិមានជំងឺភាគច្រើនពួកគាត់ទៅមណ្ឌលសុខភាពប្រម៉ោយទីរួមស្រុកវាលវែងដែលមានចំងាយប្រមាណ ៤៥គ.ម.។ បើប្រៀបធៀបកាលពីឆ្នាំ ២០០៨ (ការធ្វើដំណើរជួបការលំបាកច្រើនដោយត្រូវឆ្លងកាត់ដងអូរតូចធំ ឡើង ចុះចំណោតនិងរអិលខ្លាំងនៅរដូវវស្សា មិនមានរថយន្តចេញចូលដូចសព្វថ្ងៃទេ ពោលគឺគេអាចធ្វើដំណើរដោយម៉ូតូត្រូវចំណាយអស់សាហ៊ុយច្រើន បើមានអ្នកជំងឺឈឺធ្ងន់ធរពួកគាត់ ត្រូវចំណាយពេលពី ៣ ម៉ ទៅ ៤ម៉ោងទើបអាចធ្វើដំណើរមកដល់ប្រម៉ោយ) តែបច្ចុប្បន្ននេះស្ថានភាពផ្លូវគឺមានភាពងាយស្រួល ច្រើនជាងមុនដោយចំណាយពេលតែ១ម៉ទៅ២ម៉ោងប៉ុណ្ណោះក្នុងការធ្វើដំណើរដោយរថយន្តតូចរឺម៉ូតូ។ ក្នុងករណីពួកគាត់មានជម្ងឺធ្ងន់ធ្ងរត្រូវបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យបង្អែកខេត្តពោធិសាត់ចំងាយមធ្យមប្រមាណ១៦០គ.ម.ពីភូមិ រឺក៏ទៅព្យាបាលនៅពេទ្យ បង្អែកខេត្តកោះកុងក៏បាន ចំងាយប្រមាណ ១០៣ គ.មពីអូរសោមដែលមានផ្លូវល្អជាងទៅពោធិ៍សាត់ (ពិបាកខ្លាំង ចំងាយ ២គ.ម ម្តុំស្ទឹងឆាយលូក ឃុំអូរសោម) ។

យោងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមការងារ SAWAC បានរកឃើញថា សុខភាពរបស់ប្រជាពលរដ្ឋទាំង០៣ ភូមិភាគច្រើនអ្នកភូមិក្នុងតំបន់នេះ ច្រើនតែកើតមានជំងឺគ្រុនចាញ់ប្រមាណ ៦៦.៦៧% និងជំងឺកើតឡើងដោយសារទឹកដូចជា រាគ ៦៦.៦៧% . គ្រុនពោះវៀន ៦៣.៦៤%. សើស្បែក៣០.៣០% . គ្រុនឈាម ៩.០៩% . និងគ្រុនក្តៅសន្លំ ២៧.២៧% ។

<u>បញ្ជាក់</u> : មួយគ្រួសារអាចកើតជំងឺ ២ ទៅ ៣ករណី ។

ក្រាហ្វិកនៃជំងឺសំខាន់ៗរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់គំរោង

សិក្សាចាប់ពីថ្ងៃទី ១៥ កក្កដា ដល់ ៣០ សីហា ២០១១



<u>តារាង ៥៥(ក)</u>: ប្រភេទជំងឺសំខាន់ៗដែលកើតនៅក្នុងតំបន់គំរោងនៅពេលសាងសង់
(សិក្សាថ្ងៃទី១៥កក្កដា ដល់៣០ សីហា ២០១១)

ឆ្នាំ ២០១១						
គ្រុនចាញ់	គ្រុនឈាម	គ្រុនសន្និ	អាសន្នរោគ	រាគ	គ្រុនពោះវៀន	[illegible]
66.67%	9.09%	27.27%	0.00%	66.67%	63.64%	[illegible]

<u>តារាង ៥៥(ខ)</u>: ប្រភេទជំងឺសំខាន់ៗដែលកើតនៅក្នុងតំបន់គម្រោងនៅពេលមុនសាង[illegible]
(សិក្សាថ្ងៃទី ២២ មេសា ដល់ ០៩ ឧសភា ២០០៨)

ឆ្នាំ ២០០៨						
គ្រុនចាញ់	គ្រុនឈាម	គ្រុនសន្និ	អាសន្នរោគ	រាគ	គ្រុនពោះវៀន	[illegible]
52.78%	5.56%	75%	16.67%	86.11%	69.44%	[illegible]

យោងតាមតារាង (៥៥ ក. ខ) បានបញ្ជាក់ថានៅក្នុងឆ្នាំ២០១១នេះប្រជាពលរដ្ឋក្នុង[illegible]ច្រើនកើតជំងឺគ្រុនចាញ់គឺកើនឡើង ១៤ %, ជំងឺគ្រុនឈាមកើនឡើង៣.៥% ។ ចំពោះជំងឺផ្សេងៗទៀតគឺមានតួលេខប្រហាក់ប្រហែល[illegible] ខុសគ្នាតិចតួច ។



ប៉ុស្តិ៍សុខភាពឃុំអូរសោមនៅក្នុងសាលាឃុំអូរសោម
រូបថតនៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០១១

៥.២.៩ ជំនឿសាសនា និងវប្បធម៌របស់ប្រជាពលរដ្ឋ

៥.២.៩.១ ជំនឿសាសនា

តាមការសិក្សា និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅក្បែរតំបន់គំរោងបានឱ្យដឹងថា មានវត្ត ០១ ចំនួនព្រះសង្ឃ ០៣ អង្គ ភិក្ខុ០២អង្គ និងសាមណេរ០១ អង្គ។ នៅក្នុងឃុំអូរសោមមិនមានវិហារកាតូលិក ឬវិហារអ៊ីស្លាមទេ។ សូមមើលតារាង ៥១ ខាងក្រោម។ ចំពោះអ្នកកាន់សាសនានៅក្នុងតំបន់គំរោងគឺព្រះពុទ្ធសាសនា ១០០%។ ប្រពៃណីវប្បធម៌របស់ប្រជាពលរដ្ឋក្នុងតំបន់គំរោងគឺមានលក្ខណៈជាតិខ្មែរទាំងស្រុងទោះបីមានជនជាតិជងរស់នៅលាយជាមួយខ្មែរក៏ដោយ។

តារាង ៥៦: ចំនួនវត្តដែលមាននៅក្នុងតំបន់គំរោង (សិក្សាថ្ងៃទី១៥កក្កដា ដល់៣០/សីហា/២០១១)

ល.រ	ឈ្មោះវត្ត	ហៅក្រៅ	ភូមិ	ឃុំ	ស្រុក	ចំនួនព្រះសង្ឃ			ផ្សេងៗ
						ភិក្ខុ	សាមណេរ	សរុប	
1	លម្ពីនីវិសាលវ័នណារាម	អូរសោម	អូរសោម	អូរសោម	វាលវែង	២	១	៣	

វត្តអូរសោមហៅថា លម្ពីនីវិសាលវ័នណារាម ស្ថិតនៅក្នុងឃុំអូរសោម
ស្រុកវាលវែង រូបថតតនៅថ្ងៃទី ១៧ ខែ កក្កដា ២០១១

៥.២.៩.២ សម្បត្តិវប្បធម៌

យោងតាមក្រុមសិក្សារបស់ក្រុមការងារ SAWAC បានឱ្យដឹងថានៅក្បែរនិងក្នុងតំបន់គំរោងនោះពុំមានសំណង់ប្រវត្តិសាស្ត្រ ឬប្រាសាទបុរាណទេ ទាំងតំបន់១ (ក្នុងអាងទី១ និងទី២) តំបន់២ (តំបន់រចនាសម្ព័ន្ធគំរោងផ្សេងៗ) និងតំបន់ ៣ (តំបន់តាមគន្លងខ្សែ១១៥គ.វ)។

៥.២.១០ តំបន់ទេសចរណ៍ (Resort)

យោងតាមការសិក្សាបានបង្ហាញអោយឃើញថានៅក្នុងតំបន់គំរោង និងតំបន់ក្បែរខាងនៃវារីអគ្គិសនីស្ទឹងអាតៃ ដែលស្ថិតនៅក្នុងឃុំអូរសោមនេះ មានតំបន់ទេសចរណ៍ធម្មជាតិបីកន្លែងសំខាន់ៗដូចជា តំបន់ព្រៃការពារក្រវាញរបស់ឃុំអូរសោម, តំបន់វាលវែងមានវាលស្មៅធំល្វឹងល្វើយនិងមានទេសភាពល្អត្រកាល, និងជំរកសត្វក្រពើភ្នំស្ថិតនៅក្នុងទឹកដីភូមិសាស្ត្រភូមិគៀនជង្រុក ដែលជាតំបន់ មានសក្តានុពលសំរាប់ទេសចរណ៍ ឬអេកូទេសចរណ៍ទៅថ្ងៃអនាគត។ ជាងនេះទៅទៀត គេអាចធ្វើអេកូទេសចរណ៍ ដោយចេញពីឆ្នេរសមុទ្រនៅកោះកុងដែលមានព្រៃកោងកាង មានតំបន់ក្បាលឆាយនៃ ព្រែកកោះប៉ោ ឬ ភ្ជាប់អេកូទេសចរណ៍ពីដីផាតតាមផ្លូវវារីអគ្គិសនីស្ទឹងឬស្សីជ្រុំ និងតាមផ្លូវវារីអគ្គសនីស្ទឹងអាតៃនេះដែលមានទេសភាពតាមដងផ្លូវ ល្អ អមជាមួយនូវព្រៃទឹកភ្លៀង

តំបន់ត្រូពិក ហើយមានអាកាសធាតុមិនសូវក្តៅដូច ទំបន់ទំនាបកណ្តាលយើងទេ។ នៅថ្ងៃអនាគត ពេលដែលវារីអគ្គិសនីទាំងពីរនេះដំណើរការ បង្កើតបានជាអាងទឹកសាបតាមដងស្ទឹងឫស្សីជ្រុំ និងអាតៃ គេអាចបង្កើតជាតំបន់កំសាន្តតាមទូកមើលសត្វព្រៃ និងសត្វទឹក ប្រសិនបើបញ្ឈប់ និងទប់ការបំផ្លាញព្រៃឈើបន្ថែមទៀត ឬទប់ស្កាត់ការស្កាព្រៃចាប់ដីធ្វើកម្មសិទ្ធឱ្យមានប្រសិទ្ធិភាពខ្ពស់តាមដងផ្លូវនេះ និងនៅតាមតំបន់ជុំវិញអាង និងបេះដូងព្រៃការពារក្រវាញភាគខាងត្បូង. ក្រវាញកណ្តាល រួមទាំងតំបន់ដែនជំរកសត្វព្រៃភ្នំសំកុសផងដែរ ។

សន្និដ្ឋានៈ

ឆ្លងតាមការសិក្សាសេដ្ឋកិច្ច-សង្គមរួចមកយើងអាចធ្វើការសន្និដ្ឋានបានថាៈ

នៅក្នុងឆ្នាំ២០១១នេះចំនួនគ្រួសារនៃប្រជាពលរដ្ឋក្នុងឃុំអូរសោមទាំងមូលបានកើនឡើងរហូតដល់២០% មូលហេតុដែលនាំ អោយមានកំណើននេះដោយសារមកពីៈ

- ដោយសារការស្តាឡើងវិញ និងធ្វើផ្លូវថ្មីរបស់ក្រុមហ៊ុនវិនិយោគវារីអគ្គិសនីស្ទឹងអាតៃ ដែលបង្ករលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងឃុំ និងអ្នកខាងក្រៅក្នុងការធ្វើដំណើរចាប់ពីខេត្តពោធិ៍សាត់រហូតខេត្តកោះកុងតាមរថយន្ត រឺម៉ូតូ ក្នុងការដឹកជញ្ជូនផលិតផលកសិកម្មទៅកាន់ទីផ្សារនៃខេត្តទាំងនេះ ។
- លំហូរចូលនៃជនចំណូលថ្មីមកតាំងទីលំនៅដើម្បីប្រកបមុខរបរផ្សេងៗដូចជា(ចំការពោត. សណ្តែក. ល្ង. ដំឡូងមី ពីព្រោះទឹកដីនេះមានភាពអំណោយផលផ្នែកកសិកម្ម) ។
- ការបំបែកគ្រួសារថ្មីដែលទើបរៀបអាពាហ៍ពិពាហ៍ ។

ប្រាក់ចំណូលប្រចាំឆ្នាំ២០១១របស់ប្រជាពលរដ្ឋម្នាក់ៗ កើនឡើងច្រើនពីរហូតដល់ទៅ ៤២១.២៧ ដុល្លា ស្មើ៣៥ % កត្តាដែលនាំអោយមានកំណើនប្រាក់ចំណូលគឺៈ

- ការវិនិយោគរបស់ក្រុនហ៊ុនC.H.D ដោយជ្រើសរើសប្រជាពលរដ្ឋរស់នៅក្នុងតំបន់គំរោងធ្វើជាកម្មករ
- ការដេញថ្លៃសំអាតអាងរបស់ក្រុនហ៊ុន MDS ដូច្នេះពួកគាត់មានឪកាសបានការងារ និងរកប្រាក់ចំណូល ។
- ការស្តាផ្លូវឡើងវិញចាប់ពីប្រម៉ោយមកដល់ឃុំអូរសោមដែលបង្ករលក្ខណៈងាយស្រួលសំរាប់ការដឹកផលិតផលដំណាំកសិកម្មដូចជា (ពោតក្រហម សណ្តែក ល្ង ដំឡូងមី ជាដើម) របស់ពួកគាត់ទៅកាន់ទីផ្សារនៅប្រម៉ោយ ឬទីរួមខេត្តពោធិ៍សាត់ និងឆ្ពោះទៅកាន់ខេត្តកោះកុង ឬក៏មានឈ្មួញចូលមកទិញផលិតផលរបស់ពួកគាត់ដល់ទីកន្លែងតែម្តង ។
- ផលចំណេញពីការជួញដូរអនុផលព្រៃឈើជាពិសេសគឺក្រញូង ។
- នៅក្នុងឆ្នាំ២០១១នេះប្រភេទជំងឺគ្រុនចាញ់បានកើនឡើងរហូតដល់ទៅ១៤% . ជំងឺគ្រុនឈាមកើនឡើងតែ ៣.៥ % ដោយសារមានកំណើនប្រជាជនខ្លាំង ហើយតំបន់នេះមិនទាន់មានការទប់ស្កាត ឬការពារ ព្យាបាលជំងឺទាំងនេះឱ្យបានច្រើននៅឡើយទេ ។